**សាកលវិទ្យាល័យជាតិគ្រប់គ្រង**

National University of Management

# ហិរញ្ញវត្ថុសាធារណៈ



**លោក ជាវ គីរីរម្យ**

រក្សាសិទ្ធិគ្រប់យ៉ាង

ឆ្នាំ ២០២១

# ហិរញ្ញវត្ថុសាធារណៈ

និពន្ធដោយ

**លោក ជាវ គីរីមៀ**

**បោះពុម្ពផ្សព្វផ្សាយលើកទី១**

**រក្សាសិទ្ធិគ្រប់យ៉ាង**

**ព.ស. ២៥៦៥ គ.ស. ២០២១**

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានបង្កើតឡើងដោយបរិបូណ៌នៅឆ្នាំ១៩៩៨ កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨ភាគរយ ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣ភាគរយ នៅឆ្នាំ២០០៤ មកនៅទាបជាង១០ភាគរយ នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាព សម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឲ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤.០ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មីនវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤ភាគរយ នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ផងដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥ភាគរយនៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០ភាគរយនៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០ភាគរយនៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួត

ប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤.០ នៅក្នុងសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ ហើយដែល ប្រការនេះចាំបាច់តម្រូវឲ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែល ប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បី ទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពី ឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធាន អតិកម្ម (Labour and Resource Based-Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លង ដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមាន សមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាព នៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជា មានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរក នវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកប ដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិ នឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិ និងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជា សង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បាន ពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេ លក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខ នព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ជាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គម ដែល ប្រកបដោយពុទ្ធិ គឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជា នវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែក រំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយ ការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សា ជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះ នឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀន និងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបដោយពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឲ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ច ដែល ពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់

តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិក និងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្ដុះវប្បធម៌អំណាន និងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឲ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង ២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ពដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណាន ក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរស័ព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឲ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណាក៏ដោយ ក៏អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើប តាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាព នៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឲ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចម្រុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់ និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាព នៃការផលិតធនធានអប់រំឌីជីថលគួបផ្សំជាមួយការចែកសន្លឹកកិច្ចការឲ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឲ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្ដិសិទ្ធិ និងផ្ដល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស

និស្សិត និងសាធារណជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្ត និងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឲ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឲ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និង និស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឲ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញ ឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀននិងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឲ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឲ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឲ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំ និងចំណាយពេលអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិដែលជាមាតាបិតា ឬអ្នកអាណាព្យាបាលសូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ **ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា** (Text book) **ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវ នៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈការចែករំលែកបទពិសោធន៍និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សា ជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួចហើយ សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំសូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សានិងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្ដីបញ្ជាក់
# នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះ ជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរ និងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# អារម្ភកថា

ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការសិក្សា ការរៀនសូត្រ និងការលើកកម្ពស់អំណានឯកសារសិក្សាស្រាវជ្រាវ ដែលជាខេមរភាសាក្នុងកម្រិតឧត្តមសិក្សា សៀវភៅហិរញ្ញវត្ថុសាធារណៈ ភាគទី១ ត្រូវបានរៀបចំឡើងស្របតាមកម្មវិធីសិក្សា និងឆ្លុះបញ្ចាំងពីទ្រឹស្តី គោលនយោបាយ អនុវត្តន៍ និងដំណោះស្រាយ។ ការសិក្សាហិរញ្ញវត្ថុសាធារណៈ គឺជាការសិក្សាផ្នែកមួយនៃសេដ្ឋកិច្ចវិទ្យា ដែលផ្តោតជាពិសេសទៅលើផ្នែកសាធារណៈ ឬសំដៅទៅលើផ្នែករដ្ឋាភិបាល ដែលជាប់ពាក់ព័ន្ធចំណូល និងចំណាយ។ តួនាទីរបស់រដ្ឋាភិបាលបានក្លាយជាកម្លាំងចលករប្រកបដោយកម្លាំងថាមពលមហិមា ក្នុងដំណោះស្រាយបញ្ហាសេដ្ឋកិច្ចសាធារណៈនានា ដូចជាការគាំពារសុខភាពសាធារណៈ សុវត្ថិភាពសង្គម ការរក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ច ការបែងចែកចំណូលឡើងវិញ ការកាត់បន្ថយគម្លាតរវាងអ្នកមាន និងអ្នកក្រ ឬការកាត់បន្ថយភាពក្រីក្រ ការលើកស្ទួយសុខុមាលភាពនៃសេចក្តីសុខ និងការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការត្រួតពិនិត្យនិងវាយតម្លៃផលប៉ះពាល់ និងការដោះស្រាយផលប៉ះពាល់ខាងក្រៅជាដើម។

លើសពីនេះទៀត សៀវភៅហិរញ្ញវត្ថុសាធារណៈ ភាគទី១នេះ នឹងក្លាយជាស្នាដៃថ្មីមួយ ដែលត្រូវបានចងក្រង និងលើកយកពីបរិបទប្រទេសកម្ពុជាជាក់ស្តែង ដើម្បីឆ្លើយតបឲ្យស្របបច្ចុប្បន្នភាព ចំពោះកិច្ចការជាអទិភាពនៃមុខងារហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាដើម្បីបំពេញតម្រូវការរបស់អ្នកសិក្សាស្រាវជ្រាវឲ្យទាន់បរិបទសេដ្ឋកិច្ចសង្គម ស្របនឹងគោលនយោបាយអនុវត្តហិរញ្ញវត្ថុសាធារណៈ របស់ព្រះរាជាណាចក្រកម្ពុជាផងដែរ។ ហើយអ្នកនិពន្ធសង្ឃឹមយ៉ាងមុតមាំថា សៀវភៅហិរញ្ញវត្ថុសាធារណៈ ភាគទី១នេះ នឹងជួយផ្តល់នូវពុទ្ធិសំខាន់ៗ ជាស្ពានចំលងដល់ការសិក្សាមុខវិជ្ជាហិរញ្ញវត្ថុសាធារណៈ និងសេដ្ឋកិច្ចសាធារណៈ និងមុខវិជ្ជាដែលពាក់ព័ន្ធដទៃៗទៀតផងដែរ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏សៀវភៅនេះនៅតែមានចន្លោះខ្វះខាត និងមានកំហុសដោយប្រការណាមួយជាក់ជាមិនខានឡើយ។

ជាចុងបញ្ចប់ ខ្ញុំបាទជាអ្នកនិពន្ធ សូមឲ្យមិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវជួយផ្តល់នូវយោបល់ និងមតិរិះគន់ទាំងឡាយដើម្បីធ្វើការស្ថាបនា និងកែលម្អឲ្យកាន់តែប្រសើរឡើងថែមទៀត ដោយក្តីអនុគ្រោះ និងការយោគយល់បំផុតចំពោះការខ្វះខាត កំហុស និងការឆកល្វែងដែលមានក្នុងសៀវភៅនេះ។ ហើយខ្ញុំបាទមានសេចក្តីសោមនស្សរីករាយ ក្នុងការទទួលយកនូវគ្រប់មតិយោបល់ ដើម្បីអភិវឌ្ឍសៀវភៅនេះក្នុងការបោះពុម្ពផ្សព្វផ្សាយលើកៗក្រោយទៀត។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១

**ជាច គីរីរម្យ**

# សេចក្តីថ្លែងអំណរគុណ


សៀវភៅហិរញ្ញវត្ថុសាធារណៈដែលកំពុងមានវត្តមានក្នុងការសិក្សានេះ គឺជាស្នាដៃមួយដែលបានកើតឡើងពីការរួមចំណែកយ៉ាងធំធេង និងការជួយជំរុញជ្រោមជ្រែងយ៉ាងអស់ពីចិត្ត និងដោយមិនអាចខ្វះបានពីគ្រប់មជ្ឈដ្ឋាន។ អ្នកនិពន្ធ សូមគោរពសំដែងនូវការដឹងគុណ និងមានកតញ្ញូតាចំពោះ៖

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិតនិងនវានុវត្តន៍ ដែលបានផ្តួចផ្តើមគំនិត បង្កើតឲ្យមានការលើកស្ទួយកម្មវិធីស្រាវជ្រាវ និងផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។

ឯកឧត្តមបណ្ឌិត ហោ ប៉េង សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងចំពោះការជំរុញ លើកទឹកចិត្តយ៉ាងខ្លាំងក្លាឲ្យមានការចូលរួមសិក្សាស្រាវជ្រាវ និងនិពន្ធសៀវភៅដើម្បីជាស្នាដៃដ៏មានតម្លៃ និងគុណតម្លៃជាប្រយោជន៍នៃការសិក្សាអប់រំ ស្រាវជ្រាវ និងការកសាងធនធានមនុស្សសម្រាប់ប្រទេសជាតិទាំងមូល។

លោកបណ្ឌិត កុយ កុសល ព្រឹទ្ធបុរសនៃមហាវិទ្យាល័យហិរញ្ញវត្ថុ និងគណនេយ្យ លោកបណ្ឌិត សៀម មុនីលក្ខណ៍ លោក កុល បូរ៉ន និងលោក ជ័យ សុវណ្ណរិទ្ធ ព្រឹទ្ធបុរសរងមហាវិទ្យាល័យដែលបានជួយណែនាំ និងផ្តល់យោបល់ និងលើកទឹកចិត្តឲ្យមានការចូលរួមសិក្សាស្រាវជ្រាវ និងនិពន្ធសៀវភៅសម្រាប់ជាប្រយោជន៍សិក្សាក្នុងមហាវិទ្យាល័យហិរញ្ញវត្ថុ និងគណនេយ្យ។

លោកបណ្ឌិត លី សុខហេង សាកលវិទ្យាធិការង លោកស្រី ប៉ុក ភារ៉ុន និងបណ្តាមិត្តរួមការងារទាំងអស់នៃអាជ្ញាធរសវនកម្មជាតិ ជាពិសេសលោក ទៀប សុត្ថា ដែលតែងតែបានជួយគាំទ្រ ផ្តល់យោបល់ ត្រួតពិនិត្យ កែតម្រូវ កែលម្អ និងលើកទឹកចិត្តក្នុងការនិពន្ធសៀវភៅនេះឡើង។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ លោកឪពុក ហោ ជាវ និងអ្នកម្តាយ ទុយ ម្លិះ ដែលជាអ្នកមានគុណទាំងពីរ ដែលលោកបានបង្កើត ខិតខំចិញ្ចឹមបីបាច់ថែរក្សា និងបានលះបង់យ៉ាងធំធេង ឥតឧបមាចំពោះខ្ញុំបាទ ប្រកបដោយសណ្តានចិត្តស្មោះស សេចក្តីមេត្តាករុណាដែលជាព្រហ្មវិហារធម៌ដ៏ប្រពៃ។ ហើយខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះ លោក ជាវ ផល្លា លោកស្រី ជាវ គន្ធា លោក ជាវ គីរីរិទ្ធ និងលោកស្រី ជាវ រតនា ដែលត្រូវជាបងប្អូនប្រុសស្រីបង្កើត ដ៏ល្អរបស់ខ្ញុំបាទផងដែរ។

# មាតិកា


ទំព័រ

**បុព្វកថា** ---- I

**សេចក្ដីបញ្ជាក់** ---- VI

**អារម្ភកថា** ---- VII

**សេចក្ដីថ្លែងអំណរគុណ** ---- VIII

**មាតិកា** ---- IX

**ជំពូកទី១៖ សេចក្ដីផ្ដើមនៃហិរញ្ញវត្ថុសាធារណៈ** ---- 1

**មេរៀនទី១៖ សញ្ញាណអំពីហិរញ្ញវត្ថុសាធារណៈ** ---- 3

១. សេចក្ដីផ្ដើម ---- 3

២. និយមន័យនៃហិរញ្ញវត្ថុសាធារណៈ ---- 6

៣. រដ្ឋាភិបាល និងកិច្ចអន្តរាគមន៍ ---- 7

៣.១. មុខងារនៃវិភាជន៍ធនធាន ---- 13

៣.២. មុខងារនៃបំណែងចែកចំណូល ---- 15

៣.៣. មុខងារនៃស្ថិរកម្ម ---- 18

៤. គោលនយោបាយ និងវិស័យសាធារណៈ ---- 21

**មេរៀនទី២៖ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសារពើពន្ធ** ---- 26

១. សេចក្ដីផ្ដើម ---- 26

២. ក្របខ័ណ្ឌច្បាប់ហិរញ្ញវត្ថុ និងសារពើពន្ធ ---- 28

៣. សិទ្ធអំណាច និងការទទួលខុសត្រូវ ---- 30

៤. ច្បាប់ហិរញ្ញវត្ថុ ---- 33

៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ---- 33

៥.១. តួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ---- 34

៥.២. រចនាសម្ព័ន្ធថ្នាក់កណ្ដាល ---- 36

៥.៣. រចនាសម្ព័ន្ធថ្នាក់មូលដ្ឋាន ---- 37

៦. ធនាគារកណ្ដាល ---- 37

៦.១. តួនាទី មុខងារ និងភារកិច្ចរបស់ធនាគារកណ្ដាល ---- 38

៦.២. សម្ព័ន្ធការផ្ទេរហិរញ្ញវត្ថុជាមួយអង្គភាពសាធារណៈ ---- 39

៧. សវនកម្មជាតិ ---- 40

៧.១. តួនាទីសវនកម្មជាតិ ---- 41

៧.២. ប្រភេទសវនកម្ម ---- 42

៨. សវនកម្មផ្ទៃក្នុង ---------- 44

៩. មុខងារ និងការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង ---------- 44

១០. រដ្ឋសភា ---------- 47

១០.១. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ---------- 47

១០.២. គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម 49

១០.៣. ថវិការដ្ឋសភា ---------- 51

១១. កំណរកំណើតសារពើពន្ធ ---------- 52

១២. ប្រព័ន្ធសារពើពន្ធ ---------- 53

១២.១. របបកំណត់ពន្ធ ---------- 56

១២.២. ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ---------- 57

១២.៣. ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្ម ---------- 59

១៣. ការគ្រប់គ្រងចំណូលពន្ធ ---------- 60

១៤. អគ្គនាយកដ្ឋានពន្ធដារ ---------- 60

១៥. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ---------- 62

មេរៀនទី៣៖ ថវិកា ---------- 64

១. សេចក្ដីផ្ដើម ---------- 64

២. និយមន័យ ---------- 66

៣. ចរិតលក្ខណៈនៃថវិកា ---------- 69

៤. តួនាទី និងសារៈសំខាន់នៃថវិកា ---------- 71

៥. រចនាសម្ព័ន្ធថវិកា ---------- 71

៥.១. ចំណូល ---------- 72

៥.២. ចំណាយ ---------- 72

៥.៣. ចំណូល និងចំណាយថវិកាថ្នាក់ជាតិ ---------- 73

៦. គោលការណ៍សំខាន់ៗនៃថវិកា ---------- 74

៦.១. គោលការណ៍ការិយបរិច្ឆទមានកាលកំណត់មួយឆ្នាំ ---------- 74

៦.២. គោលការណ៍ឯកភាព ---------- 75

៦.៣. គោលការណ៍សកលភាព ---------- 75

៦.៤. គោលការណ៍ឯកទេសភាព ---------- 75

៦.៥. គោលការណ៍តុល្យភាព ---------- 76

៧. ក្របខ័ណ្ឌប្រព័ន្ធថវិកា ---------- 76

៧.១. ក្របខ័ណ្ឌនយោបាយ ---------- 77

៧.២. ក្របខ័ណ្ឌសេដ្ឋកិច្ច ---------- 77

៧.៣ ក្របខ័ណ្ឌនៃការរៀបចំថវិកានៅកម្ពុជា ---------- 78

៨. ដំណើការរៀបចំថវិកា ---- 80
  ៨.១ ដំណើរការរៀបចំណូល ---- 80
  ៨.២. ដំណើរការរៀបចំចំណាយ ---- 81
  ៨.៣. របាយការណ៍ដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា ---- 82
  ៨.៤. សេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុ ---- 83
៩. ការអនុម័តច្បាប់ហិរញ្ញវត្ថុ ---- 83
១០. ការអនុវត្តថវិកា ---- 85
  ១០.១. ក្របខ័ណ្ឌនៃការអនុវត្តថវិកា ---- 85
  ១០.២. ការអនុវត្តថវិកា ---- 86
  ១០.៣. ដំណើរការនៃការអនុវត្តថវិកា ---- 87
១១. គណនេយ្យ និងការត្រួតពិនិត្យលទ្ធផល ---- 88
  ១១.១. ក្របខ័ណ្ឌគណនេយ្យ និងការទូទាត់ថវិកា ---- 88
  ១១.២ ក្របខ័ណ្ឌគណនេយ្យ ការត្រួតពិនិត្យលទ្ធផល ---- 88
១២. ទោសប្បញ្ញត្តិ ---- 91
១៣. វិធីសាស្ត្រនៃការរៀបចំថវិកា ---- 91
  ១៣.១. គោលការណ៍នៃប្រព័ន្ធថវិកាផ្អែកលើថវិកាកម្មវិធី ---- 92
  ១៣.២. គោលការណ៍នៃប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម ---- 94
ឯកសារយោង ---- 97

# ជំពូកទី១៖ សេចក្តីផ្តើមនៃហិរញ្ញវត្ថុសាធារណៈ

នៅពេលដែលគេស្តាប់ឮ ឬនិយាយអំពីហិរញ្ញវត្ថុសាធារណៈ នោះគេតែងតែលើកនិយាយអំពីប្រាក់ចំណូល និងបន្ទុកចំណាយរបស់រដ្ឋាភិបាលក្នុងប្រព័ន្ធសេដ្ឋកិច្ច។ ហិរញ្ញវត្ថុសាធារណៈ គឺជាការសិក្សាអំពីបណ្តាទំនិញសាធារណៈ និងសេវាសាធារណៈ ដែលត្រូវបានផ្តល់ជូនតាមរយៈសកម្មភាពវិស័យសាធារណៈ និងការធ្វើហិរញ្ញប្បទានរបស់រដ្ឋាភិបាល។ ហិរញ្ញវត្ថុសាធារណៈសំដៅដល់ចំណូល និងចំណាយ ប្រចាំឆ្នាំរបស់រដ្ឋាភិបាល ដែលរាល់សម្មភាពទាំងឡាយពាក់ព័ន្ធទៅនឹងហិរញ្ញវត្ថុ និងការទូទាត់ផ្សេងៗត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្តកិច្ចការ ការងារ សកម្មភាព មុខងារសាធារណៈ កម្មវិធីក្រសួង ស្ថាប័ន និងកាតព្វកិច្ច ការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដើម្បីបម្រើផលប្រយោជន៍ និងធានាឲ្យបាននូវសុខុមាលភាពសេដ្ឋកិច្ចចំពោះប្រជាជន និងសាធារណជនជាដើម[1]។ ហិរញ្ញវត្ថុសាធារណៈមិនត្រឹមតែជាមុខវិជ្ជាថ្មីទំនើបដែលត្រូវបានលើកយកមកសិក្សា ក្នុងកិច្ចការរដ្ឋាភិបាលតាំងសម័យបុរាណដែលមានលក្ខណៈតូចចង្អៀត និងនៅមានកម្រិតនៅឡើយ ប៉ុន្តែតាមបែបលក្ខណៈវិទ្យាសាស្ត្រ មុខវិជ្ជានេះត្រូវបានបន្តយកមកសិក្សាយ៉ាងទូលំទូលាយ និងយ៉ាងយកចិត្តទុកដាក់ខ្លាំងរហូតមកដល់សម័យបច្ចុប្បន្ន។ កំណត់ត្រាចំណូល ចំណាយក្នុងប្រព័ន្ធបែបបុរាណនៅក្នុងសម័យនោះលក្ខណៈ ទ្រង់ទ្រាយ និងរបៀបនៅមានកម្រិតខ្លាំង ពីព្រោះមុខងារ និងតួនាទី សកម្មភាពផ្សេងៗរបស់រដ្ឋាភិបាលក៏នៅមិនទាន់ជឿនលឿនរីកចម្រើនខ្លាំងដែរ។ ដើម្បីដោះស្រាយបញ្ហានេះ មុខងារ និងតួនាទីរបស់រដ្ឋាភិបាលក្នុងហិរញ្ញវត្ថុសាធារណៈទំនើបត្រូវបានគ្រប់គ្រង បែងចែក ប្រមែប្រមូល គៀរគរ និងអនុវត្តចំណូល និងចំណាយជាបន្តបន្ទាប់ប្រកបដោយតម្លាភាព គណនេយ្យភាព ស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព និងចីរភាព។ ជាពិសេសដើម្បីបង្កើតឲ្យមានសុខុមាលភាពសេដ្ឋកិច្ចល្អ និងធានាឲ្យជីវភាពសេដ្ឋកិច្ចរបស់ប្រជាជនមានលក្ខណៈធូរធារប្រសើរ (Toshihiro, 2017 & Richard et al. 2013)។

ប្រទេសនៅជុំវិញពិភពលោកមានបញ្ហាប្រឈមស្រដៀងគ្នា និងភាពប្រគួតប្រជែងជាច្រើនក្នុងការកំណត់ ថាតើសកម្មភាពអ្វីខ្លះដែលរដ្ឋាភិបាលគួរតែអនុវត្ត និងថាតើសកម្មភាពទាំងនេះគួរតែត្រូវបានផ្តល់ហិរញ្ញប្បទានយ៉ាងដូចម្តេច? និងធ្វើដោយរបៀបណា? សេដ្ឋវិទូតែងតែគិតពិចារណាអំពីបញ្ហាលំបាកទាំងនេះយ៉ាងល្អិតល្អន់ជាយូរណាស់មកហើយ។ ដូច្នេះសំណួរទាំងនេះ មានប្រយោជន៍ជាច្រើនក្នុងការចាប់ផ្តើមការសិក្សាហិរញ្ញវត្ថុសាធារណៈ ដោយពិនិត្យឡើងវិញនូវទស្សនៈរបស់សេដ្ឋវិទូអំពីតួនាទីសមស្របរបស់រដ្ឋាភិបាល នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារទំនើប (Jonathan, 2011)។

សព្វថ្ងៃនេះមុខងាររបស់រដ្ឋាភិបាលមិនត្រឹមតែរៀបចំសន្តិសុខការពារជាតិ កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អប់រំ សុខាភិបាល និងការរៀបចំប្រព័ន្ធច្បាប់ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ផ្សេងៗតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តការងារសុខុមាលភាពជាច្រើនដូចជា ការកាត់បន្ថយភាពក្រីក្រ

---

[1] សូមមើល https://en.wikipedia.org/wiki/Public_finance។

ការផ្តល់ឧបត្ថម្ភធនជាសាច់ប្រាក់ ឬការគាំពារសង្គម ការផ្តល់ជាទំនិញសាធារណៈ សេវាសាធារណៈ ដល់ប្រជាពលរដ្ឋ និងការផ្តល់អាហារូបករណ៍ជាដើម។ ការធ្វើផែនការសេដ្ឋកិច្ចសង្គម និងរលកនៃកំណើនសេដ្ឋកិច្ច បានកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការស្នូលរបស់រដ្ឋាភិបាល និងជួយជំរុញពង្រីកពង្រឹងរចនាសម្ព័ន្ធនៃការងារ និងមុខងាររបស់រដ្ឋាភិបាល ការលើកស្ទួយកំណើនការងាររបស់ប្រជាជន ការការពារបរិស្ថានស្អាត ការរក្សាស្ថិរភាពថ្លៃ ការរក្សាអតិផរណាកម្រិតទាប ការពង្រឹងសមធម៌សង្គម និងការកាត់បន្ថយអំពើពុករលួយ។ល។ តាមធម្មតា ចំណូល និងចំណាយនឹងកើនឡើងក្នុងពេលជំណាលគ្នា ស្របគ្នាជាមួយនឹងការបង្កើនមុខងារសកម្មភាព និងតួនាទីរបស់រដ្ឋាភិបាល ( Joshua E. Greene, 2012 & Auld and Miller, 1984 )។

សព្វថ្ងៃនេះហិរញ្ញវត្ថុសាធារណៈ បានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងកិច្ចការសកម្មភាព ជាគោលនយោបាយអភិវឌ្ឍជាតិ និងជាឧបករណ៍ដ៏មានប្រសិទ្ធភាព ប្រសិទ្ធផល ក្នុងការអនុវត្តកម្មវិធីផែនការសកម្មភាព យុទ្ធសាស្ត្រនយោបាយ និងគោលនយោបាយស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅក្នុងបរិបទឧស្សាហកម្មជំនាន់ទី៤.០ ទំនើប។

នៅក្នុងសៀវភៅហិរញ្ញវត្ថុសាធារណៈ ភាគទី១ ដែលមានជំពូកទី១ នឹងត្រូវគ្របដណ្តប់ដោយចំនួន ៣ មេរៀនគឺ៖ មេរៀន១៖ សញ្ញាណអំពីហិរញ្ញវត្ថុសាធារណៈ មេរៀនទី២៖ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសារពើពន្ធ ហើយមេរៀនទី៣៖ ថវិកា ដែលមេរៀននីមួយៗបង្ហាញពីការយល់ដឹងអំពីហិរញ្ញវត្ថុសាធារណៈ និងសារៈសំខាន់តាមមុខងារ និងផ្នែកនីមួយៗផ្សេងៗគ្នា។ មេរៀនទី១ ស្តីអំពីសញ្ញាណអំពីហិរញ្ញវត្ថុសាធារណៈ ដែលអ្នកសិក្សាអាចយល់អំពីការកំណត់និយមន័យរបស់ហិរញ្ញវត្ថុសាធារណៈ វិសាលភាព និងសារប្រយោជន៍ នៃមុខងារហិរញ្ញវត្ថុសាធារណៈសំខាន់ៗដូចជា វិភាជន៍ធនធាន បំណែងចែកចំណូល និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាដើម។ មេរៀនទី២ បង្ហាញអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសារពើពន្ធនៅប្រទេសកម្ពុជា ដែលសំដៅសិក្សាអំពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ការវិវត្តនៃពន្ធដារ យន្តការ និងគោលនយោបាយកំណែទម្រង់សារពើពន្ធនៅកម្ពុជា ហើយមេរៀនទី៣ និយាយអំពីថវិកាជាតិជាច្បាប់ ដំណើរការរៀបចំថវិកា ដែលជាឧបករណ៍នយោបាយរបស់រដ្ឋាភិបាលប្រើប្រាស់យ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយថវិកាជាតិ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា[2]។

[2] សូមមើល ទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០។

# មេរៀនទី១៖ សញ្ញាណអំពីហិរញ្ញវត្ថុសាធារណៈ

## ១. សេចក្តីផ្តើម

នៅក្នុងអំឡុងឆ្នាំ១១៧៧[3] ពួកចាមបានលើកទ័ពមកធ្វើការលុកលុយ ត្រួតត្រាប្រទេសកម្ពុជាអស់រយៈពេលប្រមាណ៤ឆ្នាំ ខណៈនោះដោយឥទ្ធិពលអំណាច ការចេះដឹង ពិសោធន៍ និងប្រាជ្ញាភ្លឺថ្លាឈ្លាសវៃ នៃការដឹកនាំប្រទេសក្នុងសម័យបុរាណ នៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានធ្វើការបង្រួមបង្រួមជាតិ ចំណាយពេលវេលារៀបចំយុទ្ធសាស្ត្រកងទ័ពប្រយុទ្ធប្រឆាំង ច្បាំងតតាំងនឹងពួកចាម យ៉ាងស្វិតស្វាញដើម្បីរំដោះប្រទេសជាតិឲ្យរួចផុតពីការជិះជាន់ រហូតដល់ទទួលបានជ័យជម្នះ ហើយព្រះអង្គបានឡើងគ្រងរាជ្យសម្បត្តិ ដឹកនាំប្រទេសជាតិនៅក្នុងឆ្នាំ១១៨១[4] ក្នុងព្រះជន្មាយុ៥៦ព្រះវស្សា និងបានធ្វើឲ្យប្រទេសជាតិមានការរីកចម្រើនរុងរឿង ដល់កម្រិតកំពូលស្ទើរគ្រប់វិស័យ និងប្រែក្លាយទៅជាចក្រភពរុងរឿង ល្បីល្បាញ ជាមហាអំណាចមួយយ៉ាងធំនៅក្នុងអាស៊ីអាគ្នេយ៍។

ព្រះបាទជ័យវរ្ម័នទី៧ គឺជាមហាក្សត្រដែលមានឫទ្ធិអំណាចខ្លាំងក្លាក្នុងសម័យអង្គរ និងបានដឹកនាំប្រទេសជាតិឲ្យរីកចម្រើនឈានទៅមុខ ប្រកបដោយទសពិធរាជធម៌ និងមានព្រហ្មវិហារធម៌ និងបានបន្សល់នូវសមិទ្ធផល នៃស្នាព្រះហត្ថដ៏ល្បីល្បាញរបស់ព្រះអង្គជាច្រើន។ ព្រះអង្គបានដឹកនាំរៀបចំប្រទេសជាតិឲ្យមានស្ថិរភាព កសាងប្រាសាទតូច និងធំស្កឹមស្កៃជាច្រើន ជាពិសេសគឺប្រាសាទបាយ័ន កសាងហេដ្ឋារចនាសម្ព័ន្ធស្ពាន ផ្លូវថ្នល់ សាងសង់សាលាសំណាក់ទាំងអស់ ចំនួន១២១ ប្រព័ន្ធធារាសាស្ត្រពាសពេញផ្ទៃប្រទេស កសាងទំនុកបម្រុងសាសនា សម្រាប់ផលប្រយោជន៍ដល់សង្គមជាតិ និងប្រជាជន និងកសាងមន្ទីរពេទ្យចំនួន១០២ នៅទូទាំងប្រទេស សម្រាប់សារធារណៈជនចូលសម្រាកព្យាបាល ដោយមិនប្រកាន់ទៅលើវណ្ណៈ ព្រោះព្រះបាទជ័យវរ្ម័នទី៧ ជាព្រះមហាក្សត្រដែលយកចិត្តទុកដាក់លើសន្តិសុខជាតិ សុវត្ថិភាព ជីវភាព សុខុមាលភាព និងសុខភាព របស់ប្រជាជនរបស់ព្រះអង្គ ដូចក្នុងសិលាចារឹកនៃមន្ទីរពេទ្យរបស់ព្រះអង្គបានចែងថា៖ «**ជំងឺរបស់ប្រជារាស្ត្រធ្វើឲ្យព្រះអង្គឈឺចាប់ជាងជំងឺផ្ទាល់របស់ព្រះអង្គទៅទៀត ព្រោះថាសេចក្តីឈឺចាប់សាធារណៈនេះហើយ ដែលជាសេចក្តីឈឺចាប់របស់ព្រះរាជាទាំងឡាយ ពុំមែនសេចក្តីឈឺចាប់ផ្ទាល់ទេ ដែលអាចធ្វើឲ្យព្រះអង្គឈឺចាប់បាននោះ**»[5]។

ចាប់តាំងពីការចុះសន្ធិសញ្ញាអាណាព្យាបាលបារាំងឆ្នាំ១៨៦៣ បារាំងបានធ្វើការកំណែទម្រង់រដ្ឋបាល និងបានរឹតបន្តឹងអំណាចរបស់ខ្លួននៅកម្ពុជា ព្រមទាំងធ្វើការពង្រីករបបគ្រប់គ្រង និង

[3] សូមមើល ប្រវត្តិសាស្ត្រសង្ខេបនៃរាជធានីក្នុងតំបន់អង្គរ និងសង្គមខ្មែរក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៧ បកប្រែចេញពីសៀវភៅរបស់ ហិសតុ និងរៀបចំចងក្រងដោយសម្រួលជាភាសាខ្មែរដោយ អ្លូង វង (២០០៦)។

[4] សូមមើល ត្រឹង ងា (២០០១) ប្រវត្តិសាស្ត្រខ្មែរ និង ខួយ ខេមរិន ប្រវិត្តិសាស្ត្រកម្ពុជា (១៩៨៨)។

[5] សូមមើល ខាត់ ធី ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (២០០៩) និងមីសែល ត្រាណេ ព្រះបាទជ័យវរ្ម័នទី៧ និងប្រវត្តិសាស្ត្រនៃកម្ពុជា សង្គមខ្មែរក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (១៩៩៦ និង២០០៣)។

អាណាព្យាបាលរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយស្ថានភាពរបស់ប្រជាជននៅក្រោម អាណាព្យាបាលបារាំងមានភាពលំបាកច្រើន ហើយបារាំងកាន់តែរឹតបន្តឹង ធ្វើបាបប្រជារាស្ត្រខ្មែរកាន់តែខ្លាំងឡើងៗ ជាពិសេសគឺការដាក់បញ្ញត្តិកម្រិតធ្ងន់ធ្ងរ ការគៀបសង្កត់[6] និងការបង្ខិតបង្ខំឲ្យមានការបង់ពន្ធទៅលើអ្វីៗគ្រប់យ៉ាងដូចជា ការបង់ពន្ធមនុស្ស ពន្ធដីធ្លី ពន្ធលំនៅដ្ឋាន ពន្ធសត្វពាហនៈ ពន្ធយានជំនិះ និងពន្ធផលរបរអាជីវកម្ម។ល។ ដើម្បីបង់ពន្ធជាប្រាក់កាសឲ្យបារាំង ប្រជាកសិករខ្មែរបានខិតខំពង្រីកដំណាំដាំដុះស្រូវ ពោត សណ្តែក និងដំណាំឧស្សាហកម្ម ដូចជាដំណាំកៅស៊ូជាដើម។ ប៉ុន្តែទិន្នផលដែលទទួលបានមិនសូវល្អ ដោយផលស្រូវក្នុងមួយហិចតា បានត្រឹមតែ១តោន ទៅ១.២តោន ហើយប្រជាជនកសិករ ក្លាយទៅជាអ្នកជាប់បំណុលពួកឈ្មួញកណ្តាល និងឈ្មួញបរទេស ដែលធ្វើឲ្យជីវភាពកាន់តែយ៉ាប់ និងក្រីក្រតោកយ៉ាក ឈឺចាប់កើនមានកាន់តែខ្លាំងឡើងៗ។

ក្រោយពីឯករាជ្យពេញលេញនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ រហូតមកដល់ក្នុងសម័យសង្គមរាស្ត្រនិយម ប្រទេសកម្ពុជា ចាប់ផ្តើមមានការរីកចម្រើនលើគ្រប់វិស័យ និងត្រូវបានគេចាត់ទុកថាជាគជអាស៊ី ក្រោមការដឹកនាំរបស់ព្រះបាទនរោត្តមសីហនុ។ ព្រះអង្គបានយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយពង្រីកផ្ទៃដីកសិកម្ម ធ្វើការជ្រើសរើសពូជ ធ្វើនយោបាយទឹក បង្កើតប្រព័ន្ធធារាសាស្ត្រ អភិវឌ្ឍវិស័យគមនាគមន៍ កសាងពង្រីកកំពង់ផែភ្នំពេញ និងកំពង់ផែក្រុងព្រះសីហនុ កសាងផ្លូវថ្នល់ ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង ដែលបច្ចុប្បន្នជាអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងកសាងអាកាសយានដ្ឋានអន្តរជាតិសៀមរាប កសាងផ្លូវរថភ្លើង កសាងស្ពានជ្រោយចង្វារ និងការភ្ជាប់ខ្សែទូរស័ព្ទ ព្រះអង្គក៏បានកសាងរោងចក្រជាច្រើនដូចជា រោងចក្រវាយនភ័ណ្ឌ រោងចក្រក្តារបន្ទះ រោងចក្រកែវ រោងចក្រក្រដាស រោងចក្រស៊ីម៉ងត៍ រោងចក្របាវក្រចៅ រោងចក្រដំឡើងត្រាក់ទ័រ រោងចក្រចម្រាញ់ប្រេងកាត និងរោងចក្រស្រាបៀរ កសាងទំនប់វារីអគ្គិសនី កសាងមន្ទីរពេទ្យ ចាត់វិធានការការពារដោយចាក់ថ្នាំបង្ការការពារជំងឺរាតត្បាត កសាងសាលារៀន ធ្វើយុទ្ធនាការបំបាត់អនក្ខរភាព យកចិត្តទុកដាក់វិស័យសិក្សាធិការដោយបណ្តុះបណ្តាលគ្រូបង្រៀន និងបញ្ជូននិស្សិតទៅសិក្សានៅបរទេស។ល។ ការអនុវត្តគោលនយោបាយជាតូនីយកម្មសេដ្ឋកិច្ច ធ្វើឲ្យហិរញ្ញវត្ថុសាធារណៈ ជាពិសេសថវិកាជាតិមានឱនភាពខ្លាំង រូបិយវត្ថុជាតិបាត់បង់តម្លៃ និងការគ្រប់គ្រងសហគ្រាសរដ្ឋគ្មានប្រសិទ្ធភាព ដែលធ្វើឲ្យមានវិបត្តិសេដ្ឋកិច្ច និងវិបត្តិនយោបាយ ក្នុងបរិបទនៃសង្គ្រាមត្រជាក់[7]។

ដោយមានការប្តេជ្ញាចិត្តខាងនយោបាយជាយុទ្ធសាស្ត្រដ៏មុតមាំ និងអង់អាចធ្វើឲ្យប្រទេសកម្ពុជាទទួលបាននូវសន្តិភាពពេញលេញ ដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងដើម្បីបុព្វហេតុកសាងជាតិមាតុភូមិ ធានាដល់សន្តិសុខសង្គម ការបង្រួបបង្រួមជាតិ ការឯកភាពជាតិ ការរក្សាសន្តិភាព ការធានាដល់បូរណភាពដែនដី អធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ច នយោបាយសង្គម ប្រកបដោយ

[6] សូមមើល ប្រវត្តិវិទ្យាសម័យអាណាចក្របារាំង-ព្រះរាជាណាចក្រកម្ពុជាទី២ របស់ ស៊ន សំណាង មាស កិរុណា ឃួន វិច្ឆិក និងឌី ខាំបូលី (២០១៧)។
[7] សូមមើល ប្រវត្តិសាស្ត្រខ្មែរ របស់ ដេវិត ឆាណ្ឌល័រ (២០០៨)។

ចីរភាពតាមរយៈនយោបាយឈ្នះ-ឈ្នះ ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងទេពកោសល្យ ដែលមានលក្ខណៈវិទ្យាសាស្ត្រ របស់សម្តេចអគ្គមហាសេនាបតី តេជោហ៊ុនសែន នាយករដ្ឋមន្ត្រី នៃព្រះរាជណាចក្រកម្ពុជា បានបើកទ្វារឱកាសឲ្យរាជរដ្ឋាភិបាលកសាង និងអភិវឌ្ឍជាតិ លើគ្រប់វិស័យ ដូចជា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន កិច្ចការពាណិជ្ជកម្មអន្តរជាតិ យុត្តិធម៌ នយោបាយការបរទេស និងកំណែទម្រង់វិស័យសំខាន់ៗដូចជា វិស័យកងទ័ពក្នុងកិច្ចការការពារ និងកសាងសន្តិសុខជាតិ កំណែទម្រង់អប់រំ កំណែទម្រង់រដ្ឋាបាលសាធារណៈ កំណែទម្រង់វិស័យហិរញ្ញវត្ថុសាធារណៈ និងវិស័យសាធារណៈជាច្រើនទៀត ដែលត្រូវបានចាត់ទុកជាសកម្មភាពក្នុងសេដ្ឋកិច្ចផ្នែកសាធារណៈ ឬត្រូវបាននិយមហៅថា សេដ្ឋកិច្ចសាធារណៈ ដែលត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមករវាងហិរញ្ញវត្ថុសាធារណៈ។ ហិរញ្ញវត្ថុសាធារណៈ ដើរតួនាទីយ៉ាងសំខាន់ និងក្លាយជាកម្លាំងចលករជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធសង្គម កិច្ចការសាធារណៈ កំណើនសេដ្ឋកិច្ច និងតម្លាភាពហិរញ្ញវត្ថុជាដើម[8]។

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅលើកំណែទម្រង់ចំណូល ចំណាយថវិកាជាតិធ្វើយ៉ាងណាឲ្យការគ្រប់គ្រងចំណូល ចំណាយថវិកាជាតិមានស័ក្តិសិទ្ធភាព និងប្រសិទ្ធិភាព ដើម្បីជួយពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រតាមរយៈ ការប្រមូលចំណូលឲ្យបានគ្រប់គ្រាន់ និងឲ្យអស់លទ្ធភាពសម្រាប់ទ្រទ្រង់ចំណាយ ការកាត់បន្ថយបំណុលក្នុងប្រទេស និងបំណុលក្រៅប្រទេស ការបែងចែកធនធានហិរញ្ញវត្ថុឲ្យចំគោលដៅអភិវឌ្ឍន៍ និងសម្រាប់លើកកម្ពស់គុណភាពសេវាសាធារណៈ។ ហើយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ដាក់ឲ្យអនុវត្តនៅខែធ្នូ ឆ្នាំ២០០៤[9] ដោយមានឆន្ទៈនយោបាយមុតស្រួចឥតរាថយ និងមានគោលដៅច្បាស់លាស់ គឺការផ្លាស់ប្តូរប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងវិមជ្ឈការឆ្ពោះទៅរកប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ ពោលគឺសំដៅប្រែក្លាយជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ឲ្យទៅជាប្រព័ន្ធមួយស្របតាមបទដ្ឋាន និងឧត្តមានុវត្តន៍អន្តរជាតិ។

ក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញកំណើនសេដ្ឋកិច្ចឲ្យបានរីកចម្រើនក្នុងរង្វង់ ៧ភាគរយ ក្នុងមួយឆ្នាំនោះ ការរក្សាបានកំណើនសេដ្ឋកិច្ចរឹងមាំបានបង្ហាញឲ្យឃើញ នូវកំណើនចំណូលសរុប សម្រាប់មនុស្សម្នាក់ៗកើនឡើង ដល់១៧០៦ដុល្លារ ក្នុងឆ្នាំ២០១៩ ធៀបនឹង១៥៦៣ដុល្លារ ក្នុងឆ្នាំ២០១៨[10] ។ ការសម្រេចបានសមិទ្ធកម្មសេដ្ឋកិច្ចដ៏ល្អប្រសើរនេះ បានធ្វើឲ្យអត្រានៃភាពក្រីក្ររបស់ប្រជាជនធ្លាក់ចុះប្រមាណពី៥៣.៥ភាគរយ ក្នុងឆ្នាំ២០០៤ ហើយធ្លាក់ចុះមកត្រឹម ១៣.៥ភាគរយ (ធនាគារពិភពលោក ២០១៤) មកក្នុងរង្វង់ក្រោម៩ភាគរយក្នុងឆ្នាំ២០១៩។ ការរីកចម្រើនឥតឈប់ឈរនេះ ដោយសារកម្ពុជាកំពុងឈរលើសុខសន្តិភាព ស្ថិរភាពនយោបាយល្អក្រោមគោលនយោបាយឈ្នះ-ឈ្នះ

[8] សូមមើល សេដ្ឋកិច្ចសម្រាប់វិស័យសាធារណៈរបស់ Joseph E. Stiglitz (2000)។

[9] សូមមើល ទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រ នៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០។

[10] សូមមើល សេចក្តីថ្លែងហេតុអំពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

ដែលបាននឹងកំពុងប្រែក្លាយប្រទេសកម្ពុជា ពីប្រទេសក្រីក្រមកជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងមានទិសដៅប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ហើយក៏មានមហិច្ឆិតាក្លាយទៅជាប្រទេស ដែលមានប្រាក់ចំណូលខ្ពស់ ក្នុងឆ្នាំ២០៥០[11]។

## ២. និយមន័យនៃហិរញ្ញវត្ថុសាធារណៈ

ហិរញ្ញវត្ថុសាធារណៈ សំដៅដល់ប្រាក់កាសរបស់រដ្ឋ ដែលជាសំណុំនៃចំណូល និងចំណាយរបស់រដ្ឋ ឬរដ្ឋអំណាចមូលដ្ឋាន។ ហិរញ្ញវត្ថុសាធារណៈព្យាករណ៍នូវការគ្រោង និងការអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវសំណុំនៃធនធានជាចំណូល និងជាបន្ទុកចំណាយទាំងអស់ របស់រដ្ឋាភិបាលក្នុងក្របខ័ណ្ឌតម្រង់ទិស និងគោលដៅរបស់ប្រទេសជាតិ ក្នុងវិស័យសេដ្ឋកិច្ច សង្គម ហើយគិតគូរដល់ការថែរក្សាជាសារវន្តនូវតុល្យភាពនៃហិរញ្ញវត្ថុ។ ហិរញ្ញវត្ថុសាធារណៈ ត្រូវកំណត់ន័យតាមតួនាទី៣ប្រភេទធំៗគឺ៖ ១. វិភាជន៍ធនធាន ២. បំណែងចែកចំណូល និងស្ថិរកម្មសេដ្ឋកិច្ច និងកំណើន (Auld & Miller, 1984 & Musgrave, 1989)។

ហិរញ្ញវត្ថុសាធារណៈ សំដៅលើសកម្មភាពផ្នែកហិរញ្ញវត្ថុ ដែលត្រូវរៀបចំជាថវិកា ដែលកើតចេញពីចំណូល ចំណាយរបស់ប្រទេសមួយ ឬនៅក្នុងរដ្ឋមួយ និងនៅក្នុងស្ថាប័នសាធារណៈដទៃទៀត ដែលត្រូវបែងចែក ប្រើប្រាស់ ឬគៀរគរចំណូល និងចំណាយឲ្យមានប្រសិទ្ធភាពដើម្បីជានាឲ្យបានសុខុមាលភាពសេដ្ឋកិច្ច សម្រេចបាននូវគោលបំណងសេដ្ឋកិច្ច ដែលត្រូវបែងចែកតាមវិស័យនានានៃរដ្ឋបាលរបស់ប្រទេស។ ហិរញ្ញវត្ថុសាធារណៈ ក៏ជាការសិក្សា និងពិនិត្យមើលតាមគោលការណ៍ ឬជានីតិហិរញ្ញវត្ថុសាធារណៈ ពោលគឺជាសំណុំនៃវិធានដែលអនុវត្តលើចំណូល និងលើបន្ទុកចំណាយរបស់ប្រទេសជាតិ ឬរដ្ឋ និងរបស់ស្ថាប័នសាធារណៈដទៃទៀត។ ចំណូល និងចំណាយ បង្កើតបានជាថវិការបស់ប្រទេសជាតិ ឬរបស់រដ្ឋ ឬរបស់រដ្ឋាភិបាលនៃប្រទេសជាតិមួយ និងរបស់ស្ថាប័នទាំងនោះ ព្រមទាំងបង្កើតជាសកម្មភាពនៃការអនុវត្ត និងសមិទ្ធផលទាំងក្នុងរយៈពេលខ្លី និងវែងផងដែរ[12]។

ហិរញ្ញវត្ថុសាធារណៈ គឺជាសកម្មភាព និងមធ្យោបាយផ្សេងៗ របស់រដ្ឋក្នុងដំណើរការគៀរគរចំណូល និងការទូទាត់ចំណាយរបស់ខ្លួន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពចំណូល និងចំណាយ ហើយចំណាយត្រូវប្រកបដោយវិចារណកម្ម រួមចំណែកដើម្បីឲ្យសេដ្ឋកិច្ចមានការរីកចម្រើន មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ដែលមានផលប៉ះពាល់តិចតួចលើសកម្មភាពសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ សកម្មភាព និងវិធានការនៃហិរញ្ញវត្ថុសាធារណៈ ជាទូទៅផ្តោតទៅលើ

---

[11] សូមមើល យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា (២០១៨) និង ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ របស់រាជរដ្ឋាភិបាលកម្ពុជា (២០១៨) និង សមិទ្ធផល និងទិសដៅ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេល៥ឆ្នាំ ដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៨។

[12] សូមមើល ហង់ ជួនណារ៉ុន និង ប៉ាទ្រីកហ្សីលបែ - ដឺវ៉ាល់ឡុង (២០០៩) និង ខឹមសារិទ្ធ (២០១៨)។

សកម្មភាពរបស់រដ្ឋាភិបាល លើចំណុចសំខាន់ធំៗដូចជា ការធានាប្រសិទ្ធភាពនៃវិភាជន៍ធនធាន ការបែងចែកចំណូលប្រកបដោយសមធម៌ និងការធ្វើឲ្យមានស្ថិរភាពលំនឹងម៉ាក្រូសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាព។

ហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសមួយ អាស្រ័យលើការយកចិត្តទុកដាក់ លើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលើការដាក់ចេញឲ្យអនុវត្តក្នុងគោលបំណងដើម្បីជួយជំរុញឲ្យមានអភិបាលកិច្ចល្អ គណនេយ្យភាព និងតម្លាភាពក្នុងការគ្រប់គ្រងថវិកាជាតិរបស់ប្រទេស ឬរបស់រដ្ឋឲ្យកាន់តែមានភាពប្រសើរឡើង ជាពិសេសការចំណាយថវិកាជាតិ ត្រូវកែលម្អការគ្រប់គ្រង និងគណនេយ្យភាពនៃចំណូល-ចំណាយ ឲ្យមានលក្ខណៈស្តង់ដារក្នុងការប្រើប្រាស់ នូវធនធានរបស់រដ្ឋាភិបាលទាំងថវិកាចរន្ត និងថវិកាមូលធនប្រកបដោយប្រសិទ្ធភាពខ្ពស់។

ហិរញ្ញវត្ថុសាធារណៈ គឺជាមែកធាងមួយនៃសេដ្ឋកិច្ចវិទ្យា ដែលផ្តោតជាពិសេសទៅលើផ្នែកសាធាណៈ និងផ្នែករដ្ឋាភិបាល ដែលជាប់ពាក់ព័ន្ធសារពើពន្ធ ជាប្រភពចំណូលរបស់រដ្ឋាភិបាល នៃប្រទេសជាតិ ឬរដ្ឋមួយ និងជាការធ្វើថវិកាជាតិដែលជាឧបករណ៍ធ្វើផែនការ សម្រាប់ការគៀគរចំណូល និងកំណត់សកម្មភាពចំណាយដើម្បីបំពេញសេចក្តីការលើការងារ កម្មវិធី គោលនយោបាយ និងផ្នែកអភិវឌ្ឍន៍ ជំរុញធ្វើឲ្យសេដ្ឋកិច្ចមានការរីកចម្រើន ប្រជាជនទទួលបានផលប្រយោជន៍ពីការចំណាយរបស់រដ្ឋាភិបាលតាមរយៈ ផលិតផលសាធារណៈ គោលនយោបាយ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយវិចារណកម្ម ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព ប្រសិទ្ធផល គណនេយ្យភាព តម្លាភាព និងភាពអាចជឿជាក់បាន។ តួនាទីរបស់រដ្ឋាភិបាល បានក្លាយជាកម្លាំងចលករប្រកបដោយថាមពល សំដៅដោះស្រាយបញ្ហា គាំពារសុខភាព សុវត្ថិភាព រក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ច បំណែងចំណូលឡើងវិញ ការកាត់បន្ថភាពគម្លាតរវាងអ្នកមាន និងអ្នកក្រ ឬការកាត់បន្ថយភាពក្រីក្រ ការលើកស្ទួយសុខុមាលភាពជីវិភាពប្រជាជន ការត្រួតពិនិត្យ និងដោះស្រាយផលប៉ះពាល់ពីខាងក្រៅជាដើម។

## ៣. រដ្ឋាភិបាល និងកិច្ចអន្តរាគមន៍

ការសិក្សាអំពីហិរញ្ញវត្ថុសាធារណៈ ដូចជាការសិក្សាអំពីមែកធាងពិសេស និងដាច់ដោយឡែកនៃសេដ្ឋកិច្ច ដែលត្រូវបានចង្អុលបង្ហាញដោយកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ដែលកើតមានក្នុងវិស័យសាធារណៈក្នុងប្រទេសមួយ (Auld & Miller, 1984)។ តួយ៉ាងដូចជាក្នុងប្រទេសកម្ពុជាក្នុងរយៈពេលមួយទសវត្សកន្លងមកនេះ កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧ភាគរយក្នុងមួយឆ្នាំចាប់តាំងពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២០) ហើយការសម្រេចបានអត្រាតួលេខកំណើននេះ តាមរយៈការដាក់ចេញអនុវត្តន៍ នូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានអនុម័តជាក្របខ័ណ្ឌរបស់ជាតិ និងជាផ្នែកមួយ នៃ

ក្របខ័ណ្ឌគោលនយោបាយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នាទៅវិញទៅមក សង្កត់ធ្ងន់លើអភិបាលកិច្ចល្អ ដែលត្រូវបានចាត់ថាជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក៏ដូចជាមូលដ្ឋានគ្រឹះ នៃការអនុវត្តផ្សេងៗទៅលើសមតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងវិស័យពាណិជ្ជកម្មថវិកាជាតិ និងអតិផរណា ក៏ដូចជាការជំរុញកំណើន និងការធ្វើពិពិធកម្មជាដើម។

ក្នុងឆ្នាំ២០១៨ កម្ពុជាអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រា៧.៥ភាគរយ ដែលជាកំណើនមួយខ្ពស់បំផុត ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៩)។ កំណើននេះ ត្រូវបានគាំទ្រដោយកំណើនខ្ពស់លើសការរំពឹងទុក នៃអនុវិស័យកាត់ដេរ កំណើនរឹងមាំនៃអនុវិស័យសំណង់ និងអនុវិស័យអចលទ្រព្យ អនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ស្របនឹងកំណើនល្អប្រសើរ នៃអនុវិស័យលក់ដុំ-រាយអនុវិស័យដឹកជញ្ជូន និងគមនាគមន៍ និងអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន។ ទោះបីជាយ៉ាងនេះក្តីសេដ្ឋកិច្ចកម្ពុជា នៅជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធ សំខាន់ៗចំនួន២គឺៈ ភាពប្រកួត ប្រជែងនៅមានកម្រិត និងភាពយឺតយ៉ាវ នៃការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយ ជាច្រើន ដែលផ្តោតលើការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងបង្កើតភាពប្រកួតប្រជែងរួមមាន ការសម្រួលតួនាទី និងភារកិច្ចរបស់ស្ថាប័នឈរជើងនៅច្រកទ្វារអន្តរជាតិ ការលុបស្ថាប័នកាំសាប ការកាត់បន្ថយថ្លៃអគ្គិសនី ការសម្រួលនីតិវិធី និងការបន្ថយថ្លៃសេវាសាធារណៈចាំបាច់មួយចំនួន ការកាត់បន្ថយថ្លៃឡូជីស្ទីក និងដឹកជញ្ជូន ដែលទាំងអស់នេះសំដៅជួយវិស័យឯកជន ក្នុងការកាត់បន្ថយថ្លៃដើម ពេលវេលា និងការបង្កើនភាពងាយស្រួលដល់ការធ្វើអាជីវកម្ម[13]។

យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៧-២០២១) កំណើនសេដ្ឋកិច្ច ឆ្នាំ២០១៩ ត្រូវបានព្យាករណ៍ថា អាចសម្រេចបានក្នុងរង្វង់ ៧.១ភាគរយ ដូចការគ្រោងទុក បើទោះបីជាស្ថានភាពពិភពលោកំពុងជួបប្រទះនូវបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាជាច្រើន ជាពិសេសសភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម អស្ថិរភាពទីផ្សារហិរញ្ញវត្ថុសកលលោក ដែលធ្វើឲ្យសេដ្ឋកិច្ច ប្រទេសចិន សហរដ្ឋអាមេរិក និងបណ្តាប្រទេសដទៃ ក្នុងតំបន់មានកំណើនថមថយ។ ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅតែអាចបន្តរក្សាបានកំណើនរឹងមាំ ទាំងក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ក្នុងអត្រាកំណើនសេដ្ឋកិច្ចនេះ វិស័យឧស្សាហកម្មបានដើរតួយ៉ាងសំខាន់ ជាវិស័យជំរុញកំណើន និងកើនឡើងក្នុងអត្រាប្រមាណ ១១ភាគរយ ដោយសារកំណើនរឹងមាំនៃអនុវិស័យសំណង់ និងអនុវស័យឧស្សាហកម្ម មិនមែនកាត់ដេរ បើទោះបីជាកំណើនអនុវិស័យកាត់ដេរមានការថមថយបន្តិចក៏ដោយ។ ដោយឡែក វិស័យសេវាកម្មនៅតែបន្តកំណើនល្អប្រសើរក្នុងអត្រាប្រមាណ ៦.៧ភាគរយ ដែលគាំទ្រដោយការកើនឡើង នៃអនុវិស័យអចលនទ្រព្យ អនុវិស័យលក់ដុំ-រាយ អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ និងអនុវិស័យសណ្ឋាគារ

[13] សូមមើល សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧, ២០១៨, ២០១៩-២០២១ និង ឆ្នាំ២០២០-២០២២។

និងភោជនីយដ្ឋាន។ ចំពោះវិស័យកសិកម្មនៅតែបន្តកំណើនយឺត ពោលគឺក្នុងអត្រា១ភាគរយ ដោយសារការថមថយកំណើននៃអនុវិស័យដំណាំ បើទោះបីជាអនុវិស័យចិញ្ចឹមសត្វ អនុវិស័យនេសាទអាចរក្សាបានកំណើនប្រហាក់ប្រហែលឆ្នាំ២០១៨ក្តី។ ជាមួយនឹងកំណើនរឹងមាំ ក្នុងឆ្នាំ ២០១៩នេះ ផលិតផលក្នុងស្រុកសរុបថ្លៃបច្ចុប្បន្ន ត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់ ១០៨.២៩៨ប៊ីលានរៀលដែលធ្វើឲ្យផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ អាចនឹងកើនឡើងដល់ ១.៦៧៤ដុល្លារ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២០)។

ដោយឡែក សេដ្ឋកិច្ចនៅក្នុងឆ្នាំ២០២០ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ១.៩ ភាគរយ ដែលការថមថយកំណើននេះ បណ្តាលមកពីផលប៉ះពាល់នៃលទ្ធភាពក្នុងការដក EBA ដែលអាចនឹងដាក់សម្ពាធដល់ការនាំចេញរបស់កម្ពុជា ជាពិសេសលើផលិតផលកាត់ដេរទៅកាន់ទីផ្សារអឺរ៉ុប និងដោយសារការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ-១៩។ ទោះបីជាយ៉ាងនេះក្តី កំណើនសេដ្ឋកិច្ចកម្ពុជាអាចត្រូវព្យាករណ៍ថានឹងងើបឡើងវិញក្នុងឆ្នាំ២០២១ ក្នុងអត្រាកំណើន៣.៥ភាគរយ ដោយសារការរំពឹកទុកនៃការងើបឡើងវិញយឺតនៃសកម្មភាពសេដ្ឋកិច្ច ការកើនឡើងក្នុងកម្រិតទាបនៃតម្រូវការខាងក្រៅ ទំនុកចិត្តទីផ្សារក្នុងស្រុក ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ដែលបានរងឥទ្ធិពលដោយសារជំងឺកូវីដ-១៩ និងការទទួលបានការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២០ និង២០២១)។ កំណើននេះ ត្រូវបានគាំទ្រដោយវិស័យកសិកម្មប្រមាណ ១.៦ ភាគរយ និងការងើបឡើងវិញ នៃវិស័យឧស្សាហកម្ម ដែលអាចសម្រេចបានកំណើនក្នុងអត្រា ៤.១ ភាគរយ ព្រមទាំងការកើនឡើងវិញ នៃវិស័យសេវាកម្មក្នុងអត្រាកំណើនទាបប្រមាណ ៣.៦ភាគរយ ក្នុងវិស័យទេសចរណ៍ និងការប្រើប្រាស់ក្នុងស្រុកបន្ទាប់ពីវិបត្តិកូវីដ-១៩ និងការត្រលប់មកប្រក្រតីភាពនៃសកម្មភាពសេដ្ឋកិច្ចដែលពាក់ព័ន្ធ[14]។

លើសពីនេះ កម្ពុជារក្សាបាននូវអតិផរណាដែលស្ថិតក្នុងកម្រិតទាបអាចគ្រប់គ្រងបានក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ២.៣ភាគរយ ក្នុងឆ្នាំ២០២០ និងឆ្នាំ២០១៩ ដែលថមថយពី ២.៥ភាគរយ ក្នុងឆ្នាំ២០១៨ ដោយសារការធ្លាក់ចុះនៃថ្លៃដឹកជញ្ជូន ស្របនឹងការធ្លាក់ចុះថ្លៃប្រេងលើទីផ្សារអន្តរជាតិ នឹងអាចត្រូវបានព្យាករណ៍កើនឡើង ក្នុងកម្រិតអាចគ្រប់គ្រងបាន ក្នុងអត្រា២.៨ភាគរយ ក្នុងឆ្នាំ២០២០ ដោយសារការរំពឹងទុកកើនឡើងនៃតម្រូវការម្ហូបអាហារ ផលិតផលផ្សេងៗទៀតនៅលើទីផ្សារ ហើយអត្រាអតិផរណាក្នុងឆ្នាំ២០២១ អាចត្រូវបានព្យាករណ៍ស្ថិតក្នុងអត្រា៣.១ភាគរយ ដោយសារការកើនឡើងបន្តិចមកវិញនូវថ្លៃប្រេងអន្តរជាតិ។ ជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់នៅតែបន្តមានស្ថិរភាពក្នុងតម្លៃប្រមាណ ៤.០៥៤រៀល ក្នុង១ដុល្លារនៅក្នុងឆ្នាំ២០១៩ ហើយត្រូវបានរំពឹងថានឹងកើនឡើងក្នុងរង្វង់៤.១០០រៀល ក្នុង១ដុល្លារ ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ដោយសារជំនឿទុកចិត្តពីសំណាក់សាធារណជន លើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់

[14] សូមមើល សាររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីវិធានការរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងផលប៉ះពាល់ពីជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (ខូវីដ-១៩) និងការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួន ឆ្នាំ២០២០។

ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២១)។

ឱនភាពគណនីចរន្តត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ទំហំ ១៧.៦ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២០ ហើយទំហំនេះត្រូវបានព្យាករណ៍ថានឹងរួមតូចបន្តិចមកត្រឹម១៧.៣ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២១ ដោយសារការរំពឹងទុក នៃការងើបឡើងវិញបន្តិចនូវការនាំចេញ និងវិស័យទេសចរណ៍។ ទុនបម្រុងអន្តរជាតិសរុបក្នុងឆ្នាំ២០២០ ត្រូវបានរំពឹងថានឹងថយចុះមកត្រឹម១៦.៩៣៧លានដុល្លារ ដោយសារការរីកធំនៃឱនភាពគណនីចរន្ត រួមផ្សំនឹងការរំពឹងទុកការធ្លាក់ចុះ នៃលំហូរទុនវិនិយោគពីបរទេស។ ក្នុងឆ្នាំ២០២១ ទុនបំរុងអន្តរជាតិសរុបត្រូវបានព្យាករណ៍ថានឹងកើនឡើង១៦.៩៨១លានដុល្លារ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២១)។

ទំហំនៃវិស័យសាធារណៈទាក់ទងនឹងការបង់ពន្ធ ការប្រមូលពន្ធ ការចំណាយ ការខ្ចីប្រាក់ និងផលប៉ះពាល់នានា ដែលវិធានការថវិកាទាំងនេះកើតមានទៅលើសេដ្ឋកិច្ច ធ្វើឲ្យការសិក្សាហិរញ្ញវត្ថុសាធារណៈជាកម្រិតមូលដ្ឋានគ្រឹះ អាចក្លាយទៅជាការសិក្សាកម្រិតមធ្យម និងកម្រិតខ្ពស់ ដែលអាចធ្វើឲ្យការយល់ដឹងកាន់តែជ្រៅទៅៗ ចំពោះការងារ និងសកម្មភាពរបស់សេដ្ឋកិច្ច ដែលពឹងផ្អែកលើទីផ្សារ។ រដ្ឋាភិបាលក៏មានឥទ្ធិពលលើដំណើរការ នៃសកម្មភាពសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់រូបិយវត្ថុ ពាណិជ្ជកម្ម ពន្ធគយ ការប្រកួតប្រជែង និងប្រភេទគោលនយោបាយសាធារណៈជាច្រើនផ្សេងទៀត។ ការសិក្សាអំពីគោលនយោបាយទាំងនេះ គឺហាក់បីដូចជាស្ថិតនៅក្រៅវិសាលភាព នៃការសិក្សាហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែនៅតែត្រូវបានលើកយកមកសិក្សា ពិភាក្សា ដោះស្រាយ និងមិនអាចត្រូវបានបដិសេធឡើយ នៅពេលដែលគោលនយោបាយណាមួយរបស់រដ្ឋាភិបាលត្រូវបានវាយតម្លៃ និងដាក់ចេញឲ្យអនុវត្ត ដែលអាចប្រែក្លាយទៅជា ឬអាចមានឥទ្ធិពលដោយផ្ទាល់ ឬប្រយោលទៅលើសេដ្ឋកិច្ច។ អាស្រ័យលើការរៀបចំ និងការអនុវត្តនៃប្រព័ន្ធសេដ្ឋកិច្ចនៅក្នុងប្រទេសនីមួយៗ វិស័យសាធារណៈដើរតួនាទីសំខាន់ខុសៗគ្នា។ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសង្គមនិយមសុទ្ធសាធ ធនធានដែលជាកត្តាផលិតកម្មត្រូវបានកាន់កាប់ និងគ្រប់គ្រងដោយរដ្ឋ។ ដូចនេះហិរញ្ញវត្ថុសាធារណៈគឺជាការសិក្សាអំពីសេដ្ឋកិច្ចនេះឯង។ ទោះបីជាយ៉ាងណា នៅក្នុងសេដ្ឋកិច្ចទីផ្សារ តួនាទីរបស់រដ្ឋាភិបាលត្រូវបានកម្រិត ឬមានកំណត់ហើយតួនាទីដែលមានកម្រិតនោះនៅតែដើរតួនាទីនៅមានកម្រិតនៅឡើយ។

ជាឧទាហរណ៍ ប្រទេសកម្ពុជាបានអនុវត្តប្រព័ន្ធសេដ្ឋកិច្ចបែបទីផ្សារសេរី ចាប់តាំងពីឆ្នាំ១៩៩៣មកម្លេះ ហើយសកម្មភាពផលិតកម្ម សកម្មភាពសេដ្ឋកិច្ចភាគច្រើនត្រូវបានអនុវត្តដោយបុគ្គល ក្រុមហ៊ុន សហគ្រាសអាជីវកម្មឯកជនជាជាងរបស់រដ្ឋាភិបាល។ នៅក្នុងឆ្នាំ២០១១ វិស័យឯកជនបានក្តោបក្តាប់ សេដ្ឋកិច្ចមានចំនួនលើលលប់ប្រមាណជាង ៩១ភាគរយ ដែលភាគច្រើនជាសហគ្រាសធុន

តូច-មធ្យម ហើយសហគ្រាសទំនើបធំៗគឺមាននៅតាមទីក្រុងប្រជុំជនតែប៉ុណ្ណោះ[15] ។ កសិកម្មក្រៅប្រព័ន្ធមានទំហំតូច ដែលគាំទ្រការរួមចំណែកដល់សេដ្ឋកិច្ចជាតិ និងកំណើនយ៉ាងឆាប់រហ័ស។ ទោះបីតួនាទីរបស់រដ្ឋាភិបាលក្នុងសេដ្ឋកិច្ចទីផ្សារសេរីត្រូវបានកម្រិត ឬមានកំណត់នោះក៏ដោយ ក៏តួនាទីនេះកាន់តែដើរតួនាទីយ៉ាងសំខាន់ ហើយត្រូវបានកត់សម្គាល់ឃើញថា មានការកើនឡើងយ៉ាងខ្លាំងនូវកិច្ចអន្តរាគមន៍ការងារសេដ្ឋកិច្ចសាធារណៈ និងប្រសិទ្ធភាពទីផ្សារជាដើម ក្នុងរយៈពេលប្រមាណ២០ឆ្នាំចុងក្រោយនេះ។ ទាំងនេះធ្វើឲ្យមានសំណួរគួរឲ្យចាប់អារម្មណ៍ជាច្រើន ថាហេតុអ្វីបានជាបញ្ហានេះត្រូវកើតឡើង?

ដោយនិយាយសង្ខេបខ្លី តើវិស័យឯកជនបានរួមចំណែកស្មើប៉ុន្មានភាគរយ នៃប្រាក់ចំណូលជាតិ និងសេដ្ឋកិច្ចជាតិបច្ចុប្បន្ន? បើនិយាយឲ្យចំទៅ ចម្លើយដ៏សាមញ្ញគឺថា ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសុទ្ធសាធនឹងមិនផ្តល់ការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព និងអាចធ្វើឲ្យមានបរាជ័យទីផ្សារនៃការប្រើប្រាស់ធនធានកើតមានឡើង នៅពេលអវត្តមានតួនាទី និងកិច្ចអន្តរាគមន៍តាមរយៈយន្តការនិងគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីធ្វើអន្តរាគមន៍លើទីផ្សារឲ្យមានលទ្ធផលប្រសើរ ឬមានប្រសិទ្ធភាពទីផ្សារ។ ដូចនេះតួនាទីរបស់រដ្ឋាភិបាលក្លាយជាយន្តការ វិធានការ ដំណោះស្រាយ និងការកែសម្រួល ដើម្បីធ្វើឲ្យការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងកែតម្រូវបរាជ័យទីផ្សារ ដែលតួនាទីនេះតម្រូវការចាំបាច់ និងសំខាន់ក្នុងសេដ្ឋកិច្ច សេដ្ឋកិច្ចសាធារណៈ គោលនយោបាយសាធារណៈ និងហិរញ្ញវត្ថុសាធាណៈជាដើម។ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុ ក៏ដូចជាគោលនយោបាយសេដ្ឋកិច្ច ដែលត្រូវកំណត់ផងដែរ អំពីលទ្ធភាពនៃការបែងចែកធនធាន ការប្រើប្រាស់ធនធាន និងការប្រើប្រាស់ជាអាទិភាពណាមួយ នៃគោលនយោបាយចម្បងផ្សេងៗ ក្នុងគោលបំណងសម្រេចគោលដៅរួម របស់រដ្ឋាភិបាលប្រទេសមួយ និងការធានាសុខុមាលភាពសេដ្ឋកិច្ច។

ដូចនេះដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចគោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានសារៈសំខាន់ណាស់ ហើយមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា គម្រោងថវិកា ការបែងចែកថវិកា និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។ ដើម្បីសម្រេចបានតាមគោលដៅក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់គោលដៅវាស់វែងជាសូចនាករហិរញ្ញវត្ថុសាធារណៈ ដោយបន្តធានាកំណើនចំណូលចរន្តប្រចាំឆ្នាំបន្ថែម០.៥ពិន្ទុភាគរយនៃផលិតផលក្នុងស្រុកសរុប បន្តពង្រឹង សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ បន្តធានាការអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងការបែងចែកផ្លែផ្កាជាផលប្រយោជន៍ នៃកំណើនប្រកបដោយសមធម៌ ដល់គ្រប់ស្រទាបវណ្ណៈ នៃប្រជាជន បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ ដើម្បីសម្រេចឲ្យបាន

[15] សូមមើល គោលនយោបាយអភិវឌ្ឍវិស័ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ របស់រាជរដ្ឋាភិបាល(២០១៥) និងធនាគារអភិវឌ្ឍន៍អាស៊ី (២០២៤) ស្តីពីយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស (២០១៤-២០១៨)។

នូវកំណើន សេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងចីរភាពក្នុងបរិការណ៍ នៃភាពមិនច្បាស់លាស់ និងហានិភ័យ ព្រមទាំងធានាបាននូវអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន និងស្ថិរភាពអត្រាប្តូរប្រាក់។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បន្តគាំទ្រអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រងគ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយជាដើម ហើយរាជរដ្ឋាភិបាល ក៏បន្តគិតគូរលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល ក្នុងកម្រិតសមស្រប ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចក្នុងគោលដៅធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈ។ ជាងនេះទៀត ការបន្តអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាព សំដៅធានាបាននូវចីរភាពបំណុលត្រូវបានយកចិត្តទុកដាក់។ មិនត្រឹមតែប៉ុណ្ណោះ ការជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈ ការលើកកម្ពស់អប់រំ និងការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គម ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឲ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ ការជំរុញនិងពន្លឿនការអនុវត្តឲ្យខ្លាំងក្លា នូវការអភិវឌ្ឍវិស័យឧស្សាហកម្ម ការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការបង្កើនវិនិយោគសាធារណៈលើការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន វិស័យថាមពល ការតភ្ជាប់វិស័យឌីជីថល ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ ការបន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព ពិពិធកម្ម ការកែច្នៃកសិផលគោលដៅ និងរចនាសម្ព័ន្ធទេសចរណ៍ និងពាណិជ្ជូបនីយកម្មថែមទៀត។ រាជរដ្ឋាភិបាលក៏បានដាក់ឲ្យអនុវត្តក្របខ័ណ្ឌចំណាយអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់ និងហានិភ័យមកលើសេដ្ឋកិច្ចកម្ពុជា ដូចជាការបន្តរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ តាមរយៈការជំរុញការនាំចេញឲ្យអស់សក្តានុពល និងងាកពីការពឹងផ្អែកទាំងស្រុងលើតម្រូវការខាងក្រៅ មកពឹងផ្អែកមួយចំនួនលើតម្រូវការក្នុងស្រុក ការជំរុញការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមជាដើម។

យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំណូលថវិកា ក្នុងប្រទេសកម្ពុជាត្រូវបានរំពឹងថា នឹងកើនដល់២៤.០៦៣ប៊ីលានរៀល នៅឆ្នាំ២០២០ មានកំណើន២១.៨ភាគរយ ធៀបនឹងឆ្នាំ២០១៩ ឬស្មើនឹង២០.២ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ កំណើននេះ ត្រូវបានជំរុញដោយកំណើនលើចំណូលពន្ធប្រយោល ជាពិសេសអាករលើតម្លៃបន្ថែម និងអាករពិសេស។ ពន្ធប្រយោលត្រូវបានរំពឹងថា នឹងកើនឡើងប្រមាណ២៤.៩ភាគរយ ដែលលើសពីកំណើនមធ្យមប្រមាណ ១៥.១ភាគរយ ពីឆ្នាំ២០១៦ ដល់២០១៩។ ពន្ធប្រយោលនេះ គឺជាប្រភពចំណូលចម្បង និងត្រូវបានរំពឹងថានឹងមានចំនួន៣៥ភាគរយនៃប្រាក់ចំណូលពន្ធសរុប ឬស្មើ ៦.២ នៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ២០២០។ អាករពិសេសត្រូវបានរំពឹងថានឹងកើនឡើងដល់៣៨.៦ភាគរយលើសពីកំណើនជាមធ្យម ដែលមានតែ១៩ភាគរយ។ ចំណូលអាករពិសេសមានចំនួន២៧.២ភាគរយនៃចំណូលពន្ធសរុប ឬស្មើ៤.៨ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ពន្ធលើប្រាក់ចំណូលត្រូវបានរំពឹងថានឹងកើនឡើង១៧.៣ភាគរយ ក្នុង

ឆ្នាំ២០២០ខ្ពស់ជាងកំណើនជាមធ្យម១៥.៨ភាគរយ ពីឆ្នាំ២០១៦ ដល់២០១៩។ ពន្ធលើពាណិជ្ជកម្មក្រៅប្រទេសត្រូវបានរំពឹងថា នឹងកើនឡើង១៤.៩ភាគរយធៀបទៅនឹងថវិកាឆ្នាំ២០១៩ ដោយមានកំណើនជាមធ្យមប្រមាណ ៧.០ភាគរយ ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩។

ចំណាយថវិកាសរុបត្រូវបានរំពឹងថានឹងកើនឡើងដល់ ៣១.០៩៦ប៊ីលានរៀល កើនឡើង ២១ភាគរយ ធៀបនឹងឆ្នាំ២០១៩ ដែលស្មើនឹង ២៦ភាគរយ នៃផលិតផលក្នុងស្រុកសរុប នៅឆ្នាំ២០២០។ ចំណាយមូលធនត្រូវបានរំពឹងថានឹងកើនឡើងដល់ ១៣.០៥៩ប៊ីលានរៀល និងមានកំណើនគួរឲ្យកត់សម្គាល់ប្រមាណ ៤៦ភាគរយធៀបនឹងឆ្នាំ២០១៩ ដែលស្មើនឹង ១១ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ការកើនឡើងនេះ គឺដោយសារតែកំណើនយ៉ាងឆាប់រហ័ស នៃចំណាយការវិនិយោគសាធារណៈមិនទាន់បែងចែក ដែលត្រូវបានរំពឹងទុកថា នឹងមានចំនួន៣.៨៨៦ប៊ីលានរៀលក្នុងឆ្នាំ២០២០ធៀបទៅនឹង ៦៣៦លានរៀននៅក្នុងឆ្នាំ២០១៩។ ចំណាយថវិកាចរន្តសរុបត្រូវបានគ្រោងចំនួន១៨.០៣៧ប៊ីលានរៀលក្នុងឆ្នាំ២០២០ កើនឡើង៧ភាគរយ ធៀបនឹងឆ្នាំ២០១៩ ដែលស្មើនឹង១៥ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ ចំណាយបន្ទុកបុគ្គលិកសរុបត្រូវបានរំពឹងថានឹងកើនឡើងដល់៩ភាគរយ បើធៀបទៅនឹងឆ្នាំ២០១៩ ដែលស្មើនឹង៤៧ភាគរយនៃចំណាយចរន្តសរុប ឬស្មើ៧ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ស្រដៀងគ្នានេះដែរ ការចំណាយមិនមែនបុគ្គលិកសរុបត្រូវបានគ្រោងបង្កើនប្រមាណ៦ភាគរយ ដែលស្មើនឹង៨ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០២០[16]។

## ៣.១. មុខងារនៃវិភាជន៍ធនធាន

ការចាប់ផ្តើមដំបូងជាមួយនឹងមុខងារវិភាជន៍ធនធាន ការស្នើសុំ និងការប្រើប្រាស់ដែលសំដៅទៅលើទំនិញមួយចំនួន ឬអាចនិយាយបានថាជាទំនិញសាធារណៈ ឬជាទំនិញសង្គមនៅទីនេះ ដែលខុសគ្នាពីទំនិញឯកជន ដែលមិនត្រូវបានផលិត និងផ្គត់ផ្គង់ក្នុងទីផ្សារប្រកួតប្រជែង ឬមិនត្រូវបានផ្តល់ជូនតាមរយៈប្រព័ន្ធទីផ្សារ ពោលគឺតាមរយៈប្រតិបត្តិការរវាងអ្នកប្រើប្រាស់ និងអ្នកផលិត ឬអ្នកផ្គត់ផ្គង់ដែលមានន័យថាទំនិញនោះ មិនត្រូវបានផលិត ផ្គង់ផ្គង់ ឬផ្តល់ជូនដោយឯកជនតាមរយៈប្រព័ន្ធទីផ្សារនោះទេ ឬអាចនិយាយបានថា ទំនិញសាធារណៈ ជាទំនិញដែលត្រូវបានផលិត ផ្គត់ផ្គត់ ឬផ្តល់ជូនដោយរដ្ឋាភិបាលសំដៅដល់អត្ថប្រយោជន៍សង្គម និងប្រជាជនដោយមិនគិតថ្លៃក្នុងការប្រើប្រាស់ ឬដោយមិនយកកម្រៃពីសាធារណជន។ ខណៈពេលខ្លះស្ថានភាពសេដ្ឋកិច្ចក្នុងសេដ្ឋកិច្ចទីផ្សារ ឬក្នុងករណីខ្លះទីផ្សារអាចកើតមានបរាជ័យទាំងស្រុង ដែលបណ្តាលមកពីគ្មានប្រសិទ្ធភាពក្នុងការវិភាជន៍ និងការប្រើប្រាស់ធនធាន។ ហេតុអ្វីបានមានករណីនេះកើតឡើងយ៉ាងដូច្នេះ? មូលហេតុគ្រឹះចំពោះបរាជ័យទីផ្សារ ក្នុងការផលិត ផ្គត់ផ្គង់ ឬផ្តល់ជូនទំនិញសាធារណៈមិនមែនបណ្តាលមកពីតម្រូវការ

[16] សូមមើល សង្ខេបស្តីពីថវិកាជាតិឆ្នាំ ២០២០ របស់វិទ្យាស្ថានសភាកម្ពុជា ឆ្នាំ ២០១៩ និងរបស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ឆ្នាំ ២០១៩-២០២១។

ចំពោះទំនិញសាធារណៈ ដែលជាទំនិញសមូហៈប្រើប្រាស់ដោយសាធារណជននោះទេ។ រីឯទំនិញឯកជន គឺជាទំនិញដែលផលិត ផ្គត់ផ្គង ឬផ្តល់ជូនដោយបុគ្គលឯកជន ឬសហគ្រាសឯកជន ដើម្បីប្រាក់ចំណេញអតិបរមា ឬអាចនិយាយថាជាទំនិញដែលផ្តល់ដោយទីផ្សារ ហើយមានការប្រគួតប្រជែងក្នុងការប្រើប្រាស់ក្នុងទីផ្សារ។

ជាទូទៅនៅក្នុងសេដ្ឋកិច្ច ចំណូលចិត្តរបស់ប្រជាជន អាចត្រូវរងឥទ្ធិពលដោយបរិយាកាសសង្គម ឬកត្តាកំណត់ផ្សេងៗ។ ចំណូលចិត្ត និងការទៅកំសាន្តនៅឯរមណីដ្ឋានត្រូវឆ្លងកាត់ជាបទពិសោធន៍ដោយបុគ្គលម្នាក់ៗ ហើយមិនមែនដោយសង្គមទាំងមូលនោះទេ។ លើសពីនេះ ទាំងទំនិញសាធារណៈ និងទំនិញឯកជន ក៏ត្រូវបានវាស់វែង និងមានបង្ហាញក្នុងផែនទីចំណូលចិត្តដែរ។ ដូចនេះ សំវិធានធន ឬការផ្តល់ជូនទំនិញសាធារណៈ ឬដំណើរការ ដែលធនធានសរុបត្រូវបានប្រើប្រាស់ ឬត្រូវបានបែងចែករវាងទំនិញសាធារណៈ និងទំនិញឯកជនមានចរិតលក្ខណៈខុសគ្នា។ ការផ្តល់ជូនទំនិញសាធារណៈនេះ គឺជាអ្វីដែលត្រូវបានគេស្គាល់ថា ជាមុខងារនៃវិភាជន៍ធនធាន។ ហើយបរាជ័យទីផ្សារក្នុងការផលិត ផ្គត់ផ្គង់ ឬផ្តល់ជូនទំនិញសាធារណៈ អាចកើតមានឡើងដោយសារវត្តមានទំនិញសាធារណៈ ឬអាចកើតចេញពីកត្តាផ្សេងៗជាច្រើនក្នុងទីផ្សារ។ យន្តការទីផ្សារ គឺសមស្របសម្រាប់ការផ្គត់ផ្គង់ ឬផ្តល់ជូនទំនិញឯកជន។ វាផ្អែកលើការដោះដូរ ហើយការដោះដូរអាចកើតឡើងបានតែក្នុងករណីមានសិទ្ធិផ្តាច់មុខ ឬសិទ្ធឯកាធិភាព និងមានការប្រគួតប្រជែងមិនសុក្រឹតកើតឡើងចំពោះទំនិញដែលត្រូវគេដោះដូរជាដើម (Musgrave, 1989)។

ការអនុវត្តគោលការណ៍ នៃការផ្តាច់មុខ ឬឯកាធិភាព ទំនងជាដំណោះស្រាយដែលមិនមានប្រសិទ្ធភាពក្នុងទីផ្សារ។ នេះមិនមែនក្នុងករណីទំនិញសាធារណៈនោះទេ ព្រោះវាមិនមានប្រសិទ្ធិភាពនៅពេលដែលមិនអនុញ្ញាតឲ្យអ្នកប្រើប្រាស់ណាម្នាក់ ចូលរួមទទួលបានអត្ថប្រយោជន៍ នៅពេលដែលការចូលរួមនឹងមិនត្រូវកាត់បន្ថយការប្រើប្រាស់នោះ។ ឧទាហរណ៍ អ្នកអាចប្រើប្រាស់ ផ្លូវសាធារណៈដើរឆ្លងកាត់ស្ពានសាធារណៈ ឬអង្គុយលេងក្នុងសួនសាធារណៈច្រើនតាមដែលអ្នកអាច ប៉ុន្តែមិនមែនមានន័យថាធ្វើឲ្យមានកាត់បន្ថយលទ្ធភាព នៃការប្រើប្រាស់របស់អ្នកដទៃនោះឡើយ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីដែលទទួលបានអត្ថប្រយោជន៍ ចំពោះអ្នកប្រើប្រាស់ទាំងអស់ នឹងមិនផ្តល់ការបង់ប្រាក់ដោយស្ម័គ្រចិត្តដល់អ្នកផ្គត់ផ្គង់ទំនិញសាធារណៈឡើយ។ ហេតុដូច្នេះ គឺមិនមានការចំណាយ ឬការបង់ប្រាក់ដោយស្ម័គ្រចិត្តណាមួយ ត្រូវបានធ្វើឡើងចំពោះទំនិញសាធារណៈនោះទេ ជាពិសេសអ្នកប្រើប្រាស់ដែលបានប្រើប្រាស់ច្រើននោះ។ ការផ្សារភ្ជាប់គ្នារវាងអ្នកផលិត ឬអ្នកផ្គត់ផ្គង និងអ្នកប្រើប្រាស់ត្រូវបានបំបែក ឬកាត់ផ្តាច់ ដូចនេះរដ្ឋាភិបាលត្រូវតែឈានជើងរួមចំណែក និងចូលរួមតភ្ជាប់ ឬផ្សារភ្ជាប់ ដើម្បីផលិត ផ្គត់ផ្គង់ និងផ្តល់ជូនទំនិញបែបនេះ។

## ៣.២. មុខងារនៃចំណែងចែកចំណូល

បើគ្មានការធ្វើកិច្ចអន្តរាគមន៍ពីរដ្ឋាភិបាល តើការបែងចែកប្រាក់ចំណូលនឹងត្រូវពឹងផ្អែកទៅលើអ្នកណា? ហើយជាទូទៅការបែងចែកចំណូល ដែលមិនមានការធ្វើកិច្ចអន្តរាគមន៍ពីរដ្ឋាភិបាលអាចកើតមានតាមរយៈម្ចាស់នៃកត្តាផលិតកម្ម និងថ្លៃ និងសហគ្រាសនៅក្នុងទីផ្សារដែលត្រូវបានតម្រូវ។ គ្មានអ្វីដែលត្រូវនិយាយទេថា ទោះបីជាការបែងចែកនេះ ត្រូវបានកំណត់ដោយការប្រកួតប្រជែងដ៏សុក្រឹតនៅក្នុងទីផ្សារផលិតផល និងទីផ្សារកត្តាផលិតកម្មយ៉ាងណាក៏ដោយ នោះគឺជាការបែងចែកដែលប៉ងប្រាថ្នាដោយសង្គម។ រដ្ឋាភិបាលត្រូវតែព្យាយាមកំណត់ និងស្ទាបស្ទង់មតិរបស់ប្រជាជនថាតើគួរតែត្រូវមានការផ្តល់ជាជំនួយបន្ថែមដល់ក្រុមប្រជាជនដែលមានប្រាក់ចំណូលទាប ឬយ៉ាងណា ហើយប្រសិនបើធ្វើយ៉ាងដូច្នេះមែន ថាតើនរណាជាអ្នកដែលគួរតែត្រូវបានយកពន្ធខ្ពស់? ដោយសារការបែងចែកចំណូលនេះអាចស្ថិតក្នុងស្ថានភាព ដែលមានភាពមិនស្មើគ្នានៃការបែងចែកប្រាក់ចំណូល តើត្រូវដោះស្រាយដោយរបៀបណា? ហើយត្រូវធ្វើឡើងយ៉ាងដូចម្តេច ដើម្បីឲ្យការបែងចែងមានសមធម៌? ប្រទេសមួយអាចសម្រេចចិត្ត ថាតើការបែងចែកប្រាក់ចំណូលដែលប៉ងប្រាថ្នាដោយសង្គមនោះគឺជាកត្តាមួយដែលកំណត់ដោយកម្លាំងទីផ្សារនៃសេដ្ឋកិច្ច ដែលមានការប្រកួតប្រជែងខ្ពស់ ដែលតំរែតម្រង់រដ្ឋាភិបាលឲ្យកាន់តែផ្តោតលើគោលនយោបាយឆ្ពោះទៅរកការកាត់បន្ថយ អំណាចផ្តាច់មុខឬឯកាធិភាពនៅក្នុងទីផ្សារផលិតផល និងទីផ្សារកត្តាផលិតកម្ម ការកាត់បន្ថយភាពមិនប្រក្រតីលើទីផ្សារដូចជាការខុបខិត ថ្លៃរើសអើង ការបង្ខូចថ្លៃ និងការកើតមានអំពើពុករលួយជាដើម។ ប៉ុន្តែសេដ្ឋកិច្ចទីផ្សារភាគច្រើន ក៏បានអនុវត្តគោលនយោបាយនេះ ដោយរដ្ឋាភិបាល ដើម្បីបែងចែកប្រាក់ចំណូលរវាងអ្នកដែលមានប្រាក់ចំណូលខ្ពស់ទៅកាន់អ្នកដែលមានមិនមានចំណូលខ្ពស់។ វិធីសាស្ត្រទូទៅដែលត្រូវបានប្រើដើម្បីសម្រេចបាននូវគោលបំណងនេះ គឺការកំណត់ការយកពន្ធ និងអត្រាពន្ធលើប្រាក់ចំណូលដែលទទួលបាន ហើយបែងចែកទៅវិញជាមួយនឹងការផ្តល់ប្រាក់ចំណាយ ឬការផ្ទេរទៅគ្រួសារដែលមានប្រាក់ចំណូលទាប ឬផ្តល់ប្រាក់ឧបត្ថម្ភ ដែលអាចមានដូចជាសេវាគេហដ្ឋាន ការផ្តល់ជាសាច់ប្រាក់ប្រចាំខែ និងជាទំនិញ សំភារះ និងម្ហូបអាហារជាដើម។

ការបែងចែង ការឧបត្ថម្ភ និងការផ្ទេរប្រាក់តាមរយៈប្រព័ន្ធជំនួយសង្គម របស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរស់នៅ របស់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ការពង្រឹងសមត្ថភាពចំណូល និងចំណាយរបស់ប្រជាជនឲ្យរក្សាបាននូវស្ថិរភាពប្រាក់ចំណូល និងចំណាយក្នុងស្ថានភាពសេដ្ឋកិច្ច ដែលមានការប្រកួតប្រជែងខ្លាំង។ កម្មវិធីនានាក្នុងប្រព័ន្ធជំនួយសង្គម គាំទ្រដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ជាអាទិភាពរបស់កម្ពុជា ដែលរួមមាន៖ កំណើនប្រកបដោយបរិយាប័ន្ន ការកាត់បន្ថយភាពក្រីក្រ និងពិពិធកម្មសេដ្ឋកិច្ច។ វត្តមានរបស់ប្រព័ន្ធជំនួយសង្គមរួមចំណែក ក្នុងការជំរុញកំណើនផលិតភាពក្នុងសេដ្ឋកិច្ចតាមរយៈការផ្លាស់ប្តូរជីវភាព របស់ប្រជាជនក្រីក្រ និងងាយរងគ្រោះទៅជាប្រជាជនដែលមានចំណូលសមរម្យ ពោលគឺការបង្វែរក្រុមប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធ។ កត្តានេះក៏ផ្តល់ផលវិជ្ជមានផងដែរ ដល់ស្ថិរភាពនៃថវិកា

ជាតិ និងការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមតាមរយៈលទ្ធភាពនៃការបង់ពន្ធជូនរដ្ឋ និងលទ្ធភាពក្នុងការបង់ភាគទានចូលក្នុងមូលនិធិសន្តិសុខសង្គម។ នៅក្នុងអំឡុងពេលជាងពីរទសវត្សរ៍កន្លងទៅ ប្រទេសកម្ពុជាមានការផ្លាស់ប្តូររីកចម្រើនគួរឲ្យកត់សម្គាល់ ដោយឈានទៅទទួលបានឋានៈជាប្រទេសមានចំណូលមធ្យមទាបក្នុងឆ្នាំ២០១៥ ហើយមានបំណងប្រាថ្នាថានឹងសម្រេចឲ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមខ្ពស់ត្រឹមឆ្នាំ២០៣០។ ភាពក្រីក្រនៅប្រទេសកម្ពុជាបន្តធ្លាក់ចុះ ពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលនយោបាយអាទិភាពដើម្បីជំរុញលើកកម្ពស់ និងពង្រីកពង្រឹកជីវភាព និងចំណូលរបស់ប្រជាជាឲ្យមានលក្ខណៈប្រសើរ។ អត្រាភាពក្រីក្រនៅកម្ពុជា បន្តធ្លាក់ចុះជាលំដាប់ពី ៥៣ភាគរយ ក្នុងឆ្នាំ២០០៤ មកត្រឹម៤៧.៨ភាគរយ ក្នុងឆ្នាំ២០០៧ និងបន្តធ្លាក់ចុះមកត្រឹម១៣.៥ភាគរយ ក្នុងឆ្នាំ២០១៤ និងត្រូវបានប៉ាន់ស្មានថា ស្ថិតនៅក្នុងរង្វង់១០ភាគរយ ក្នុងឆ្នាំ២០១៩ (ធនាគារពិភពលោក ២០១៩)។ ជិត៩០ភាគរយ នៃជនក្រក្រីរស់នៅតាមទីជនបទ។ ទោះបីជាប្រទេសកម្ពុជាសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដោយកាត់បន្ថយភាពក្រីក្របានពាក់កណ្តាលនៅក្នុងឆ្នាំ២០០៩ ក៏ពិតមែនប៉ុន្តែភាគច្រើនលើសលប់នៃគ្រួសារដែលគេចផុតពីភាពក្រីក្រ គឺបានគេចផុតទាំងប៉ផិតប៉ផើយ។ ពលរដ្ឋជិត៤.៥លាននាក់ កំពុងរស់នៅក្បែរគែមនៃភាពក្រីក្រ ដែលធ្វើឲ្យពួកគេងាយ រងគ្រោះធ្លាក់ចុះក្នុងភាពក្រីក្រវិញណាស់ កាលណាត្រូវប្រឈមទៅនឹងស្ថានភាពកន្ត្រាក់ផ្នែកសេដ្ឋកិច្ច ឬកត្តាខាងក្រៅណាផ្សេងទៀត។ តួយ៉ាងថ្មីៗ ក្នុងស្ថានភាពជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តនឹងដាក់ដាក់ឲ្យដំណើរការនូវ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ ដែលជាកម្មវិធីត្រូវបានគិតគូរ សំដៅជួយដល់ប្រជាជន ដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះក្នុងពេលដែលផលប៉ះពាល់ និងសភាពការណ៍នៃជំងឺកូវីដ-១៩ ដែលនៅតែបន្តអូសបន្លាយ និងមិនមានភាពច្បាស់លាស់។

រាជរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានពិនិត្យ និងវាយតម្លៃសភាពការណ៍ជាប្រចាំ ហើយបានដាក់ចេញជាបន្តបន្ទាប់នូវកញ្ចប់វិធានការ ទាំងសេដ្ឋកិច្ច និងសង្គម ដើម្បីជួយរក្សាលំនឹងអាជីវកម្ម ទ្រទ្រង់ជីវភាពរស់នៅរបស់កម្មករនិយោជិត ក៏ដូចជាទ្រទ្រង់ប្រាក់ចំណូលរបស់ប្រជាជន ដោយឈរលើគោលការណ៍ជួយធ្វើអន្តរាគមន៍លើវិស័យ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដូចជាផ្តល់ប្រាក់ឧបត្ថម្ភ ៤០ដុល្លារក្នុងមួយខែ សម្រាប់កម្មករនិយោជិត០១នាក់ ដែលបំពេញការងារក្នុងវិស័យកាត់ដេរ-វាយនភណ្ឌ ស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូប និងការងារ ក្នុងវិស័យទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន ផ្ទះសំណាក់ និងក្រុមហ៊ុនទេសចរណ៍ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ ក្រុងបាវិត និងក្រុងប៉ោយប៉ែតសម្រាប់រយៈពេល០៣ខែបន្ថែមទៀត រហូតដល់ខែធ្នូ ឆ្នាំ២០២០ និងពន្យារការបង់ពន្ធកាតព្វកិច្ចរបបសន្តិសុខសង្គមលើផ្នែកសោធនជាដើម។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ មានគ្រួសារក្រីក្រ និងងាយរងគ្រោះបានជាង ៧១ម៉ឺនគ្រួសារ ឬប្រជាជនជាង ២.៨លាននាក់ បានទទួលផលពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសនេះ ដោយរាជរដ្ឋាភិបាលបានចំណាយថវិកាបើក

ផ្តល់អស់ប្រមាណ ២៣២លានដុល្លារក្នុងខែមករា ឆ្នាំ២០២១។ សាច់ប្រាក់សម្រាប់ខែទី១ មានអ្នកទទួលផលចំនួន ៥៣០,៨៣៨គ្រួសារ ខែទី២ ចំនួន៥៩៨,៥១២គ្រួសារ ខែទី៣ ចំនួន៦៥៤,៦៥៥គ្រួសារ។ ដោយឡែក សម្រាប់ខែទី៤ ដែលបានចាប់ផ្តើមអនុវត្តបើកផ្តល់កាលពីខែកញ្ញា ឆ្នាំ២០២០ រាជរដ្ឋាភិបាលគ្រោងនឹងចំណាយថវិកាចំនួន១២៥,១៧២,៦៨៧,៦០០រៀល ប្រមាណជាង៣០លានដុល្លារសម្រាប់បើកផ្តល់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះចំនួន ៦៨៩,៩៧៣គ្រួសារ[17]។

មុខងារនៃវិភាជន៍បង្ហាញពីការជាប់ពាក់ព័ន្ធនឹងសំវិធានធន ដែលជាការផ្គត់ផ្គង់ ឬផ្តល់ជាទំនិញសាធារណៈ ដែលកើតចេញពីដំណើរនៃការទីផ្សារដោយជៀសមិនរួច ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អ្វីៗអាចអាស្រ័យលើថាតើមុខងារ ឬតួនាទីមួយណាដែលបង្ហាញពីប្រភេទនៃបញ្ហា និងដំណោះស្រាយ ដែលជាទូទៅការវិភាគសេដ្ឋកិច្ចត្រូវបានលើកយកមក និងបង្ហាញពីការជាប់ពាក់ព័ន្ធអំពីមុខងារ ឬតួនាទី ពោលគឺការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដែលអាចផ្តល់ការបែងចែកប្រាក់ចំណូល និងទម្រង់នៃចំណូលចិត្តរបស់អ្នកប្រើប្រាស់។ បញ្ហានៃការបែងចែក គឺអាចពិបាកដោះស្រាយ ប៉ុន្តែបែរជាបញ្ហានេះ គឺក្លាយជាចំណុចគន្លឹះចំបង និងសំខាន់នៃការបង្ហាញពីភាពចម្រូងចម្រាស់ទៅវិញ ក្នុងការជជែកវែកញែក និងពិភាក្សាដេញដោលអំពីថវិកា ឬគ្រោងថវិកា និងការបែងចែកថវិកាតាមគោលដៅប្រើប្រាស់។ ជាពិសេសមុខងារ ឬតួនាទីយ៉ាងសំខាន់ក្នុងការកំណត់គោលនយោបាយពន្ធ និងការផ្ទេរប្រាក់។

នៅពេលមានការអវត្តមាននៃការសម្របសម្រួលគោលនយោបាយ នៃការបែងចែកប្រាក់ចំណូល និងទ្រព្យសម្បត្តិ គឺជាដំបូងបង្អស់អាស្រ័យលើការបែងចែកកត្តាធនធាន និងធនធានដែលអាចចូលរួមផលិតកម្ម ដែលមានរួមទាំងសមត្ថភាពរកប្រាក់ចំណូលផ្ទាល់ខ្លួន និងភាពជាម្ចាស់នៃទ្រព្យសម្បត្តិដែលជាមរតកជាដើម។ បំណែកចែកនៃប្រាក់ចំណូលពឹងផ្អែកលើការបែងចែកកត្តាធនធាន និងធនធានដែលអាចចូលរួមផលិតកម្ម គឺត្រូវកំណត់ដោយដំណើរការនៃការកំណត់ថ្លៃ ដែលនៅក្នុងទីផ្សារប្រកួតប្រជែង កត្តាចំណូលស្មើនឹងតម្លៃនៃផលិតផលបន្ថែម។ បំណែងចែកប្រាក់ចំណូលក្នុងចំណោមបុគ្គលម្នាក់ៗ គឺអាស្រ័យលើកត្តាធនធាន និងធនធានដែលអាចចូលរួមផលិតកម្ម ដែលត្រូវកំណត់យកនៅលើទីផ្សារ។ បំណែងចែកប្រាក់ចំណូលនេះ អាច ឬមិនអាចស្របនឹងអ្វី ដែលសង្គមចាត់ទុកថាយុត្តិធម៌ ឬត្រឹមត្រូវនោះទេ។ ភាពខុសគ្នាដែលអាចទាញចេញរវាងគោលការណ៍ទី១ សំដៅលើប្រសិទ្ធភាពនៃការប្រើកត្តាធនធាន គឺតម្រូវឲ្យមានការកំណត់តម្លៃសមស្រប ត្រឹមត្រូវតាមការកំណត់ថ្លៃដែលមានភាពប្រកួតប្រជែង ហើយគោលការណ៍ទី២ សំដៅលើសំណើលើកឡើងពីបំណែងចែកប្រាក់ចំណូលក្នុងចំនោមគ្រួសារ គួរតែត្រូវបានកំណត់ជាក់លាក់តាមដំណើរការទីផ្សារ។ ក្នុងគោលការណ៍ទី១ គឺជាច្បាប់សេដ្ឋកិច្ច ដែលត្រូវតែធ្វើការសង្កេតឲ្យឃើញ ប្រសិនបើមានការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព មិនថាតើនៅក្នុងសេដ្ឋកិច្ចទីផ្សារ ឬនៅក្នុងសេដ្ឋកិច្ចផែនការណ៍នោះទេ។ ក្នុងគោលការណ៍ទី២ គឺជាបញ្ហាផ្សេងដែលថ្លៃកត្តា ត្រូវបានកំណត់នៅលើទីផ្សារ អាចមិនឆ្លើយតបគ្នា

---

[17] សូមមើល សេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គមរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមឆ្នាំ២០២០។

ទៅនឹងច្បាប់បទដ្ឋាននៃការប្រកួតប្រជែង។ ប៉ុន្តែទោះបីយ៉ាងណា ថ្លៃកត្តាទាំងអស់រួមទាំងប្រាក់ឈ្នួល និងប្រាក់ចំណូលផ្សេងៗចំពោះសេវាកម្មផ្ទាល់ខ្លួន ត្រូវបានកំណត់ដោយការប្រកួតប្រជែង និងលទ្ធផលនៃទម្រង់ការបែងចែក ដែលប្រហែលអាច ឬមិនអាចទទួលយកបាន។ ជាធម្មតា អ្វីដែលមិនអាចទទួលយកបាននោះ គឺអាចមកពីការជាប់ពាក់ព័ន្ធនឹងកម្រិតនៃវិសមភាព ជាពិសេសនៅក្នុងបំណែងចែកប្រាក់ចំណូលមូលធន បើទោះបីទស្សនៈស្តីពីភាពយុត្តិធម៌ត្រឹមត្រូវ នៃការបែងចែកខុសៗគ្នាក៏ដោយ ហើយភាគច្រើនត្រូវបានយល់ស្របឲ្យមានការកែសម្រួល ដើម្បីកាត់បន្ថយគម្លាតខុសគ្នា និងការផ្តល់ភាពគ្រប់គ្រាន់ត្រឹមត្រូវ។ ការកែសម្រួលបែបនេះ ទោះយ៉ាងណាអាចពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការចំណាយ និងការចំណាយដែលត្រូវឲ្យមានការរៀបចំបង្កើតជាយន្តការ និងគោលនយោបាយបែងចែកត្រឹមត្រូវ ប្រកបដោយសមធម៌។ល។

សេដ្ឋកិច្ចបានជួយកំណត់នូវអ្វី ដែលអាចឲ្យការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដោយពឹងផ្អែកទម្រង់នៃការបែងចែក និងតម្រូវការដែលមានប្រសិទ្ធិភាព។ ប៉ុន្តែនៅតែមានសំណួរចោទសួរស្តីអំពីថាតើបំណែងចែកនោះប្រកបដោយយុត្តិធម៌ ឬត្រឹមត្រូវដែរឬទេនៅក្នុងសង្គម និងសេដ្ឋកិច្ច? នៅក្នុងការវិភាគសេដ្ឋកិច្ចបែបទំនើបហាក់បីដូចជាមានការអៀនខ្មាស់ពីបញ្ហានេះ និងពិបាកវាស់វែងថាតើយុតិធម៌កម្រិតណា ឬការបែងចែកនោះត្រឹមត្រូវកម្រិតណា។ ខ្លឹមសារៈសំខាន់នៃសេដ្ឋកិច្ចសុខុមាលភាពទំនើប ត្រូវបានប្រើប្រាស់កំណត់ពីប្រសិទ្ធភាពសេដ្ឋកិច្ចនៅក្នុងល័ក្ខខ័ណ្ឌ ដែលមិនរាប់បញ្ចូលការពិចារណាអំពីការបែងចែក។ ការផ្លាស់ប្តូរល័ក្ខខ័ណ្ឌសេដ្ឋកិច្ចត្រូវបានគេនិយាយថាមានប្រសិទ្ធភាព ឬដើម្បីធ្វើឲ្យមានភាពប្រសើរឡើងនៃសុខុមាលភាព។

ចម្លើយចំពោះសំណួរនៃបំណែងចែកដោយយុត្តិធម៌ អាចជាប់ទាក់ទងនឹងការពិចារណា នៃទស្សនវិជ្ជាសង្គម និងការវិនិច្ឆ័យតម្លៃ។ ទស្សនវិទូបានលើកឡើងខុសៗគ្នានៃចំលើយ ដែលរួមទាំងទស្សនៈមួយ គឺថាមនុស្សមានសិទ្ធិទទួលបានផលផ្លែឈើ ដែលកើតចេញពីកត្តាធនធាន ដែលការបែងចែកនោះ គួរតែត្រូវបានរៀបចំឡើង ដើម្បីធ្វើអតិបរិមាកម្មសុភមង្គល ឬភាពពេញចិត្តអតិបរិមា ហើយដែលការបែងចែកនោះ គួរតែត្រូវធ្វើតាមស្តង់ដារជាក់លាក់នៃសមធម៌ ហើយដែលក្នុងករណីខ្លះអាចកំណត់ថាជាសមភាព។ ជម្រើសក្នុងចំណោមទាំងនេះ លក្ខណៈវិនិច្ឆ័យគឺមិនសាមញ្ញទេ ហើយក៏មិនងាយស្រួលដែរ ក្នុងការបកស្រាយពីលក្ខណៈវិនិច្ឆ័យណាមួយ ឲ្យឆ្លើយតបទៅនឹងទម្រង់នៃការបែងចែកត្រឹមត្រូវនោះឡើយ។

### ៣.៣. មុខងារនៃស្តិរភម្ម

ការដោះស្រាយជាមួយតួនាទីនៃគោលនយោបាយថវិកា ក្នុងបញ្ហានៃមុខងារនៃវិភាជន៍ធនធាន និងបំណែងចែកចំណូល គឺត្រូវកត់សំគាល់ពីឥទ្ធិពលរបស់សមិទ្ធផលនៃមុខងារម៉ាក្រូសេដ្ឋកិច្ច ពោលគឺ

ទៅលើគោលដៅ កម្រិតមានការងារធ្វើខ្ពស់ ស្ថិរភាពនៃកម្រិតថ្លៃ ភាពត្រឹមត្រូវនៃគណនីបរទេស និង អត្រាដែលអាចទទួលយកបាននៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសជាដើម។

ការសម្រេចបាននូវគោលដៅទាំងនេះមិនកើតឡើងដោយស្វ័យប្រវត្តិនោះទេ ប៉ុន្តែត្រូវទាមទារឲ្យមានការប្រើប្រាស់នូវគោលនយោបាយ និងការចង្អុលបង្ហាញអំពីការអនុវត្តគោលនយោបាយទាំងនោះ។ បើគ្មានគោលនយោបាយ ដែលត្រូវដាក់ឲ្យអនុវត្តនោះទេ សេដ្ឋកិច្ចនឹងមាននិន្នាការ ឬទំនោរប្រែប្រួលឡើងចុះយ៉ាងខ្លាំង មិនអាចគ្រប់គ្រងបាន និងអាចទទួលរងផលប៉ះពាល់ទាំងរយៈពេលខ្លី និងរយៈពេលវែង ហើយអាចបណ្តាលឲ្យអត្រានិកម្មភាពកើនឡើងខ្ពស់ខ្លាំង ធ្វើបាត់បង់ចំណូលអតិផរណាប្រែប្រួលកើនឡើងខ្ពស់ និងបាត់បង់ស្ថិរភាព និងនិរន្តរភាពនៃម៉ាក្រូសេដ្ឋកិច្ច ។

បទពិសោធន៍នៃបណ្តាប្រទេសមួយចំនួនដូចជានៅអឺរ៉ុប និងសហរដ្ឋអាមេរិកដែលបានជួបប្រទះ និងឆ្លងកាត់ភាពអត់ការងារធ្វើ និងកម្រិតខ្ពស់ខ្លាំងនៃអតិផរណា គឺជាមេរៀនយ៉ាងឈឺចាប់ និងវេទនាចំពោះការរស់នៅក្នុងស្ថានភាពយ៉ាប់យ៉ឺនបំផុត។ល។ ការរក្សាស្ថិរភាពការងារ និងស្ថិរភាពថ្លៃ គឺជាគោលដៅសំខាន់ នៃគោលបំណងម៉ាក្រូសេដ្ឋកិច្ចនៃវិស័យសាធារណៈ ដែលបានចាប់ផ្តើមកើតមានឡើង និងឈានដល់បរិបទនៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទី២។ ដោយសារការយល់ឃើញតាមទស្សនៈរបស់សេដ្ឋកិច្ចក្លាស៊ិកបង្ហាញថា ភាពអត់ការងារដោយមិនស្ម័គ្រចិត្ត មិនអាចកើតមាននៅក្នុងសេដ្ឋកិច្ចប្រៀបធៀបបានទេ ហើយក៏មានការងើបឡើងនូវទស្សនៈផ្សេងៗជាច្រើនបានលេចចេញនូវទស្សនៈថា រដ្ឋាភិបាលដើរតួនាទីសំខាន់ និងមានឥទ្ធិពលលើកម្រិតតម្រូវការសរុប និងអនិកម្មភាពតាមរយៈការប្រើប្រាស់ពន្ធ និងការចំណាយនៅក្នុងសេដ្ឋកិច្ច។ ទោះបីយ៉ាងណា វិធីសាស្ត្រតាមបែបប្រពៃណីចំពោះការប្រើគោលនយោបាយសារពើពន្ធ នៅមានលក្ខណៈមិនទូលំទូលាយ និងត្រូវទទួលរងការរិះគន់មួយចំនួន ដូច្នេះហើយតួនាទីរបស់រដ្ឋាភិបាលនៅក្នុងវិស័យនេះ នៅតែត្រូវបានគេចោទសួរដដែលៗ។ កម្រិតទាំងស្រុងនៃការងារ និងថ្លៃទំនិញក្នុងសេដ្ឋកិច្ចត្រូវពឹងផ្អែកលើកម្រិតនៃតម្រូវការសរុបដែលជាប់ទាក់ទងទៅនឹងសក្តានុពល ឬសមត្ថភាពផលិតផល ឬផលិតផលសរុបដែលវាស់វែងដោយតម្លៃទីផ្សារ។ កម្រិតនៃតំរូវការ គឺជាតួនាទីនៃការសម្រេចចិត្តចំណាយរបស់អ្នកប្រើប្រាស់ សហគ្រាសសាជីវកម្ម និងវិនិយោគិនហិរញ្ញវត្ថុ និងរដ្ឋាភិបាល។ ការសម្រេចចិត្តទាំងនេះត្រូវពឹងផ្អែកលើកត្តាជាច្រើន ដូចជាប្រាក់ចំណូលដែលមានពីអតីតកាល និងបច្ចុប្បន្ន ប្រាក់សន្សំដែលមាន ទ្រព្យសម្បត្តិ និងការរំពឹងទុកនៃចំណូលដែលនឹងរកបាន។ នៅក្នុងរយៈពេលណាមួយ កម្រិតនៃការចំណាយអាចមិនគ្រប់គ្រាន់ដើម្បីធានាសុវត្ថិភាពក្នុងពេលបាត់បង់ការងារពេញលេញ ឬកម្លាំងពលកម្មត្រូវបានកាត់បន្ថយ។

ចំពោះហេតុផលផ្សេងៗទៀត ដូចជាប្រាក់ឈ្នួល និងថ្លៃ មាននិន្នាការ ឬទំនោរធ្លាក់ចុះក្រោមដែលមិនមានយន្តការណាមួយត្រៀមទុក ដើម្បីដោះស្រាយផលប៉ះពាល់ នៃការបាត់បង់ការងារការស្តារឡើងវិញ និងការធ្វើឲ្យប្រសើរឡើងវិញដោយស្វ័យប្រវត្តិនៅរយៈពេលវែង។ វិធានការពង្រីក

ដើម្បីជំរុញបង្កើតតម្រូវការសរុប គឺមានភាពចាំបាច់ណាស់។ នៅពេលណាមួយ ចំណាយអាចលើសពីចំណូលដែលមាន ក្រោមល័ក្ខខ័ណ្ឌនៃកំណើនការងារខ្ពស់ ហើយដូច្នេះនឹងអាចបណ្តាលឲ្យមានអតិផរណា។ ក្នុងស្ថានភាពបែបនេះ គោលនយោបាយរឹតត្បិត ជាវិធានការចាំបាច់ដើម្បីកាត់បន្ថយតម្រូវការសរុប ហើយនៅពេលកើតមានកង្វះតម្រូវការ នឹងបន្តបង្កើតកង្វះតម្រូវការទៀត ហើយចេះតែបន្តទៀត។ ដូច្នេះនឹងនាំឲ្យមានការកើនឡើងតម្លៃ និងកាន់តែធ្វើឲ្យកម្រិតថ្លៃទាំងស្រុងកើនឡើងបន្ថែមទៀត នោះជាហេតុនាំឲ្យមានអតិផរណាជាថ្មី។ ក្នុងករណីមិនមានដំណើរការកែតម្រូវដោយស្វ័យប្រវត្តិណាមួយ ដែលអាចធានាឲ្យសេដ្ឋកិច្ចត្រូវត្រឡប់ទៅរកស្ថានភាពការងារខ្ពស់ និងស្ថិរភាពខ្ពស់យ៉ាងឆាប់រហ័សវិញនោះទេ ហើយការប្រែប្រួលនៃការរំពឹងទុកក៏អាចជាកម្លាំង ដែលបណ្តាលធ្វើឲ្យមានកំណើន ក៏ដូចជាអាចធ្វើឲ្យកើតមានអស្ថិរភាព និងការធ្លាក់ចុះផងដែរ។

បើពិនិត្យមើលប្រទេសកម្ពុជា បង្ហាញឲ្យឃើញថាកំណើនសេដ្ឋកិច្ចទទួលបានជាមធ្យម ៦.៨ ភាគរយ ក្នុងចន្លោះឆ្នាំ១៩៩៤ និង២០០៤ ក៏ប៉ុន្តែកំណើនការងារមានជាមធ្យមត្រឹមតែ៣.៣ភាគរយប៉ុណ្ណោះ។ កម្រិតនិកម្មភាពបង្ហាញពីទំហំនៃលទ្ធផលទីផ្សារការងារនៅប្រទេសកម្ពុជា។ យោងតាមរបាយការណ៍នៃការស្ទង់មតិឆ្នាំ២០០០ ២០០១ និង២០០៤ បានបង្ហាញនូវអត្រានិកម្មភាពទាបរវាង ២.៥ភាគរយ ១.៨ភាគរយ និង០.៨ភាគរយនៃឆ្នាំជាបន្តបន្ទាប់ ហើយក្នុងជំរឿនឆ្នាំ២០០៨ ស្ថិតក្នុងអត្រា១.៧ភាគរយ ។ ក្នុងជំរឿនប្រជាជនឆ្នាំ២០០៨ អ្នកមានការងារធ្វើក្នុងវិស័យកសិកម្ម ព្រៃឈើ និងនេសាទ មាន ៧២ភាគរយ ក្នុងវិស័យពាណិជ្ជកម្ម និងជួសជុលយានយន្តមាន ៨ភាគរយ ស្ថិតក្នុងវិស័យកម្មន្តសាល ៦ភាគរយ និង ស្ថិតក្នុងវិស័យរដ្ឋបាលសាធារណៈមានតែ៣ភាគរយតែប៉ុណ្ណោះ។ តាមរយៈតួលេខជំរឿនទូទៅ នៃប្រជាជនក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ ចំនួនប្រជាជនសរុបមានចំនួន១៥.២៨៨.៤៨៩នាក់ ដែលបានកើនឡើងពី ១៣.៣៩៥.៦៨២នាក់នៅក្នុងជំរឿនឆ្នាំ ២០០៨។ ចំនួនប្រជាជនសរុបកើនឡើង១.៨៩២.៨០៧នាក់ត្រូវនឹង១៤.១ភាគរយ ក្នុងរយៈពេល១១ឆ្នាំ រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩ ដែលក្នុងនោះប្រុសមាន ៧.៤១៨.៥៧៧នាក់ ស្មើនឹង៤៨.៥ភាគរយនៃចំនួនប្រជាជនសរុប។ បើតាមការគូសបញ្ជាក់របស់ក្រសួងការងារ ក្នុងចំណោមប្រជាជនមានការងារធ្វើ ១០លាននាក់នោះ មានជាង១.៥លាននាក់ ធ្វើការក្នុងផ្នែកសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងមាន២.២លាននាក់ ធ្វើការក្នុងផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ រីឯអ្នកធ្វើការក្នុងវិស័យកសិកម្មវិញមានប្រមាណ ៤លាននាក់ ដែលមន្ត្រីសាធារណៈ មាន៥០ម៉ឺននាក់ និងពលករដែលធ្វើការនៅក្រៅប្រទេស មានប្រមាណជិត ១.៣លាននាក់។ សរុបទៅ គឺមានប្រជាជនកម្ពុជាប្រមាណ១០លាននាក់មានការធ្វើ។

ផ្អែកលើកត្តាសេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនថេរជាមធ្យមប្រចាំឆ្នាំ ៧ភាគរយ អត្រាភាពក្រីក្ររបស់ប្រជាជនត្រូវបានកាត់បន្ថយមកត្រឹម ១៣.៥ភាគរយ និងអត្រាអត់ការងារធ្វើចំនួន០.៧ភាគរយ ក្នុងឆ្នាំ២០១៧ ដែលបានជួយលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងលើកស្ទួយដល់សេដ្ឋកិច្ចជាតិ ហើយអត្រាមានការងារធ្វើមានរហូតដល់៩៩.៣ភាគរយ។ ជាមួយគ្នានេះ សហគ្រាស គ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធដែលមានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈសរុបចំនួនប្រមាណ ១.៤ម៉ឺនសហគ្រាស និងគ្រឹះស្ថានដែលមានកម្មករនិយោជិតចំនួន ១.៥លាននាក់ ដោយបានទទួលប្រាក់ឈ្នួលជាមធ្យមជាង៣៧០០លានដុល្លារក្នុងមួយឆ្នាំ ហើយបើគិតបូកប្រាក់បញ្ញើដែលពលករពីក្រៅប្រទេស បានផ្ញើមកជូនក្រុមគ្រួសារក្នុងឆ្នាំ ជាង២៨០០លានដុល្លារ គឺសរុបមានជាង ៦៥០០លានដុល្លារក្នុងមួយឆ្នាំ[18]។

## ៤. គោលនយោបាយ និងវិស័យសាធារណៈ

មានសំណួរជាច្រើនដែលបានចោតសួរ និងកំពុងចោទសួរអំពីសកម្មភាព និងតួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់វិស័យសាធារណៈ ជំរុញកំណើសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ក្នុងក្របខ័ណ្ឌការធ្វើកំណែទម្រង់ជំរុញកំណើសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ក្នុងក្របខ័ណ្ឌការធ្វើកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងរដ្ឋបាលសាធារណៈជាដើម។

ការងារ និងសកម្មភាពទាំងនេះជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល ដែលត្រូវដើរតួនាទី និងមានមុខងារជាការធ្វើកិច្ចអន្តរាគមន៍ក្នុងវិស័យសាធារណៈ និងក្នុងប្រព័ន្ធទីផ្សារដើម្បីសម្រេចបាននូវគោលបំណង់ម៉ាក្រូសេដ្ឋកិច្ចតាមរយៈការប្រើប្រាស់ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃនូវតួនាទីទាំងបីខាងលើ ក្នុងហិរញ្ញវត្ថុសាធារណៈ ដូចជាមុខងារនៃវិភាជន៍ធនធាន មុខងារនៃបំណែងចែកប្រាក់ចំណូល និងមុខងារនៃស្ថិរកម្ម ឬមុខងារនៃការរក្សាលំនឹងសេដ្ឋកិច្ច ក្នុងគោលបំណងឲ្យប្រជាជនទទួលបាននូវអតិបរមាកម្មសុខុមាលភាព និងការផ្តល់ការរស់នៅឲ្យមានសុខដុមរមណីកម្មប្រសើរប្រកបដោយសមធម៌ យុត្តិធម៌ សុវត្ថិភាព សន្តិភាព និងថ្លៃថ្នូរក្នុងសង្គមសេដ្ឋកិច្ចស៊ីវិល័យជឿនលឿង។

នៅក្នុងការដឹកនាំ និងអភិវឌ្ឍប្រទេស រាជរដ្ឋាភិបាលកម្ពុជាមានទិសដៅ និងផែនការច្បាស់លាស់ដោយបានដាក់ចេញនូវការអនុវត្តយុទ្ធសាស្ត្រត្រីកោណក្នុងឆ្នាំ១៩៩៨ ដែលមានទិសដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាតាមរយៈមុំទី១. ការធ្វើសន្តិភាវូបនីយកម្ម ដែលបាននាំសុខសន្តិភាព និងស្ថិរភាព និងរក្សាបាននូវសន្តិសុខ សម្រាប់ប្រជាជនកម្ពុជា និងប្រទេសជាតិទាំងមូល ហើយចំពោះមុំទី២. ការធ្វើសមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់ និងសហគមន៍អន្តរជាតិ ដែលដឹកនាំប្រទេសកម្ពុជាបានទទួលអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិមកវិញ ដែលអាសនៈនេះបានបាត់បង់ក្រោយការប្រឈមគ្នាខាងប្រដាប់អាវុធនៅខែកក្កដា ឆ្នាំ១៩៩៧ ហើយបន្ទាប់មកកម្ពុជាបានក្លាយជាសមាជិកទី១០ នៃសមាគមនប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថាអាស៊ាន។ ការដែលកម្ពុជាបានចូលជាសមាជិកអាស៊ានបានធ្វើឲ្យកម្ពុជាលែងជាប្រទេសឯកោតទៅទៀតធ្វើកម្ពុជាអាចឈរស្មើមុខស្មើមាត់ ជាមួយប្រទេសបណ្តាប្រទេសជាសមាជិក និងមានការចូលរួមនូវរាល់ការ

---

[18] សូមមើល របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០២០។

សម្រេចចិត្តនៅក្នុងតំបន់ ខាងផ្នែកនយោបាយ។ ចំពោះផ្នែកសេដ្ឋកិច្ចវិញ គឺកម្ពុជាបានក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ ដែលការធ្វើពាណិជ្ជកម្មមានភាពងាយស្រួលជាងមុន ប្រជាជនអាចរកការងារធ្វើបានយ៉ាងទូលំទូលាយទាំងក្នុងប្រទេស និងក្នុងតំបន់ ហើយទេសចរមានការកើនឡើងដែលអាចជួយផលិតកំណើនសេដ្ឋកិច្ចកម្ពុជាឲ្យរីកចម្រើន និងរឹងមាំជារៀងរាល់ឆ្នាំ។ មិនតែប៉ុណ្ណោះ ក៏ធ្វើឲ្យកម្ពុជាមានការរីកចម្រើនខាងផ្នែកទំនាក់ទំនងដោយបានជំរុញ និងពង្រីកពង្រឹងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្នល់ស្ពាន និងការលើកលែងទិដ្ឋាការទៀតផង។ ចំពោះខាងផ្នែកសង្គម គឺកម្ពុជាទទួល និងសម្រេចបានកិច្ចសហប្រតិបត្តិការ ជាមួយប្រទេសក្នុងតំបន់ ក្នុងការថែរក្សាសន្តិភាព សន្តិសុខសង្គម ការទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម ហើយក្នុងខែតុលាឆ្នាំ២០០៤ កម្ពុជាបានក្លាយជាសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោក។ យុទ្ធសាស្ត្រត្រីកោណ ក្នុងមុំទី៣ គឺការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលត្រូវបានធ្វើឡើងតាមរយៈកម្មវិធីកំណែទម្រង់ ទូលំទូលាយពាក់ព័ន្ធនឹងកំណែទម្រង់សាធារណៈ វិមជ្ឈការ ការរំសាយកងទ័ព កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ សមភាពយេនឌ័រ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការលុបបំបាត់អំពើពុករលួយ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

ដូចនេះសមិទ្ធផលដែលសម្រេចបានក្នុងការដាក់ចេញ និងបានអនុវត្តយុទ្ធសាស្ត្រត្រីកោណ ១៩៩៨-២០០៣ បានទទួលជោគជ័យយ៉ាងធំធេង ធ្វើឲ្យកំណើនសេដ្ឋកិច្ចខ្ពស់ ការវិនិយោគកើនឡើងឆាប់រហ័ស ការគ្រប់គ្រង និងអភិបាលកិច្ចបានប្រសើរជាងមុនខាងគោលនយោបាយរូបិយវត្ថុសារពើពន្ធ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលជាលទ្ធផលនាំឲ្យមានអតិផរណាមានកម្រិតទាប ការកើនឡើងទុនបម្រុង អត្រាប្តូរប្រាក់មានស្ថិរភាព ការកើនឡើងទុនពីបរទេស កំណើនវិនិយោគឯកជន និងការអភិវឌ្ឍវិស័យឯកជនបានយ៉ាងលឿន[19]។

បន្តពីយុទ្ធសាស្ត្រត្រីកោណ នៃការដឹកនាំអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណក៏ត្រូវបានដាក់ចេញឲ្យអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណនេះ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងឆ្នាំ២០០៤មកម្លេះ។ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានយុទ្ធសាស្ត្រចតុកោណចំនួនបីដំណាលរួចហើយគឺ ដំណាក់កាលទី១ ចន្លោះឆ្នាំ២០០៤-២០០៨ ដំណាក់កាលទី២ ចន្លោះឆ្នាំ២០០៨-២០០១៣ និងដំណាក់កាលទី៣ ចន្លោះឆ្នាំ ២០១៣-២០១៨។

ការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំង៣ដំណាក់កាលរួចមកហើយនេះ ជាលទ្ធផលនាំឲ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មីគួរជាទីមោទនៈបំផុត ធ្វើកម្ពុជាផ្លាស់ប្តូរនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការលើកម្ពស់ជីវភាពប្រជាជនឲ្យកាន់តែប្រសើរឡើងទាំងខាងសម្ភារៈ និងខាងស្មារតីតាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការបង្កើតការងារជូនប្រជាជន ការធានាសមធម៌សង្គម និងការ

[19] សូមមើល យុទ្ធសាស្ត្រត្រីកោណ ១៩៩៨-២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៨ និង ប្រវត្តិវិទ្យាសម័យអាណាចក្របារាំង-ព្រះរាជាណាចក្រកម្ពុជាទី២ របស់ ក្រសួងអប់រំ យុវជន និងកីឡា (២០១៧)។

ពង្រឹងប្រសិទ្ធភាព នៃអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ។ នៅក្នុងនីតិកាលទី៦នៃរដ្ឋសភារាជរដ្ឋាភិបាលក៏បានអនុម័ត និងដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ឆ្នាំ២០១៨-២០២៣តទៅទៀត ដោយត្រូវពង្រឹងបន្ថែមទៀតលើសមិទ្ធផលសម្រេចបានកន្លងមក និងផ្តោតសំខាន់លើរបៀបវារៈជានាប្រសិទ្ធភាពខ្ពស់ដើម្បីកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ខាងមុននេះ។

ផែនការយុទ្ធសាស្ត្រចតុកោណក្នុងដំណាក់កាលទី៤ បានក្លាយជាកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា និងរួមគ្នាបំពេញតួនាទីជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៩-២០២៣ ដែលបានកំណត់សូចនាករលទ្ធផល និងពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត និងដែលត្រូវមានសង្គតិភាពជាមួយនឹងគោលនយោបាយតាមវិស័យដទៃទៀតរបស់រាជរដ្ឋាភិបាល ហើយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នឹងក្លាយជាមគ្គទេសក៍ច្បាស់លាស់ សម្រាប់តំរែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍទាំងអស់ឲ្យស្ថិតនៅក្នុងជវភាពនៃប្រព័ន្ធអង្គតែមួយ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងទៅខាងមុខ ដោយធានាបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានសរុបរបស់ប្រទេសជាតិ។

ភាពចាំបាច់នៃការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤តទៅមុខនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិដ្ឋភាពសំខាន់ នៃគោលដៅជាយុទ្ធសាស្ត្រទាំង៤ ដែលជាការប្តេជ្ញាចិត្តក្នុងការបន្តអនុវត្តដូចជា៖ ទី១.គឺធានាឲ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់៧ភាគរយប្រកបដោយចីរភាព និងធន់នឹងវិបត្តិតាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចថ្មីដោយទូលំទូលាយ និងមានភាពប្រគួតប្រជែង ជាមួយនឹងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឲ្យនៅទាប ការធានាស្ថិរភាពអត្រាប្តូរប្រាក់ ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់មុត។ ទី២. គឺបង្កើតការងារឲ្យបានកាន់ច្រើន ទាំងបរិមាណ និងគុណភាពជូនប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជនតាមរយៈការផ្តល់ជំនាញ ព័ត៌មានទីផ្សារការងារ ការកែលម្អល័ក្ខខ័ណ្ឌការងារ ការលើកកម្ពស់សកម្មភាពធុរកិច្ច និងការជំរុញការវិនិយោគទាំងក្នុងប្រទេស និងក្រៅប្រទេស។ ទី៣. គឺសម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឲ្យស្ថិតនៅក្នុងអត្រាទាបជាង១០ភាគរយ ការពារមិនឲ្យភាពក្រីក្រវិលត្រលប់មកវិញ ដោយផ្តោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ ការអនុវត្តគោលនយោបាយគាំពារសង្គម ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ និងការផ្តល់សេវាកម្មសាធារណៈប្រកបដោយគុណភាព និងការកាត់បន្ថយគម្លាតសង្គម។ ទី៤.គឺត្រូវបន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងបរិស្ថានអំណាយផលសម្រាប់ការវិនិយោគ។ ចំពោះវិស័យអាទិភាពទាំង៤ ដែលរាជរដ្ឋាភិបាលកំណត់យករួមមាន ផ្លូវ ទឹក ភ្លើង និងមនុស្ស ដើម្បីជំរុញការអភិវឌ្ឍប្រទេសដែលលំដាប់នៃសារៈសំខាន់របស់អាទិភាពទាំងនេះ ត្រូវបានផ្លាស់ប្តូរទៅតាម

ដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ។ ក្នុងដំណាក់កាលទី១ និងទី២ នៃយុទ្ធសាស្ត្រចតុកោណ បានផ្តោតអាទិភាពទី១ លើផ្លូវ ហើយ ទឹក ភ្លើង និងមនុស្ស គឺជាអាទិភាពបន្តបន្ទាប់ ហើយក្នុងដំណាក់កាលទី៣ គឺមនុស្ស បានក្លាយជាអាទិភាពទី១វិញ ហើយផ្លូវ ភ្លើង និងទឹក បានក្លាយជាអាទិភាពបន្តបន្ទាប់។ ក្នុងដំណាក់កាលទី៤ នឹងត្រូវបន្តផ្តោតការយកចិត្តទុកដាក់លើ វិស័យអាទិភាពទាំង៤ ដោយតម្កល់មនុស្ស ជាអាទិភាពទី១ នៅលើគេ។ ក្នុងគោលដៅនេះ ចតុកោណយុទ្ធសាស្ត្រទាំង៤ នៃយុទ្ធសាស្ត្រចតុកោណត្រូវបានរៀបចំកែសម្រួលឡើងវិញ ឲ្យឆ្លុះបញ្ចាំងវិស័យអាទិភាពទាំង៤ និងកិច្ចការមួយចំនួនដែលឆ្លើយតបនឹងតម្រូវការអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មី ដូចក្នុងចតុកោលនីមួយៗ។ ចំពោះចតុកោណទី១. គឺជាការអភិវឌ្ឍធនធានមនុស្សរួមមាន ១. ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣. ការលើកម្ពស់សេវាសុខភាពសាធារណៈ និងអាហាររូបត្ថម្ភ និង ៤. ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។ ក្នុងចតុកោលទី២. គឺជាការធ្វើពិពិធកម្មសេដ្ឋកិច្ចរួមមាន ១. ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល ២. ការអភិវឌ្ឍប្រភពនៃកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ ៣. ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤.០ និង៤. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ។ ចំពោះចតុកោលទី៣. គឺជាការលើកស្ទួយវិស័យឯកជន និងការងាររួមមាន ១. ការអភិវឌ្ឍទីផ្សារការងារ ២. ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព ៣. ការរៀបចំ និងអនុវត្តភាពជាដៃគូវិស័យសាធារណៈ និងឯកជន និង៤. ការពង្រឹងការប្រកួតប្រជែង។ ក្នុងចតុកោលទី៣. គឺជាការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្នរួមមាន ១. ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ២. ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ដោយចីរភាព ៣. ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង៤. ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ[20]។

ជាការសន្និដ្ឋានរួមយុទ្ធសាស្ត្រចតុកោលណដំណាក់កាលទី៤ បានក្លាយជាកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦នៃរដ្ឋសភាព នឹងត្រូវបានអនុវត្តតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៩-២០២៣។ ទន្ទឹមនឹងនេះ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងត្រូវរៀបចំយុទ្ធសាស្ត្រគៀគរចំណូលរយៈពេលមធ្យម ឆ្នាំ២០១៩-២០២៣ ដែលជាមូលដ្ឋានសម្រាប់ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំណាយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤នេះ។

បន្ថែមពីលើនេះទៀតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម សំដៅតម្រូវការធនធាន និងហិរញ្ញប្បទានរយៈពេលបីឆ្នាំរំកិលទៅមុខឲ្យបានជាក់លាក់ ហើយបន្ទាប់មក ក្រសួង ស្ថាប័ននីមួយៗ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោម

[20] សូមមើល យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភាឆ្នាំ ២០១៨។

ជាតិត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយ ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដោយកំណត់ឲ្យកាន់តែច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយអំពីគោលនយោបាយ ព្រមទាំងរចនាសម្ព័ន្ធកម្មវិធីដែលនឹងត្រូវយកទៅអនុវត្ត ក្នុងក្របខ័ណ្ឌនៃថវិកាសមិទ្ធកម្មស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ហើយផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ននីមួយៗនឹងត្រូវយកទៅផ្ទួរផ្គងជាមួយក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ពិចារណារៀបចំការវិភាជថវិកាប្រចាំឆ្នាំ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព សំដៅឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដូចនេះថវិកាប្រចាំឆ្នាំក្លាយជាឧបករណ៍ចម្បងបំផុត សម្រាប់សម្រេចឲ្យបាននូវគោលដៅទាំងឡាយដែលត្រូវបានដាក់ចេញមកក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ហើយការអនុវត្តជាក់ស្តែង ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណនេះ នឹងត្រូវបានធ្វើឡើងដោយប្រើប្រាស់យន្តការនៃការអនុវត្តថវិកាតាមរយៈការពង្រឹងការអនុវត្តថវិកាកម្មវិធី និងការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។

# មេរៀនទី២៖ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសារពើពន្ធ

## ១. សេចក្តីផ្តើម

ហិរញ្ញវត្ថុសាធារណៈ គឺជាផ្នែកមួយនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលត្រូវបានរៀបចំ បង្កើត និងអនុវត្តតាមចរិតលក្ខណៈស្របនឹងគោលការណ៍ និងមុខងារនៃនៃវិភាជន៍ធនធាន មុខងារនៃបំណែកចែកប្រាក់ចំណូល និងមុខងារនៃស្ថិរភាពសេដ្ឋកិច្ច តាមរយៈការជានាឲ្យនិកម្មភាពកម្រិតទាបការរក្សាលំនឹងអតិផរណាកម្រិតទាប តាមដែលអាចធ្វើទៅបានក្នុងម៉ាក្រូសេដ្ឋកិច្ច ការអនុវត្តវិចារណកម្មចំណាយ និងពន្ធដារ លៃលកយ៉ាងណាឲ្យមានប្រសិទ្ធភាពនៃការប្រមូល ការគៀរគរ និងវិធាននៃគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ ដែលជួយជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ប្រព័ន្ធប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាត្រូវគោរព និងអនុលោមតាម និងស្ថិតក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី៧ នីតិកាលទី៣ ដែលត្រូវជំនួសច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលបានប្រកាសឲ្យប្រើប្រាស់ក្នុងឆ្នាំ១៩៩៣[21]។

ច្បាប់ហិរញ្ញវត្ថុនេះ គឺសំដៅដល់ច្បាប់ដែលគ្រោងចំណូល និងចំណាយប្រចាំឆ្នាំរបស់រដ្ឋ បទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងវិស័យហិរញ្ញវត្ថុ និងការទូទាត់ផ្សេងៗ ដែលត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្តមុខងារ កម្មវិធី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិស្តីពីវិស័យហិរញ្ញវត្ថុដែលច្បាប់កំណត់។ ហើយលក្ខណៈជាច្បាប់ហិរញ្ញរួមមាន ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា។

នៅក្នុងមាត្រាទី១ មាត្រាទី២ និងមាត្រា៣ នៃជំពូកទី១ អំពីបទប្បញ្ញត្តិទូទៅ ត្រូវបានចែងអំពីការកំណត់គោលដៅ គោលបំណង និងវិសាលភាពជាច្បាប់គោល។ ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ មានគោលដៅកំណត់គោលការណ៍ជាមូលដ្ឋាន សម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុជាពិសេសសម្រាប់ជំហាននីមួយៗ នៃដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិកា ការត្រួតពិនិត្យលទ្ធផលថវិកា ការកំណត់មុខងារ ការទទួលខុសត្រូវ ព្រមទាំងកម្មវិបាកលើកំហុសឆ្គង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលនឹងគ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ច្បាប់នេះមានគោលបំណងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយគោរពគោលការណ៍ បូរណភាព អាជ្ញាភាព ឯកត្តភាព សមាគតភាព សកលភាព សង្គតិភាព គណនេយ្យភាព តម្លាភាព ស្ថិរភាព ភាពគ្រប់ជ្រុងជ្រោយ និងសមិទ្ធកម្ម។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គ្របដណ្តប់ទាំងហិរញ្ញវត្ថុសាធារណៈជាតិទាំងទំនាក់ទំនង និងអន្តរសកម្មភាពរវាង

[21] សូមមើល ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ២០០៨។

ហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុឯកជនអន្តរជាតិ ហើយត្រូវជានាការគោរពគោលការណ៍ថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ភាពផ្សាភ្ជាប់រវាងថវិកា និងគោលនយោបាយ និងគណនេយ្យភាពចំពោះសមិទ្ធកម្ម។ ច្បាប់នេះមានវិសាលភាពជាច្បាប់គោល ដែលត្រូវបានយកធ្វើជាមូលដ្ឋាន និងគោរពអនុវត្តតាម សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

រដ្ឋាភិបាលនៃប្រទេសនីមួយៗ តែងតែខិតខំប្រឹងប្រែងកសាងលទ្ធផលសេដ្ឋកិច្ចប្រទេសឲ្យមានវឌ្ឍនភាពរីកចម្រើនដើម្បីបំពេញចិត្ត និងគោរពតាមការសន្យារបស់ខ្លួន ដែលបានធ្វើឡើងមុខពេលឈ្នះឆ្នោតតាមរយៈកម្មវិធីនយោបាយ និងគោលនយោបាយ។ ប្រព័ន្ធគ្របគ្រងហិរញ្ញវត្ថុសាធារណៈជាកម្លាំងចលករជួយជំរុញឲ្យរដ្ឋាភិបាល អាចសម្រេចបាននូវវិន័យថវិកា និងគោលការណ៍ ដែលបានកំណត់។

សារពើពន្ធសំដៅដល់បណ្តាពន្ធទាំងឡាយរួមទាំងពន្ធផ្ទាល់ និងពន្ធប្រយោល ដែលរួមមានអាករ និងថ្លៃសេវានានា ដែលកំណត់ដោយរដ្ឋាភិបាលនៃប្រទេសនោះ។ ហើយនៅប្រទេសកម្ពុជា ការកំណត់ និងប្រមូលពន្ធក្នុងប្រទេស និងការប្រមូលពន្ធផ្សេងៗ ជាតួនាទីអភិបាលកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ប្រភេទសារពើពន្ធក្នុងស្រុកទាំងអស់ ហើយពន្ធនាំចេញ នាំចូលជាកាតព្វកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ ប្រព័ន្ធហិរញ្ញវត្ថុសារជារណៈសំដៅលើការគ្រប់គ្រង បែងចែក និងប្រើបាស់គ្រោងថវិកា និងថវិកាក្នុងគោលនយោបាយសារពើពន្ធ។ គោលនយោបាយសារពើពន្ធ ជាផ្នែកមួយនៃប្រព័ន្ធហិរញ្ញវត្ថុសារជារណៈ ដែលជាគោលនយោបាយនៃការប្រើប្រាស់ការចំណាយ ដែលត្រូវបែងចែកជា២គឺ ការទិញ និងការផ្ទេរ និងចំណូលដែលមានប្រភពមកពីការប្រមូលពន្ធ ដោយអាជ្ញាធរមានសមត្ថកិច្ចខាងពន្ធដារ ឬរដ្ឋាភិបាល ដើម្បីមានឥទ្ធិពលលើសេដ្ឋកិច្ច។

គោលនយោបាយសារពើពន្ធ ក៏ជាផ្នែកមួយនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ហើយត្រូវបានយកមកប្រើប្រាស់ជាវិធានការ យន្តការប្រៀបធៀបនឹងគោលនយោបាយរូបិយវត្ថុ ដែលត្រូវបានគ្រប់គ្រងដោយធនាគារកណ្តាលនៃប្រទេសពោលគឺ ធនាគារជាតិនៃកម្ពុជា ដែលកំណត់ និងគ្រប់គ្រងលំហូរនៃការផ្គត់ផ្គង់រូបិយវត្ថុ ស្ថិរភាពកម្រិតថ្លៃ ការគ្រប់គ្រងអត្រាការប្រាក់ និងព្យាយាមធ្វើឲ្យមានស្ថិរភាពសេដ្ឋកិច្ច។ ឧបករណ៍សំខាន់របស់គោលនយោបាយសារពើពន្ធ គឺការផ្តោតលើចំណាយរបស់រដ្ឋាភិបាល និងការកំណត់ពន្ធដារ។ ការប្រែប្រួលនៃឧបករណ៍ មានឥទ្ធិពលផ្សេងៗលើសេដ្ឋកិច្ច ដូចជាតម្រូវការសរុប ចំណាយសរុបដែលមានសមាសធាតុដូចជា ការចំណាយការប្រើប្រាស់របស់គេហជន ការសន្សំ ការវិនិយោគ និងចំណូល។ល[22]។

---

[22] សូមមើល ម៉ាក្រូសេដ្ឋកិច្ច របស់ Mankiw (2010) និងហិរញ្ញវត្ថុសាធារណៈ របស់ Harvey (2005)។

យោងតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័ត និងប្រកាសឲ្យប្រើប្រាស់ក្នុងឆ្នាំ១៩៩៣ ក្នុងជំពូកទី៥ និងជំពូកទី៧ មានចែង និងលើកឡើងអំពីសេដ្ឋកិច្ច ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ហិរញ្ញវត្ថុសាធារណៈ សារពើពន្ធ និងថវិកាជាតិត្រង់មាត្រាទី៥៧ មាត្រាទី៩០ថ្មី និងមាត្រាទី៩១ថ្មីផងដែរ។ ការពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ និងសារពើពន្ធ ដែលរដ្ឋធម្មនុញ្ញបានចែងថា ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត។ ថវិកាជាតិត្រូវបានកំណត់ឲ្យអនុវត្តតាមច្បាប់ ហើយរបបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុត្រូវច្បាប់កំណត់។ រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចាលពន្ធដារ។ តំណាងរាស្ត្រមានសិទ្ធស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះ សំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ[23]។

## ២. ក្របខ័ណ្ឌច្បាប់ហិរញ្ញវត្ថុ និងសារពើពន្ធ

នៅក្នុងមេរៀនទី២ នៃសៀវភៅនេះ សិក្សាអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសារពើពន្ធ ដែលជាឆ្អឹងខ្នងនៃការសិក្សាហិរញ្ញវត្ថុសារណៈ នឹងត្រូវកំណត់ដោយច្បាប់ស្តីពីហរិញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់នានាដែលពាក់ព័ន្ធជាមូលដ្ឋាន។ មូលដ្ឋានគ្រឹះទី១. គឺកើតចេញពីរវាងសកម្មភាពរដ្ឋាភិបាល និងសកម្មភាពសេដ្ឋកិច្ច ហើយការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានទំនាក់ទំនងគ្នាទៅនឹងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចត្រូវបានចាត់ទុកថាជាប្រព័ន្ធ និងដំណើរការដែលចាំបាច់ដើម្បីប្រើប្រាស់ថវិការ គ្រោងថវិកា និងការប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព ដែលស្របនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រដ្ឋាភិបាល[24]។

ឧទាហរណ៍ដើម្បីសម្រេចបាននូវលទ្ធផលសារពើពន្ធ ឬការគ្រប់គ្រងចំណូល ចំណាយថវិការបស់រដ្ឋឲ្យមានប្រសិទ្ធភាពប្រកបដោយចីរភាព ឬដើម្បីអនុវត្តវិធានសារពើពន្ធ ដែលបានដាក់ចេញការគ្រងគ្រងចំណូលបានពីផលនៃផលិតផលក្នុងស្រុកសរុប ការគ្រង់គ្រងបំណុល ការខ្ចីប្រាក់របស់រដ្ឋាភិបាលជាដើម។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានប្រសិទ្ធិភាព ចាំបាច់ត្រូវគាំទ្រដោយក្របខ័ណ្ឌស្របច្បាប់ នៃបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងបទបញ្ញត្តិនានាដែលបានកំណត់ ថាតើដំណើរការថវិកា ការទទួលខុសត្រូវក្នុងការអនុវត្ត និងការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ។ មូលដ្ឋានគ្រឹះទី២. គឺស្ថាប័នសារពើពន្ធដែលត្រូវបានកំណត់ដោយច្បាប់ បទប្បញ្ញត្តិ និងវិធានផ្សេងៗ ដែលគ្រប់គ្រងដំណើរការថវិកា គឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបញ្ហាទាក់ទងនឹងនយោបាយសេដ្ឋកិច្ចនៃថវិកា និងហិរញ្ញវត្ថុសាធារណៈ ដើម្បីចាំបាច់ត្រូវវិភាគ និង

---

[23] សូមមើល ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[24] សូមមើល Musgrave (1989)។

ដាក់ជាយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ មូលដ្ឋានគ្រឹះទី៣ គឺទាក់ទងនឹងតួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័នរបស់ក្រសួង ស្ថាប័នដែលជាអ្នកអនុវត្តការប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈផ្ទាល់ ហើយមូលដ្ឋានគ្រឹះទី៤. គឺជាប់ទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់អង្គនីតិបញ្ញត្តិដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត លើហិរញ្ញវត្ថុសាធារណៈ និងក្នុងការត្រួតពិនិត្យសំណើដែលបានធ្វើ[25]។

ដូចនេះថាតើគោលនយោបាយសារពើពន្ធ មានឥទ្ធិពលលើលទ្ធផលម៉ាក្រូសេដ្ឋកិច្ច និងរបៀបដែលការពិចារណាម៉ាក្រូសេដ្ឋកិច្ច មានឥទ្ធិពលលើជម្រើសគោលនយោបាយសារពើពន្ធ។ ទំនាក់ទំនងរវាងគោលបំណងគោលនយោបាយសារពើពន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់។

ការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាំបាច់ត្រូវដឹងអំពីអន្តរកម្មទាំងនេះ ដើម្បីឲ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចប្រើប្រាស់ជំនួសក្នុងបរិបទគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ។ គោលនយោបាយសារពើពន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺប្រៀបដូចកាក់ដែលមានមុខពីរសងខាង ដែលមុខម្ខាងទាក់ទងនឹងវិធីសាស្ត្រ និងការរៀបចំគោលនយោបាយ ហើយមុខម្ខាងទៀត គឺទាក់ទងនឹងការអនុវត្តគោលនយោបាយ ដើម្បីឲ្យសម្រេចបាននូវគោលដៅសារពើពន្ធដាក់លាក់ក្នុងប្រទេស។

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំគ្រោង និងអនុញ្ញតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋដើម្បីបម្រើឲ្យរបៀបវារៈគោលនយោបាយ របស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្តពិសេសតាមរយៈការធានាឲ្យបាននូវតុល្យាភាពថវិកា។ ច្បាប់ហិរញ្ញវត្ថុហិរញ្ញវត្ថុប្រចាំឆ្នាំ វិភាជន៍ឥណទានទៅតាមក្រសួងស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងឲ្យឃើញផងដែរនូវថវិកាឧបសម្ព័ន្ធ និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅតាមប្រភេទចំណាយចរន្តនិងចំណាយមូលធន។ ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលទាំងនោះ ប្រមូលផ្តុំឥណទានទាំងអស់សម្រាប់បម្រើការងាររបស់ខ្លួននៅតាមរដ្ឋបាលថ្នាក់ជាតិ។ ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវវិភាជន៍ឥណទានដាកញ្ចប់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិកាត្រូវរៀបចំទៅតាមចំណាត់ថ្នាក់រដ្ឋបាលដែលផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ចំណាត់ថ្នាក់សេដ្ឋកិច្ច ដែលផ្អែកទៅលើប្រភេទចំណាយ ចំណាត់ថ្នាក់មុខងារដែលផ្អែកទៅលើគោលបំណង និងចំណាត់ថ្នាក់តាមកម្មវិធី (មាត្រទី១២)។ ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ស្ថាប័ននីតិបញ្ញត្តិ បានអនុម័តច្បាប់ថវិការ ដែលជាសេចក្តីថ្លែងការណ៍មួយស្តីអំពីផែនការចំណូល និងចំណាយរបស់រាជរដ្ឋាភិបាលសម្រាប់រយៈពេលមួយឆ្នាំ។ ថវិកានេះបានមកពីចំណូលពន្ធដារ ថ្លៃឈ្នួល ជំនួយបរទេស និងពីប្រភពផ្សេងៗទៀត។

[25] ដូចលេខ 24។

ថវិកានេះត្រូវប្រើប្រាស់សម្រាប់ចំណាយប្រតិបត្តិការរបស់រដ្ឋាភិបាលតួយ៉ាងដូចជាចំណាយលើការបើកប្រាក់ខែរបស់មន្ត្រីរាជការតាមក្រសួង ស្ថាប័នសាធារណៈ ប្រាក់ឧបត្ថម្ភ ប្រាក់សោធននិវត្តន៍ ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមគ្រប់ប្រភេទ និងការផលិតទំនិញសាធារណៈការផ្តល់សេវាសាធារណៈ ជាដើម ដែលប្រភេទ នៃការចំណាយទាំងនេះ ជាផលប្រយោជន៍សាធារណៈ ឬសង្គម និងមានឥទ្ធិពលដល់សុខុមាលភាពប្រជាជនកម្ពុជាគ្រប់រូប ក៏ដូចប្រទេសជាតិទាំងមូលផងដែរ។

ជាទូទៅហិរញ្ញវត្ថុសាធារណៈ បានលើកឡើងអំពីគោលការណ៍បីនៃហិរញ្ញវត្ថុ ហើយគោលការណ៍ទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីសម្រេចគោលបំណង ដូចមានការលើកមកបង្ហាញ និងវិភាគក្នុងមេរៀនទី១។

## ៣. សិទ្ធិអំណាច និងការទទួលខុសត្រូវ

យោងតាមច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០០៨ សិទ្ធអំណាចរបស់រដ្ឋាភិបាលរឹងមាំ ដោយសារមានការកំណត់ដោយច្បាប់ ហើយរដ្ឋាភិបាលត្រូវតែរៀបចំក្របខ័ណ្ឌច្បាប់ បែបបទគតិយុត្តិ វិធាន និងច្បាប់ស្តីអំពីហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ ឬច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឲ្យបានរឹងមាំ និងរួចស្រេចល្អជាមុន ដើម្បីអាចពិនិត្យពីភាពរារាំង ផលវិបាក បញ្ហា ភាពស្មុគស្មាញ និងឧបសគ្គនានាដែលកើតមាន និងជួបប្រទះ ហើយដើម្បីងាយស្រួលធ្វើជាមូលដ្ឋានដោះស្រាយ និងបំពេញគោលបំណងសង្គម និងសេដ្ឋកិច្ច។ ទាំងនេះមានន័យថា រដ្ឋាភិបាលគួរតែមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ពេញលេញ និងឯករាជ្យដើម្បីធានាចំណាយ មានធនធានបម្រុងសម្រាប់ហិរញ្ញប្បទាន និងអាចធានានិរន្តរភាពចំណាយ ដែលមានចែងក្នុងក្របខ័ណ្ឌគតិយុត្តិ និងច្បាប់ហិរញ្ញវត្ថុសាធារណៈ ដើម្បីបំពេញការងារ និងសម្មភាពរបស់ក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល។ ម៉្យាងទៀតរដ្ឋាភិបាលគួរតែមានភាពឯករាជ្យ និងការទទួលខុសត្រូវ នៃការដោះស្រាយបញ្ហាហិរញ្ញវត្ថុសាធារណៈ តាមរយៈការទទួលខុសត្រូវក្នុងការកំណត់ពន្ធ ការប្រមូលពន្ធ ការប្រមូលបំណុល កម្ចីសម្រាប់ ហិរញ្ញប្បទាន និងការគៀគរប្រភពចំណូលផ្សេងៗទៀត ដើម្បីធានាដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិដោយរលូន រក្សាស្ថិរភាពផ្ទៃក្នុង និងផ្ទៃខាងក្រៅ និងធ្វើឲ្យមានតុល្យភាពវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ចក្នុងប្រទេស ។

សិទ្ធអំណាច និងការទទួលខុសត្រូវត្រង់ផ្នែកទី២ ដែលមានចែកក្នុងមាត្រាទី៣៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណាយ ការខ្ចី ការឲ្យខ្ចី និងការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំ ការអនុវត្ត ការតាមដាន និងការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងរយៈពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា (មាត្រាទី៣៥)។

លើសពីនេះទៅទៀត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ការរៀបចំសេចក្ដីព្រាងច្បាប់ ហិរញ្ញវត្ថុ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ការគោរពច្បាប់ហិរញ្ញវត្ថុ ព្រមទាំងធានាការត្រួតពិនិត្យជាប្រចាំលើការគ្រប់គ្រងថវិកា។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារកិច្ចផ្ដល់របាយការណ៍អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថានភាពហិរញ្ញវត្ថុសាធារណៈជូនរដ្ឋសភា និងព្រឹទ្ធសភាពីរដងក្នុង១ឆ្នាំ គឺនៅរយៈពេលពិភាក្សាអនុម័តសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងនៅពាក់កណ្ដាលឆ្នាំ។ ស្រដៀងគ្នានេះដែរ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភាអំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងអំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈនាពេលបច្ចុប្បន្ន និងព្យាករណ៍សម្រាប់រយៈពេលមធ្យម (មាត្រាទី ៣៦។ រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងថវិកា និងការត្រួតពិនិត្យការអនុវត្តថវិការបស់ខ្លួន ជាពិសេសត្រូវមានគណនេយ្យភាពចំពោះការកំណត់ និងលទ្ធផលនៃការអនុវត្តគោលនយោបាយ នៅក្នុងវិស័យរបស់ខ្លួនដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងផ្នែកទី៣ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រង់មាត្រាទី៦៦ បានចែងថា រដ្ឋមន្ត្រីប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ព្រមទាំងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានតាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិការបស់ខ្លួន។ ចំពោះការប្រមូលចំណូល និងការអនុវត្តចំណាយ ត្រូវគោរពទៅតាមព្រំដែននៃសិទ្ធអំណាចរបស់ខ្លួន ដែលច្បាប់បានកំណត់។ ហើយត្រង់មាត្រាទី៦៧ និងមាត្រាទី៦៨ បានបង្ហាញយ៉ាងច្បាស់ថា ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយគត់ដែលមានសិទ្ធក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណងការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា និងការសន្យាផ្នែកហិរញ្ញវត្ថុនានា និងមានសិទ្ធិក្នុងការឲ្យប្រាក់គេខ្ចីទាំងក្នុង និងក្រៅប្រទេស។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមន្ត្រីសាធារណៈណាមួយ មានសិទ្ធក្នុងការខ្ចីប្រាក់ពីគេ ឬឲ្យប្រាក់គេខ្ចី ឬចេញជាលិខិតធានា ឬក៏ធ្វើទង្វើណាផ្សេងៗទៀតដោយផ្ទាល់ ឬដោយប្រយោល ដែលនាំឲ្យកើតមាននូវបំណុល ឬបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀតដោយផ្ទាល់ ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជា។ ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេ ឬបំណុលដែលគេជំពាក់រដ្ឋ។ ការរៀបចំកម្មវិធីដោះស្រាយបំណុលត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។

បន្ថែមពីលើនេះត្រង់មាត្រាទី៦៩ និង៧០ បានចែងថា ល័ក្ខខ័ណ្ឌហិរញ្ញវត្ថុ និងទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេនៃការឲ្យប្រាក់គេខ្ចី នៃការបោះផ្សាយមូលបត្ររដ្ឋ នៃការធានា និងនៃការសន្យាផ្នែក

ហិរញ្ញវត្ថុនានាត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈ និងណែនាំក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ស្ថាប័នថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ត្រូវគោរពតាមច្បាប់អនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំទាំងឡាយ ស្តីពីលទ្ធកម្មសាធារណៈ។

ត្រង់ផ្នែកទី២ មាត្រាទី៨៣ នៃសិទ្ធិអំណាច និងការទទួលខុសត្រូវ គណនេយ្យករសារជារណៈត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណនេយ្យករសាធារណៈមានអំណាចពិសេសរបស់ខ្លួន។ មុខចូលកាន់តំណែង គណនេយ្យករសាធារណៈ ត្រូវតែធ្វើសច្ចាប្រណិធានជាផ្លូវការតាមបែបបទត្រឹមត្រូវនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច។ អាណាប័កដើមខ្សែ និងអណាប័កផ្ទេរសិទ្ធិព្រមទាំងគណនេយ្យករសាធារណៈដទៃទៀត ត្រូវទទួលស្គាល់គណនេយ្យករសាធារណៈ ដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហើយគណនេយ្យករសាធារណៈទទួលបន្ទុកប្រមូលចំណូល ទូទាត់ចំណាយរក្សាទុកដាក់មូលនិធិមូលបត្រ ផលិតផល និងសម្ភារៈដែលជាកម្មសិទ្ធរបស់ស្ថាប័នសាធារណៈ។ មានតែគណនេយ្យករសាធារណៈមួយគត់ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តប្រតិបត្តិការទាំងឡាយ និងដោះស្រាយបញ្ហាមូលនិធិពាក់ព័ន្ធដទៃទៀតជាមួយចំណូល និងចំណាយ។ ក្នុងសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈ មានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជាប្រាក់កាស ដែលមានចែងក្នុងមាត្រាទី៨២ នៃសិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈនេះ។ រាល់ការអនុវត្តចំណូល និងចំណាយនៃថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រាល់ការកត់ត្រា ចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគោរពទៅតាមប្លង់គណនេយ្យ និងមាតិកាថវិកា ហើយរាល់របាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុត្រូវតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ (មាត្រាទី៨៤)។ រាល់ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាន និងទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំទូទាត់ថវិកាប្រចាំឆ្នាំ (មាត្រាទី៨៤)។

ចំពោះទោសប្បញ្ញត្តិ គឺថាមន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈដែលបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងៗទៀត។ ក្នុងករណីរបស់មន្ត្រីសា ធារណៈនោះ បានធ្វើឲ្យមានការបាត់បង់ប្រាក់កាស ឬខូចខាតទ្រព្យសម្បត្តិសាធារណៈ នោះតម្លៃ

នៃការបាត់បង់ ឬការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់នេះ នឹងក្លាយជាបំណុលចំពោះមន្ត្រីសាធារណៈនោះ ដែលត្រូវសង និងបង់ចូលថវិការដ្ឋវិញ។

## ៤. ច្បាប់ហិរញ្ញវត្ថុ

យោងតាមមាត្រាទី៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលថ្នាក់ជាតិ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលដែលជាមន្ត្រីសាធារណៈ និងប្រតិបត្តិករនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល ត្រូវប្រកាន់ខ្ជាប់នូវមូលដ្ឋាននៃគោលការណ៍បូរណភាព សមាគតភាព និងសង្គតិភាព គណនេយ្យភាព តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំវិសាលភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល និងគោលការណ៍គន្លឹះទាំង១១យ៉ាងនៃថវិកា ដែលត្រូវអនុវត្តដាច់ខាត គឺមានដូចជា ១. ភាពជាអាជ្ញា ២. ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ៣. ភាពគ្រប់ជ្រុងជ្រោយ ៤. ឯកត្តភាព ៥. សកលភាព ៦. វិសេសភាព ៧. តុល្យភាព ៨ គណនេយ្យភាព ៩. តម្លាភាព ១០. ស្ថិរភាព និង១១. សមិទ្ធកម្ម (មាត្រាទី៥) ។ ដើម្បីជានាការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិ នៃច្បាប់ពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ត្រូវចេញអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និងសារាចរណែនាំដោយរាជរដ្ឋាភិបាលព្រមទាំងប្រកាស និងសារាចរណែនាំផ្សេងៗទៀតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហើយក្រៅពីអ្វីដែលមានចែងក្នុងច្បាប់នេះ របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុនៃច្បាប់ដោយឡែក។

## ៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំណុះរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដោយច្បាប់ដែលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានកំណត់ដោយអនុក្រឹត្យ[26]។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការតាមការចាំបាច់។ រដ្ឋមន្ត្រីទទួលបន្ទុកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានជ្រើសរើសដោយនាយករដ្ឋមន្ត្រី និងតែងតាំងដោយព្រះមហាក្សត្រក្សត្រ។ ជាងនេះទៅទៀត ក្នុងដែនសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួមមានការរៀបចំបេសកម្មនិងរចនាសម្ព័ន្ធ ការរៀបចំមុខងារនិងភារកិច្ច ការធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ការបង្កើតប្រព័ន្ធហិរញ្ញវត្ថុឯកភាពទូទាំងប្រទេស ការរៀបចំនិងការអនុវត្តថវិកាជាតិ ការបែងចែកនិងចែកចាយចំណូលជាតិ ការធ្វើអធិការកិច្ចលើហិរញ្ញវត្ថុសាធារណៈ និងការតាមដានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយ កម្មវិធី និងនយោបាយពាក់ព័ន្ធផ្សេងៗ របស់រាជរដ្ឋាភិបាល។ ដើម្បីបំពេញភារកិច្ចនេះ

---

[26] សូមមើល ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ១៩៩៦។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរៀងចំជាអគ្គនាយកដ្ឋាន និងនាយកដ្ឋាន រាប់បញ្ចូលទាំងបណ្តាអង្គភាពមូលដ្ឋានមួយចំនួនដូចជា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត សាខាគយ និងរដ្ឋាការរាជធានី-ខេត្តជាដើម។

## ៥.១. តួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

យោងតាមអនុក្រឹត្យលេខ៤៨៨ អនក្រ.បកចុះថ្ងៃទី១៦ ខែតុលាឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋាន ដោយគ្របដណ្តប់លើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឲ្យរាជរដ្ឋាភិបាល លើបេសកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើនជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម។ បេសកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំ និងការអនុវត្តឲ្យបានត្រឹមត្រូវនូវគោលនយោបាយក្របខ័ណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និងឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់ និងបទបញ្ញាពាក់ព័ន្ធផ្សេងៗទៀត[27]។ ក្នុងមាត្រាទី៥ នៃអនុក្រឹត្យលេខ៤៨៨ នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រង និងសម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពង្រឹងអភិបាលកិច្ចល្អ ទៅលើអ្វីដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- វិភាគតាមដាន និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង និងដាក់ចេញនូវវិធានការ ដើម្បីតម្រង់ទិស និងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច
- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ និងចូលរួមក្នុងការរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល លើកិច្ចការសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកិច្ចការសមាហរណកម្មកម្ពុជា ទៅក្នុងសេដ្ឋកិច្ចពិភពលោក ជាពិសេសកិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ក្នុងក្របខ័ណ្ឌអាស៊ាន

---

[27] សូមមើល ក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០១៣។

- កសាងប្រព័ន្ធហិរញ្ញវត្ថុឲ្យឯកភាពទូទាំងប្រទេស ហើយធានាអនុវត្តប្រព័ន្ធនេះ ឲ្យបានត្រឹមត្រូវ តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ព្រមទាំងច្បាប់ពាក់ព័ន្ធ និងបទបញ្ញាដទៃទៀត
- ធ្វើការបែងចែក និងបែងចែកឡើងវិញ នូវផលទុនជាតិ តាមរយៈការប្រមូលចំណូល និងកម្មវិធីនីយកម្ម និងថវិកានីយកម្មនៃការចំណាយសាធារណៈ
- រៀបចំ និងកសាងសេចក្តីព្រាងច្បាប់ និងបទបញ្ញាផ្សេងៗ សម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬជាលក្ខណៈអចិន្ត្រៃយ៍
- រៀបចំ និងគ្រងគ្រងថវិការដ្ឋ
- រៀបចំ និងអនុវត្តគោលនយោបាយចំណូលថវិកាជាតិ
- ប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និងវិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ
- គ្រងគ្រងទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមកសាង និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្តកៀរគរហិរញ្ញប្បទានពីក្រៅប្រទេស និងទទួលបន្ទុកគ្រប់គ្រងបំណុលសាធារណៈ
- ចូលរួមរៀបចំគោលនយោបាយ និងគ្រប់គ្រងកិច្ចការវិនិយោគ
- ពិនិត្យ និងចុះទិដ្ឋាការលើការចំណាយរបស់ក្រសួង និងស្ថាប័នរដ្ឋនានា
- គ្រងគ្រង និងត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈ នៃបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពរដ្ឋដទៃ និងដៃគូឯកជនសាធារណៈ
- ទទួលបន្ទុកដឹកនាំ រៀបចំ ជំរុញអនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- វិភាគ គ្រប់គ្រង និងតាមដានការវិវត្តនៃវិស័យហិរញ្ញវត្ថុ ព្រមទាំងចូលរួមរៀបចំ និងអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យនៃវិស័យហិរញ្ញវត្ថុ ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ
- អភិវឌ្ឍ គ្រប់គ្រង និងត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុ រួមមានកិច្ចការធានារ៉ាប់រង និងសោធនទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ
- ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- គ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មភ្នាល់គ្រប់ប្រភេទ
- ធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ
- បំពេញមុខងារជាបេឡា និងគណនេយ្យករសាធារណៈ របស់រាជរដ្ឋាភិបាល ព្រមទាំងរៀបចំគោលការណ៍ និងបទបញ្ញាគណនេយ្យករសាធារណៈ

- បំពេញមុខងារសវនកម្មផ្ទៃក្នុង
- បណ្តុះបណ្តាល និងធ្វើវិក្រឹតការជាប្រចាំនូវមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដល់មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- អនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ៥.២. រចនាសម្ព័ន្ធថ្នាក់កណ្តាល

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គលេខាធិការរងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។ អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។ អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយរងមួយចំនួនជាជំនួយការ។ នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។ វិទ្យាស្ថានដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួន ដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។ ដូចនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរចនាសម្ព័ន្ធថ្នាក់កណ្តាលដែលត្រូវបែងចែកចំនួន១៣ប្រអប់ ដូចខាងក្រោម៖

១. ខុទ្ទការល័យរដ្ឋមន្ត្រី
២. អគ្គលេខាធិការដ្ឋាន
៣. អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤. អគ្គនាយកដ្ឋានថវិកា
៥. អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
៦. អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
៧. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
៨. អគ្គនាយកដ្ឋានពន្ធដារ
៩. អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
១០. អគ្គនាយកដ្ឋានរតនាគារជាតិ
១១. អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
១២. អគ្គាធិការដ្ឋាន
១៣. អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

### ៥.៣. រចនាសម្ព័ន្ធថ្នាក់មូលដ្ឋាន

អង្គភាពមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយរូបដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។ ដូចនេះរចនាសម្ព័ន្ធថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួមមាន ដូចខាងក្រោម៖

១. មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត

២.សាខាគយ និងរដ្ឋាករាជធានី ខេត្ត ការិយាល័យគយ និងរដ្ឋាករត្រួតពិនិត្យបែបបទគយ និងបណ្តាការិយាល័យគយ និងរដ្ឋាករដទៃទៀត។

៣. សាខាពន្ធដារខេត្ត ខណ្ឌនានា នៃរាជធានី និងស្នាក់ការពន្ធដារក្រុង ស្រុក

៤. រតនាគាររាជធានី ខេត្ត។

## ៦. ធនាគារកណ្តាល

យោងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ធនាគារជាតិនៃកម្ពុជា ហៅថាធនាគារកណ្តាល គឺជាស្ថាប័នស្វ័យតសាធារណៈ មានលក្ខណៈជាពាណិជ្ជកម្ម និងឧស្សាហកម្ម[28]។ ធនាគារកណ្តាល គឺជានីតិបុគ្គលមានសមត្ថភាពគតិយុត្តិពេញលេញ ហើយដើរតួជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា ។ បេសកកម្មចម្បងរបស់ធនាគារជាតិ នៃកម្ពុជាគឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅបង្កលក្ខណៈងាយស្រួល រួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យរីកចំរើន ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។ ធនាគារកណ្តាលមានសិទ្ធចេញប្រកាស បទបញ្ជា សារាចរ និងសេចក្តីណែនាំផ្សេងៗទៀត ដើម្បីបំពេញបេសកម្មរបស់ខ្លួន ហើយធនាគារកណ្តាលត្រូវចេញផ្សាយជាប្រក្រតីនូវគោលនយោបាយរូបិយវត្ថុ ដែលរួមមាន រូបិយវត្ថុ ឥណទាន ការប្តូរប្រាក់ អត្រាការប្រាក់ និងស្ថិតិទាក់ទងជាអាទិ៍ដល់បរិមាណរូបិយវត្ថុ ថ្លៃ ឥណទាន ជញ្ជីងទូទាត់ និងការប្តូរប្រាក់។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជា មានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀល ដែលជារូបិយវត្ថុជាតិ ។ ធនាគារជាតិនៃកម្ពុជា ជាអ្នករក្សាស្ថិរភាពរូបិយវត្ថុ។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា ជាអ្នកផ្តល់ និងដកហូតអាជ្ញាប័ណ្ណចេញបទប្បញ្ញត្តិ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រចាំចេញផ្សាយ របាយការណ៍

[28] សូមមើល ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាឆ្នាំ១៩៩៦។

និងព្រឹត្តបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ ដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រង បំណុល និងឥណទេយ្យក្រៅប្រទេស ។

## ៦.១. តួនាទី មុខងារ និងភារកិច្ចរបស់ធនាគារកណ្តាល

ធនាគារជាតិនៃកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចទៅតាមដំណាក់កាលផ្សេងៗគ្នាជាបន្តបន្ទាប់ ដោយផ្តើមពីការស្តារខឿនសេដ្ឋកិច្ចជាតិឡើងវិញ បន្ទាប់ពីការបំផ្លិចបំផ្លាញស្ទើរគ្មានសល់ក្នុងអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម តាមរយៈការគ្រងគ្រងដំណាក់កាលអន្តរកាលមួយ ដែលចេញពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារ និងបច្ចុប្បន្នបានកសាងប្រព័ន្ធធនាគារនិង ហិរញ្ញវត្ថុទំនើបមួយសម្រាប់កម្ពុជា។ ដំណាក់កាលសំខាន់ៗទាំងនេះ គឺមិនអាចសម្រេចទៅបានដោយគ្មានការខិតខំបំពេញតួនាទី មុខងារ ភារកិច្ច ការលះបង់ និងការតាំងចិត្តខ្ពស់របស់ធនាគារជាតិនៃកម្ពុជាឡើយ។ ដូចនេះធនាគារកណ្តាលមានមុខងារ និងភារកិច្ចដូចខាងក្រោម៖

១. កំណត់គោលដៅនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។

២. ត្រិះរិះរក អនុវត្ត និងត្រួតពិនិត្យនយោបាយរូបិយវត្ថុ និងប្តូរប្រាក់ឲ្យសម្រេចទៅតាមគោលដៅដែលបានកំណត់។

៣. ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតី រួចចេញផ្សាយលទ្ធផលហើយលើកសំណើ និងវិធានការជូនរាជរដ្ឋាភិបាល។

៤. ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានឯទៀតដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើមព្រមទាំងចេញបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ។

៥. ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាព នៃការទូទាត់អន្តរធនាគារ។

៦. ទទួលភារកិច្ចផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

៧. ទទួលខុសត្រូវ និងអនុវត្តក្នុងនាម នៃព្រះរាជាណាចក្រកម្ពុជា នូវកិច្ចការទាំងឡាយដែលជាលទ្ធផល នៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ជាមួយស្ថាប័នអន្តរជាតិសាធារណៈក្នុងកិច្ចការធនាគារ ឥណទានរូបិយវត្ថុ។

៨. តម្លើងតារាងជញ្ជីងទូទាត់។

៩. ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យប្រទេសក្រៅ។

១០. ចូលរួមក្នុងការបង្កើត និងការត្រួតពិនិត្យទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុ។

១១. ផ្ដល់ ឬដកហូតអាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានដែលបានចូលរួម ក្នុងអាជីវកម្មទីផ្សារប្ដូរប្រាក់ សង្ការឹម ប័ណ្ណត្បូងថ្ម និងលោហធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ។

១២. កំណត់អត្រាការប្រាក់

ដើម្បីបំពេញបេសកម្មរបស់ខ្លួន ធនាគារកណ្ដាល ក្នុងឋានៈជាអ្នកទទួលនូវសិទ្ធិអចិន្ត្រៃយ៍ពីរាជរដ្ឋាភិបាលមានស្វ័យភាពក្នុងការគ្រប់គ្រង តែត្រូវធ្វើរបាយការណ៍ ស្ដីពីការអនុវត្តភារកិច្ច និងលទ្ធផលដែលសម្រេចបានជូនរាជរដ្ឋាភិបាល។ នៅដំណាច់ឆមាសនីមួយៗ ធនាគារកណ្ដាលត្រូវដាក់ជូនរដ្ឋសភា និងរាជរដ្ឋាភិបាលនូវរបាយការណ៍ដោយៈ

- វាយតម្លៃនូវគោលធំៗនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា និងរៀបរាប់អំពីនយោបាយរូបិយវត្ថុ និងនយោបាយប្ដូរប្រាក់ដែលធនាគារកណ្ដាលត្រូវអនុវត្តតាមឆមាសបន្ទាប់ ឬក្នុងរយៈពេលវែងជាងនេះ។
- ពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តនយោបាយរូបិយវត្ថុ និងនយោបាយប្ដូរប្រាក់ដែលមានចែងក្នុងរបាយការណ៍ឆមាសមុន។

ធនាគារកណ្ដាលត្រូវកាន់កាប់បញ្ជីគណនេយ្យ និងបញ្ជីផ្សេងៗទៀត ហើយត្រូវកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងដោយប្រាកដប្រជានូវស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនស្របទៅតាមគោលការណ៍ និងបែបបទគណនេយ្យ ដែលត្រូវបានទទួលស្គាល់ជាទូទៅ សម្រាប់ធនាគារកណ្ដាល។ ត្រង់មាត្រាទី៥៧ថ្មី ការត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុ របស់ធនាគារកណ្ដាល ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ។

## ៦.២. សម្ព័ន្ធការផ្ទេរហិរញ្ញវត្ថុជាមួយអង្គភាពសាធារណៈ

យោងតាមមាត្រាទី៨ ធនាគារកណ្ដាលអាចបើកគណនីឲ្យស្ថាប័នរដ្ឋ ឬអង្គភាពរដ្ឋបាលកណ្ដាលដូចជារតនាគារជាតិជាដើម។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានការអនុញ្ញាតពីធនាគារកណ្ដាលឲ្យធ្វើអាជីវកម្ម។ ធនាគារកណ្ដាលបរទេស និងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ។ ធនាគារកណ្ដាលមិនអាចបើកគណនីឲ្យសហគ្រាសឧស្សាហកម្ម ឬពាណិជ្ជកម្មបានទេ ទោះជារបស់រដ្ឋក៏ដោយ។ សម្ព័ន្ធការផ្ទេរហិរញ្ញវត្ថុជាមួយអង្គភាពសាធារណៈគឺ យោងតាមមាត្រាទី ២១ និងមាត្រាទី២២ បានកំណត់ថា ធនាគារកណ្ដាលទទួលប្រាក់បញ្ញើផ្ដាច់មុខ ជារូបិយវត្ថុជាតិពីរតនាគារជាតិ។ ធនាគារកណ្ដាលទទួលបានប្រាក់ពីរតនាគារជាតិ ហើយចេញជួសនូវទឹកប្រាក់ ដែលរតនាជាតិត្រូវចំណាយ។ ធនាគារកណ្ដាលត្រូវកំណត់ជាមួយនឹងរតនាគារជាតិនូវកម្រៃ ដែលត្រូវបង់ជូនធនាគារកណ្ដាល លើរាល់ប្រតិបត្តិការដែលត្រូវអនុវត្ត។ ចំពោះចំណូលជារូបិយប័ណ្ណរបស់រតនាគារជាតិត្រូវលក់ឲ្យធនាគារកណ្ដាល ហើយធនាគារកណ្ដាលត្រូវបញ្ចូលទឹកប្រាក់ជារៀល ក្នុងគណនីតែមួយរបស់

រតនាគារជាតិ ដោយគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃ។ ដោយឡែកទៀត គឺធនាគារកណ្តាលជាទីប្រឹក្សារបស់រាជរដ្ឋាភិបាលក្នុងវិស័យរូបិយវត្ថុ និងហិរញ្ញវត្ថុ។ ធនាគារកណ្តាលមានភារកិច្ច ក្នុងកិច្ចការផ្តល់ព័ត៌មាន និងយោបល់ជូនរាជរដ្ឋាភិបាលអំពីបញ្ហាទាំងឡាយ ដែលមានអានុភាពក្នុងការធ្វើឲ្យសម្រេចគោលដៅនយោបាយ នៃហិរញ្ញវត្ថុ។

ធនាគារកណ្តាលត្រូវជួយគ្រប់គ្រងក្នុងការខ្ចីប្រាក់របស់រាជរដ្ឋាភិបាល ឬអង្គភាពសាធារណៈ ដោយធ្វើប្រតិបត្តិការលើមូលប័ត្រជាអាទិ៍ ជូននយោបាលលើកាលបរិច្ឆេទនៃការបោះផ្សាយមូលប័ត្រ និងជំរុញទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុឲ្យរីកចម្រើន។ ធនាគារកណ្តាលអាចទទួលធ្វើជាអាណត្តិគាហករបស់រាជរដ្ឋាភិបាល ឬរបស់អង្គភាពសាធារណៈចំពោះប្រតិបត្តិការ ដោយការទិញ-លក់មូលប័ត្រដែលបោះផ្សាយដោយរាជរដ្ឋាភិបាល ឬអង្គភាពសាធារណៈ ព្រមទាំងកិច្ចការជាភ្នាក់ងារជាគណនេយ្យដើម្បីចុះបញ្ជី និងផ្ទេរនូវមូលប័ត្រនោះ និងដោយការទូទាត់សងដើមនិងការប្រាក់ព្រមទាំងកម្រៃផ្សេងៗលើមូលប័ត្រនោះ។ ម្យ៉ាងទៀតធនាគារកណ្តាល ត្រូវកំណត់ជាមួយរាជរដ្ឋាភិបាល ឬអង្គភាពសាធារណៈអំពីកម្រៃដែលត្រូវបង់ជូលធនាគារកណ្តាលលើរាល់ប្រតិបត្តិការ។

យោងតាមមាត្រាទី២៤ ធនាគារកណ្តាល មិនត្រូវផ្តល់ឥណទានដោយផ្ទាល់ ឬដោយប្រយោលដល់រាជរដ្ឋាភិបាលឡើយ ជាពិសេសដោយទិញយកមូលប័ត្រដែលបោះផ្សាយដំបូង ឬមូលប័ត្រដែលធានាដោយរាជរដ្ឋាភិបាល ឬអង្គភាពសាធារណៈ លើកលែងតែករណីស្របទៅនឹងបទបញ្ញត្តិនានាក្នុងជំពូកនេះ។ ធនាគារកណ្តាលអាចផ្តល់ឥណទានដែលមានកាលវសានមិនហួសពី ៣ខែ ជូនទៅរតនាគារជាតិដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទានៈ ទី១. រាល់ប្រតិបត្តិការឥណទានត្រូវមានកិច្ចព្រមព្រៀងរវាងធនាគារកណ្តាល និងអ្នកខ្ចីដែលត្រូវមានបញ្ជាក់ទឹកប្រាក់ឥណទាន កាលវសាន និងអត្រាការប្រាក់ ហើយទី២. ប្រតិបត្តិការឥណទានត្រូវធ្វើឲ្យមានយថាភាពដោយប្រគល់ជូនធនាគារកណ្តាលនូវមូលប័ត្ររដ្ឋដែលអាចធ្វើអន្តរការបាន និងទី៣. ចំនួនទឹកប្រាក់សរុបនៃឥណទាន និងមូលប័ត្រដែលមានស្របតាមមាត្រាទី២៤ នៃច្បាប់នេះ ក្នុងការិយបរិច្ឆេទនីមួយៗ មិនត្រូវឲ្យលើសពី១០ភាគរយ (ដប់ភាគរយ) នៃចំណុចធម្មតានៃថវិកាជាតិ ក្នុងការិយបរិច្ឆេទនាឆ្នាំមុនឡើយ ដោយមិនគិតជំនួយ និងចំណូលពីការលក់ទ្រព្យសម្បត្តិ (មាត្រាទី២៥)។

## ៧. សវនកម្មជាតិ

អាជ្ញាធរសវនកម្មជាតិ គឺជាស្ថាប័នសាធារណៈមួយ ដែលឯករាជ្យអំពីប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅ របស់រាជរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អគ្គសវនករត្រូវបានប្រគល់អំណាចជូនក្នុងការបំពេញសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យ

កិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាស្ថាប័នគ្រប់គ្រង ដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាល[29]។

ច្បាប់នេះក៏បានបង្កើតមុខងារសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងបណ្តាសហគ្រាសសាធារណៈផងដែរ ដោយយោងតាមអនុក្រឹតលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាល ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

ក្នុងការបំពេញបេសកម្មរបស់ខ្លួន និងដើម្បីអនុវត្តច្បាប់នេះអាជ្ញាធរសវនកម្មជាតិ មានសិទ្ធអំណាចចេញសេចក្តីសម្រេច បទបញ្ជា សារាចរ និងការណែនាំផ្សេងៗទៀត ហើយមានថវិកាដោយឡែករបស់ខ្លួនផ្តល់ដោយថវិកាជាតិ។ ការគ្រប់គ្រងចំណូល និងចំណាយនៃអាជ្ញាធរសវនកម្មជាតិត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ។

ក្នុងមាត្រាទី២នៃច្បាប់នេះបានចែងថា បណ្តាស្ថាប័នគ្រប់គ្រងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ រួមមានបណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារ រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀត ទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជនផងដែរ។

## ៧.១. តួនាទីសវនកម្មជាតិ

សវនកម្មផ្ទៃក្រៅ គឺជាការពិនិត្យពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីកាគណនេយ្យប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រង ដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាលដើម្បីផ្តល់ថា៖

- បណ្តាសកម្មភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈសេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍។
- បណ្តាសកម្មភាពទាំងនេះ ត្រូវបានអនុវត្តដោយអនុលោម តាមគោលការណ៍គណនេយ្យទូទៅ។
- ការត្រួតពិនិត្យនីតិវិធីនិងការអនុវត្តដោយអនុលោមតាមច្បាប់ បទបញ្ជា កិច្ចព្រមព្រៀងប្រព័ន្ធគ្រប់គ្រង កិច្ចសន្យា កម្មវិធី និងលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត ដែលទាក់ទងដល់ចំណូល ចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រាជរដ្ឋាភិបាល។

---

[29] សូមមើល ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០០។

ក្នុងករណីចាំបាច់តាមសំណើ របស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភា គណៈកម្មាធិការអេចិន្ត្រៃយ៍ក្នុងនាមនៃរដ្ឋសភាមានសិទ្ធិជ្រើសរើសសវនករពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ (មាត្រាទី៤០)។ ក្នុងករណីចាំបាច់តាមសំណើរបស់គណៈកម្មាធិការអេចិន្ត្រៃយ៍នៃរដ្ឋសភា រដ្ឋសភាអាចសម្រេចបង្កើតគណៈកម្មការពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសម្មភាពនិងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ ដែលត្រូវបំពេញបន្ថែមជាមាត្រាទី៤០ ក្នុងជំពូកទី៨ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

### ៧.២. ប្រភេទសវនកម្ម

ក្នុងច្បាប់នេះ សវនកម្មផ្ទៃក្រៅ រាប់បញ្ចូលនូវការអនុវត្តប្រភេទសវនកម្មដូចខាងក្រោម៖

១. សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

២. សវនកម្មលើការគ្រប់គ្រងកម្មវិធីគម្រោងឥណទាន ដែលបានទទួលពីមូលនិធិក្រៅប្រទេស។

៣. សវនកម្មលើប្រព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅលើបណ្តាស្ថាប័ន

៤. សវនកម្មលើការវាយតម្លៃ ការផ្តល់លទ្ធផលល្អ និងប្រសិទ្ធភាពក្នុងការអនុវត្ត។

៥. សវនកម្មលើអង្គការដែលមិនរកប្រាក់ចំណេញ សមាគមន៍ គណបក្សនយោបាយ និងសវនកម្មលើសហគ្រាសវិនិយោគឯកជន ដូចមានចែងក្នុងមាត្រាទី២នៃច្បាប់នេះ

៦. សវនកម្មតាមសំណើពិសេស។

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងៗទៀត ដែលសំណូមពរដោយភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និងបណ្តាឥណទាយក នៅក្នុងគម្រោងផ្តល់មូលនិធិពីក្រៅប្រទេស។ សវនកម្មនេះ ត្រូវបញ្ជាក់អំពីភាពសមស្រប និងភាពត្រឹមត្រូវនៃឯកសារយុត្តិការក្នុងការដកប្រាក់ និងការចំណាយលើគម្រោងនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុបង្ហាញនូវការសមស្របទៅនឹងល័ក្ខខ័ណ្ឌ នៃកិច្ចព្រមព្រៀងឥណទាន និងកិច្ចព្រមព្រៀងគម្រោង។ សវនកម្មនឹងបន្តបន្ថែមទៅទៀត លើការវាយតម្លៃចំពោះការសម្រេចគោលដៅ នៅពេលចប់គម្រោងទាំងនេះ (មាត្រាទី៦)។

សវកម្មលើប្រព័ន្ធត្រួតពិនិត្យនានា ដើម្បីរៀបចំនូវមតិលើភាពសមស្របគ្រប់ជ្រុងជ្រោយ ក្នុងការចាត់ចែងប្រព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅ ដែលបានបង្កើតឡើងដោយស្ថាប័នគ្រប់គ្រងលើសកម្មភាព និងកិច្ចប្រតិបត្តិការទាំងឡាយ (មាត្រាទី៧) ។ ក្នុងមាត្រាទី ៨ និងមាត្រាទី៩ បានបង្ហាញថា សវនកម្មលើមុខងារ ឬកិច្ចការកំពុងអនុវត្តរវាងស្ថាប័នគ្រប់គ្រង និងស្ថាប័នគ្រប់គ្រងដើម្បីជានាសកម្មភាពកិច្ចប្រតិបត្តិការ ដែលទាក់ទងដល់មុខងារនៅក្នុងបណ្តាស្ថាប័នគ្រប់គ្រង ឲ្យអនុវត្តគោរពតាមច្បាប់ បទបញ្ជា និងគោលការណ៍ទាំងឡាយកំពុងអនុវត្ត។ សវនកម្មនេះរាប់បញ្ចូលទាំងលទ្ធផលលទ្ធកម្មសាធារណៈ បៀវត្សបុគ្គលិក កិច្ចសន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបេសកម្ម។

សវនកម្មដើម្បីវាយតម្លៃអំពីការសន្សំសំចៃ ការផ្តល់ឲ្យនូវផលល្អ ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលទ្ធផលនៃកម្មវិធីរបស់រាជរដ្ឋាភិបាល។ សវនកម្មនេះ រាប់បញ្ចូលទាំងការពិនិត្យពិចារណាឡើងវិញនៃកិច្ចប្រតិបត្តិការរបស់បណ្តាស្ថាប័នសាធារណៈ ទោះជាស្ថាប័នហិរញ្ញវត្ថុ ឬមិនមែនស្ថាប័នហិរញ្ញវត្ថុក៏ដោយ(មាត្រាទី៩) ។

សវនកម្មលើការអនុវត្តស្របតាមបទបញ្ញត្តិជាធរមាន ក្នុងកិច្ចប្រតិបត្តិការរបស់អង្គការ ដែលមិនរកប្រាក់ចំណេញ សមាគម និងគណបក្សនយោបាយ ដែលបានទទួលជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលក្នុងទ្រង់ទ្រាយលើកលែងពន្ធគយ ពន្ធលើប្រាក់បៀវត្ស និងពន្ធអាករទៀត ព្រមទាំងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលពុំមានការអនុញ្ញាតដោយច្បាប់។ គោលដៅនៃសវនកម្មនេះ គឺដើម្បីកុំឲ្យរាជរដ្ឋាភិបាលត្រូវបានបាត់បង់ប្រាក់ចំណូល ដែលបណ្តាលមកពីការលើកលែងពន្ធ និងដើម្បីជានាស្ថាប័នគ្រប់គ្រងបានដំណើរការទៅតាមក្របខ័ណ្ឌនៃគោលបំណងរបស់ខ្លួន (មាត្រាទី១០)។

សវនកម្មលើការអនុវត្តស្របតាមបទបញ្ញត្តិជាធរមាន របស់សហគ្រាសវិនិយោគឯកជន ដែលបានទទួលការលើកលែងពន្ធ និងសម្បទានពីរាជរដ្ឋាភិបាល ដើម្បីធ្វើឲ្យអាជីវកម្មធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សវនកម្មទាំងនេះសង្កត់ធ្ងន់ទៅលើការអនុវត្តទៅតាមកិច្ចព្រមព្រៀម និងបណ្តាល័ក្ខខ័ណ្ឌ នៃការអនុញ្ញាតពីរាជរដ្ឋាភិបាល (មាត្រាទី១១) ។ សវនកម្មលើសេចក្តីថ្លែងការណ៍ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ដែលជាមូលដ្ឋានសម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល នៅដំណាច់ឆ្នាំនៃការិយបរិច្ឆេទដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលដាក់ជូនទៅអង្គភាពនីតិប្បញ្ញត្តិ។ សវនកម្មលើភាពត្រឹមត្រូវ ភាពពិតប្រាកដការយល់ព្រម ការធ្វើឲ្យមានសុពលភាព និងស្របតាមទិន្នន័យហិរញ្ញវត្ថុដូចមានបង្ហាញរបាយការណ៍របស់បណ្តាក្រសួង ស្ថាប័ន និងរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល។ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ អាជ្ញាធរ រួមមានតារាងតុល្យការ របាយការណ៍អំពីប្រាក់ចំណេញ ការខាតបង់ និងការវិភាគគណនីដែលជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។ សវនកម្មនេះក៏ត្រូវរាប់បញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសអាជីវកម្មនៅក្នុងបណ្តាក្រសួង ស្ថាប័ន ខេត្តក្រុង និងរដ្ឋបាលមូលដ្ឋានផងដែរ (មាត្រាទី៥)។

សវនកម្មតាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភា ឬរដ្ឋសភា ឬព្រឹទ្ធសភា ឬក្រសួង ឬស្ថាប័ននានា ឬអាជ្ញាធរសម្រាប់ធ្វើការត្រួតពិនិត្យពិសេសឡើងវិញលើវិស័យមួយផ្នែក ឬទាំងអស់នៃកិច្ចប្រតិបត្តិការរបស់ម្ចាស់សំណើ។ ការអនុវត្តនៃសវនកម្មដែលមានចែងក្នុងមាត្រានេះ គឺស្ថិតនៅលើឆន្ទានុសិទ្ធរបស់អគ្គសវនករ (មាត្រាទី ១២)។

## ៨. សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើងនៅតាមបណ្តាស្ថាប័ន ក្រសួងនិងសហគ្រាសសាធារណៈ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួន ហើយត្រូវផ្ញើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះទៅ អាជ្ញាធរសវនកម្មជាតិ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង ត្រូវបានកំណត់ដោយអនុក្រឹត្យ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងគឺជាដំណើរការរបស់រាជរដ្ឋាភិបាល ដែលធ្វើឡើងដោយថ្នាក់ដឹកនាំ ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ដើម្បីផ្តល់នូវការធានាភាពសមស្របលើសមិទ្ធកម្មនៃកម្មវត្ថុតាមបណ្តាផ្នែកខាងក្រោម៖

- ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ
- ភាពទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ
- ភាពសមស្របតាមបណ្តាច្បាប់ បទបញ្ញា គោលនយោបាយ នីតិវិធី និងការចាត់ចែងដែលត្រូវអនុវត្ត។

យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តា ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈចុះថ្ងៃទី ១៥ខែកុម្ភៈ ឆ្នាំ២០០៥ សវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងវាយតម្លៃសកម្មភាពរបស់អង្គភាព ដើម្បីជាជំនួយសម្រាប់ថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និងក្រុមប្រឹក្សាភិបាលរបស់សហគ្រាសសាធារណៈ។ ការធ្វើសវនកម្មផ្ទៃក្នុង គឺមានគោលដៅជួយដល់ផ្នែកនីមួយៗ នៃស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈខាងលើដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

## ៩. មុខងារ និងការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង

ថ្នាក់ដឹកនាំ ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈត្រូវទទួលខុសត្រូវលើការបង្កើត និងរក្សាឲ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ តួនាទីនៃសវនកម្មផ្ទៃក្នុង គឺត្រូវវាយតម្លៃដោយឯករាជ្យនូវភាពសមស្រប គ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងនេះ និងផ្តល់នូវការធានាលើភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យ ដែលកំពុងមាន និងកំពុងដំណើរការទៅតាមគោលបំណង។ ដើម្បីអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន សវនករផ្ទៃក្នុងត្រូវមានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ និងគ្មានការរារាំង ការហាមឃាត់ លើការចូលត្រួតពិនិត្យនូវគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រា រាល់ទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព។ គោលដៅចម្បងនៃសវនកម្មផ្ទៃក្នុង គឺផ្តល់ឲ្យ ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ នូវការវិភាគ ការវាយតម្លៃ អនុសាសន៍ មតិយោបល់ និងព័ត៌មានទាក់ទងនឹងសកម្មភាពដែលបានត្រួតពិនិត្យ និងពិនិត្យឡើងវិញ។

នៅក្នុងមាត្រាទី៧ នៃអនុក្រឹត្យនេះ មុខងារ និងការទទួលខុសត្រូវ របស់សវនកម្មផ្ទៃក្នុងមាន ដូចខាងក្រោម៖

- ពិនិត្យឡើងវិញលើមុខងារ សកម្មភាពកិច្ចប្រតិបត្តិ និងកម្មវិធីរបស់អង្គភាព ក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តឲ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យដោយផ្អែកតាមគោលការណ៍ណែនាំគោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព។
- កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព។
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់ នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រ ដែលប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណវាស់វែងចំណាត់ថ្នាក់ និងរាយការណ៍ អំពីព័ត៌មានទាំងនេះ។
- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានទៅតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ បទបញ្ជាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍។ ក្នុងករណីស្ថាប័ន ក្រសួង និងសហគ្រាសាធារណៈអនុវត្តពុំបានសមស្របដូចបានរៀបរាប់ខាងលើចាំបាច់សំណូមពរឲ្យមានការផ្លាស់ប្តូរ និងកែលម្អ។
- ត្រួតពិនិត្យឡើងវិញលើការគ្រប់គ្រងថែទាំ ការពារ និងផ្ទៀងផ្ទាត់សម្បត្តិដែលមានឲ្យបានត្រឹមត្រូវ។
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពលើការប្រើប្រាស់ធនធាន និងកំណត់ការកែលម្អលើការអនុវត្តកិច្ចប្រតិបត្តិការ និងផ្តល់អនុសាសន៍។
- ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយមូលធន លើលទ្ធផលការងារវិជ្ជមាន ឬអវិជ្ជមានតាមគោលបំណង គោលដៅដែលបានដាក់ចេញ និងតាមផែនការដែលបានកំណត់។
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗដើម្បីធានាឲ្យ៖

  ១.តម្រូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាសលាស់។

  ២.ការត្រួតពិនិត្យផ្ទៃក្នុងសមស្របត្រូវបានបញ្ចូលទៅក្នុងកុំព្យូទ័រ។

  ៣.ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រត្រូវបានប្រព្រឹត្តទៅក្នុងជំហានសមស្រប។

  ៤.ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ។
- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យ សំខាន់ៗក្រោយពេលតម្លើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះឆ្លើយតបតាម

គោលបំណង និងគោលដៅដែលបានគ្រោងទុកហើយទទួលបានលទ្ធផលមានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

- ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តដើម្បីធានាថាវិធានការបានដាក់ចេញក្នុងគោលបំណងការពារការកេងបន្លំ។ ប្រសិនបើមានការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបានទាន់ពេលវេលា។
- ពិនិត្យឡើងវិញ លើការអនុវត្តតាមគោលការណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលស្តីពីឥរិយាបថ និងក្រមសីលធម៌ចំពោះមន្ត្រីរាជការ។
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឲ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា។
- ធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួនហើយត្រូវផ្ញើររបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះទៅអាជ្ញាធរសវនកម្មជាតិស្តីពី៖

  ១.សកម្មភាពកែលម្អតាមអនុសាសន៍សំខាន់ៗរបស់សវនកម្មផ្ទៃក្នុង។

  ២.សកម្មភាពសវនកម្មត្រូវបានផ្តោតលើហានិភ័យ និងបង្កើនភាពសន្សំសំចៃប្រសិទ្ធភាព និងការផ្តល់លទ្ធផលល្អក្នុងកិច្ចប្រតិបត្តិការ។

  ៣.សវនកម្មផ្ទៃក្នុង ត្រូវធ្វើការសម្របសម្រួលការងារ ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីជៀសវាងការធ្វើសវនកម្មស្ទួនគ្នា។ ក្នុងករណីមានភាពមិនច្បាស់លាស់ អាជ្ញាធរសវនម្មជាតិអាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មសារឡើងវិញ។

  ៤.ផែនការសវនកម្មផ្ទៃក្នុងត្រូវមានភាពសមស្របច្បាស់លាស់ និងគ្រប់គ្រាន់។

  ៥.ការរារាំងលើព័ត៌មាន និងបញ្ជី។

- ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំត្រូវដាក់ជូនថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈពិនិត្យ និងសម្រេច។
- វាយតម្លៃផែនការ ឬសកម្មភាពកែលម្អ លើចំណុចរកឃើញរបស់សវនករផ្ទៃក្នុង។ ប្រសិនបើសកម្មភាពកែលម្អនេះមិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្តដើម្បីឲ្យសម្រេចបានតាមសំណូមពរដែលអាចទទួលយកបាន។
- ផ្តល់លទ្ធភាពសមស្របគ្រប់គ្រាន់ក្នុងការតាមដានសកម្មភាពកែលម្អលើអនុសាសន៍។
- ប្រធានសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ឬក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ
- ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវនកម្មផ្ញើជូនដល់ផ្នែកនីមួយៗរបស់ស្ថាប័នក្រសួង សហគ្រាសសាធារណៈដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍។ សវនកម្មផ្ទៃក្នុងត្រូវបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរសវនម្មជាតិ។

- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗដែលប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈប្រគល់ឲ្យ។

## ១០. រដ្ឋសភា

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ដែលបានចែងត្រង់មាត្រាទី១ នៃរដ្ឋធម្មនុញ្ញ។

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ហើយនីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ សម្លេងភាគច្រើនដាច់ខាត (ឬពាក់កណ្ដាលបូកមួយ) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ប្រើសម្រាប់អនុម័តច្បាប់ទាំងឡាយ អនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ បោះឆ្នោតទុកចិត្តលើរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ មិនត្រឹមតែប៉ុណ្ណោះត្រង់មាត្រាទី៩៥ និងមាត្រាទី ៩៧ រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋសភា និងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ហើយគណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន[30]។

### ១០.១. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាត្រង់ប្រការទី៥ ថ្មី (ពីរ) បានកំណត់ថា ក្រោយពីព្រះមហាក្សត្រ ឬព្រះរាជតំណាងបានបើកនីតិកាលរដ្ឋសភារួចហើយ ហើយបើអង្គសភាមានសមាជិកវត្តមានលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាអាចដំណើរការបន្តតាមរបៀបវារៈដូចមានចែងក្នុងប្រការទី២ ថ្មី (ពីរ)។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមាន

- ប្រធានរដ្ឋសភា
- អនុប្រធានទាំងពីរ នៃរដ្ឋសភា
- ប្រធានគណៈកម្មការនានា នៃរដ្ឋសភា

ប្រធានរដ្ឋសភាជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ហើយកូរ៉ុមសម្រាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិក ហើយគណៈកម្មាធិការ

[30] សូមមើល បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាឆ្នាំ២០១៧។

អចិន្ត្រៃយ៍រដ្ឋសភាមានអាណត្តិស្មើនឹងនីតិកាលរបស់រដ្ឋសភា។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាដែលបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចតទៅ៖

- ដឹកនាំចាត់ចែង និងពិនិត្យសម្រេចរាល់ការងារ សកម្មភាពផ្សេងៗរបស់រដ្ឋសភាក្នុងល័ក្ខខ័ណ្ឌកំណត់ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រមទាំងទទួលពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់នូវសេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ។
- ចាត់ចែងការងាររបស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា
- រៀបចំសមាសភាពលេខាធិការ បីរូប សម្រាប់សម័យប្រជុំបន្ទាប់ ដើម្បីដាក់ជូនអង្គប្រជុំនៃរដ្ឋសភាអនុម័ត
- ជានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា
- ជានាការគ្រប់គ្រង និងការចំណាយថវិការដ្ឋសភាឲ្យប្រព្រឹត្តទៅបានត្រឹមត្រូវតាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ជានាការផ្តល់គ្រឿងឥស្សរិយយសជូនដល់សមាជិករដ្ឋសភា
- ជានាការអនុវត្តវិន័យក្នុងរដ្ឋសភា
- លើកជូនរដ្ឋសភាអំពីករណីនៃការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភាដោយអនុវត្តតាមកថាខ័ណ្ឌទី៣ និងទី៤ នៃមាត្រាទី៨០ នៃរដ្ឋធម្មនុញ្ញ
- លើជូនរដ្ឋសភាពិនិត្យ និងសម្រេចលើការផ្អាកការឃុំខ្លួន ការចោទប្រកាន់ សមាជិករដ្ឋសភាណាមួយដោយសម្លេង បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល
- លើកជូនរដ្ឋសភាពិនិត្យ និងសម្រេចអំពីការលើកអភ័យឯកសិទ្ធិសភា ការប្រគល់ជូនវិញនូវអភ័យឯកសិទ្ធិ ការបោះបង់ចោលការងារ វិសមិតភាព និងការប្រាសចាកសមាជិកភាពរដ្ឋសភា ដោយសំលេង ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នករៀបចំរបៀបវារៈនៃពេលប្រជុំនីមួយៗ។ មុនផុតពេលប្រជុំនីមួយៗ ប្រធានអានរបៀបវារៈសម្រាប់ពេលប្រជុំបន្តទៅទៀត។ ក្នុរបៀបវារៈមានសេចក្តីជាលំដាប់មុខក្រោយ ដូចតទៅនេះ៖

- បញ្ហាទាំងឡាយដែលរដ្ឋសភាបានសម្រេចថាទុកជាការប្រញាប់
- បញ្ហាទាំងឡាយ ដែលរាជរដ្ឋាភិបាលជូនមករដ្ឋសភា
- បញ្ហាទាំងឡាយ ដែលគណៈកម្មការនានាជូនមករដ្ឋសភា
- បញ្ហាទាំងឡាយ ដែលសមាជិករដ្ឋសភាជូនមករដ្ឋសភា

បើក្នុងប្រភេទនីមួយៗមានបញ្ហាជាច្រើននោះរបៀបវារៈនៃបញ្ហាទាំងនោះត្រូវរៀបចំតាមលំដាប់កាលបរិច្ឆេទនៃការបញ្ជូនមកដល់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ។ ត្រង់ប្រការទី២១ (ថ្មី) បានកំណត់ថា សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ សេចក្តីព្រាងច្បាប់នោះធ្វើជាលាយលក្ខណ៏អក្សរ ហើយត្រូវ

ចែកជូនតំណាងរាស្ត្រទាំងអស់ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្តីព្រាងនោះទៅគណៈកម្មការនោះតាមមុខជំនាញឲ្យពិនិត្យ។ កាលបើពិនិត្យរួចហើយប្រធាននៃគណៈកម្មការនោះ ត្រូវនាំយកយោបល់គណៈកម្មការមកជម្រាបជូនរដ្ឋសភា។ ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅ (ប្រការទី២៩ ថ្មី)៖

- អង្គសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថាតើគួរទទួលពិចារណា ឬទេ។
- អង្គសភាពិភាក្សា និងអនុម័តលើមាត្រមួយៗក៏បាន ឬលើជំពូកមួយម្តងៗក៏បាន។ អង្គសភាអាចប្រើនីតិវិធីពិភាក្សាសង្ខេបបានដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ។ ក្នុងករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវជូនព័ត៌មានដល់អ្នកតំណាងរាស្ត្រជាមុន។
- អង្គសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល។

## ១០.២. គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភាមានភារកិច្ចរួមដូចតទៅ៖

- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានប្រគល់ជូន
- នាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គអំពីការពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់
- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ។ល។
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភា នៃបណ្តាប្រទេសដើម្បីពង្រឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិបញ្ញត្តិ
- ប្រធាន ឬប្រធានស្តីទីមានភារៈកិច្ចចូលរួមក្នុងការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភា
- សមាជិកគណៈផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងប្រធានរដ្ឋសភាប្រគល់។
- បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងប្រធានរដ្ឋសភាប្រគល់ជូន។

របៀបរបបធ្វើការងារ និងបែងចែកភារកិច្ចទទួលខុសត្រូវរបស់សមាជិកគណៈកម្មការនីមួយៗ ត្រូវបានកំណត់ដោយប្រធានគណៈកម្មការ។ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភាមានភារកិច្ចស្នូលសំខាន់ៗ ដូចខាងក្រោម៖

- ពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលពាក់ព័ន្ធនឹង វិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម និងលិខិតបទដ្ឋាននានា ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប្រគល់ជូន
- ធ្វើសេចក្តីរាយការណ៍ អំពីយោបល់របស់គណៈកម្មការក្នុងការពិនិត្យសិក្សាសចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងសម័យប្រជុំពេញអង្គរដ្ឋសភា
- ពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុ រួមមានច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ ច្បាប់ទូទាត់ថវិកា
- ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា តាមការអញ្ជើញរបស់គណៈកម្មការជំនាញ ឬ/និងគណៈកម្មការពិសេសចំពោះកិច្ច
- តាមដាន ត្រួតពិនិត្យលើការអនុវត្តច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
- ធ្វើរបាយការណ៍ស្តីពីលទ្ធផល នៃការត្រួតពិនិត្យតាមការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសវនកម្ម ជូនប្រធានរដ្ឋសភា
- ចូលរួមវេទិកាថ្នាក់ជាតិ និងវេទិកាអន្តរជាតិ ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ធនាគារ និងសវនកម្ម
- រៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់ពាក់ព័ន្ធនឹងការកសាងគោលនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
- ពិនិត្យ ស្រាវជ្រាវ លើរបាយការណ៍សវនកម្មរបស់អាជ្ញាធរសវនម្មជាតិ និងរៀបចំជាអនុសាសន៍ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងអគ្គសវនករ ស្តីពីការកែលម្អភាពមិនប្រក្រតី
- ចូលរួមពិនិត្យ ពិភាក្សាលើគម្រោងថវិការដ្ឋសភាប្រចាំឆ្នាំ ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាដើម្បីពិនិត្យ និងសម្រេច
- កសាងគោលការណ៍ បទដ្ឋាន នីតិវិធីប្រតិបត្តិការថវិកា និងសវនកម្ម និងត្រួតពិនិត្យកិច្ចប្រតិបត្តិការថវិការដ្ឋសភា ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងពិនិត្យសម្រេច
- អញ្ជើញរដ្ឋមន្ត្រី ឬរដជនណាមួយមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយ ដៃគូជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជនដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

- ចងក្រងឯកសារ ដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុក ទាំងឯកសារជាតិ និងឯកសាររបស់បណ្តាប្រទេស ដែលមានការអភិវឌ្ឍកម្រិតប្រហាក់ប្រហែល ឬខ្ពស់ជាង ដើម្បីធ្វើទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ និងជំរុញកិច្ចសហប្រតិបត្តិការជាផលប្រយោជន៍ជាតិ
- រួមចំណែកពង្រឹង និងពង្រីកការផ្សព្វផ្សាយច្បាប់ ការគោរពប្រតិបត្តិច្បាប់ និងលើកកម្ពស់ការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ
- លើកទឹកចិត្តឲ្យមានការចូលរួមដោយសកម្មភាពពីសំណាក់សាធារណជន ក្នុងវេទិកានានាសំដៅឆ្លើយតបទៅនឹងសំណូមពរ ព្រមទាំងផលប្រយោជន៍ស្របច្បាប់ របស់ប្រជាពលរដ្ឋ
- ទទួលពិនិត្យ សេចក្តីស្នើទាំងឡាយ និងសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ ដើម្បីលើកសំណើតាមរយៈប្រធានរដ្ឋសភា ជូនក្រសួងពាក់ព័ន្ធពិចារណា និងដោះស្រាយ។

### ១០.៣. ថវិការដ្ឋសភា

យោងតាមប្រការទី៣០ និងមាត្រាទី៣១ថ្មី (បី) នៃជំពូកទី៨ អំពីបញ្ញត្តិពិសេសសម្រាប់ថវិកាជាតិ និងថវិកាសម្រាប់រដ្ឋសភាបានបង្ហាញថា សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ត្រូវញែក និងបំបែកជាលំអិតឲ្យបានច្បាស់លាស់តាមការកំណត់ក្នុងច្បាប់ស្តីពីរបបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុ ដែលមានចែងក្នុងមាត្រាទី៥៧ នៃរដ្ឋធម្មនុញ្ញ។ រដ្ឋសភាមានថវិកាស្វ័យតសម្រាប់ដំណើរការ។ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដោយមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភាមានភារកិច្ចពិនិត្យ និងលើកយោបល់ ក្នុងគម្រោងថវិកាប្រចាំឆ្នាំ របស់រដ្ឋសភា ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យសម្រេច ហើយបញ្ជូនសេចក្តីស្នើថវិកានោះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់បញ្ចូលទៅក្នុងគម្រោងថិការជាតិតាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ រាល់ការចំណាយថវិការបស់រដ្ឋសភា ត្រូវមានតម្លាភាព និងធានាផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងសមធ៌មជូនដល់រដ្ឋសភា គណៈកម្មការនានារបស់រដ្ឋសភា ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ និងសមាជិករដ្ឋសភា។

បែបបទនៃការចំណាយថវិការដ្ឋសភា ត្រូវកំណត់ដោយសេចក្តីសម្រេចប្រចាំឆ្នាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ អគ្គលេខាធិការដ្ឋានរដ្ឋសភា ទទួលខុសត្រូវធ្វើរបាយការណ៍ចំណាយថវិការដ្ឋសភានៅរាល់ ៦ខែម្តង និងក្នុងរាល់ដំណាច់ឆ្នាំ និងដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យសម្រេចក្រោយពីមានការវាយតម្លៃ និងសេចក្តីសន្និដ្ឋានពីគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រមទាំងមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភាផង លើក

លែងតែរបាយការណ៍ទូទាត់ថវិកាដំណាច់ឆ្នាំ ក្រោយពីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យសម្រេចហើយ ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំបញ្ចូលក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ។

## ១១. កំណត់កំណើតសារពើពន្ធ

ប្រព័ន្ធសារពើពន្ធសំដៅលើការគ្រប់គ្រងពន្ធដារគ្រប់ប្រភេទ ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការគៀរគរ ប្រមូលចំណូលពន្ធ អាករ រួមទាំងការគ្រប់គ្រងចំណាយ និងការចំណាយរបស់រដ្ឋាភិបាលនៃប្រទេសមួយឲ្យមានលក្ខណៈតុល្យភាព តម្លាភាព និងនីត្យានុកូលតាមច្បាប់ដែលបានកំណត់។ តាមរយៈប្រព័ន្ធសារពើពន្ធនេះ រដ្ឋអាចប្រមូលពន្ធពីអ្នកជាប់ពន្ធទាំងឡាយដូចជា ការប្រមូលពន្ធពីគេហជនគ្រួសារ សហគ្រាស ក្រុមហ៊ុនអាជីវកម្មផ្សេងៗ ហើយធ្វើការចំណាយមូលនិធិ ដែលប្រមូលបាននេះ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម ផលិតទំនិញសាធារណៈ ផ្ដល់សេវាសាធារណៈ ការពារសន្តិសុខជាតិ អភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈការអនុវត្តកម្មវិធី ផែនការ និងគោលនយោបាយផ្សេងៗរបស់រដ្ឋ ដើម្បីផលប្រយោជន៍សាធារណៈ និងសង្គមជាតិទាំងមូល។

គួយ៉ាងក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាពីសម័យបុរាណ ពន្ធដារ ឬការយកពន្ធ និងការប្រមូលពន្ធពីប្រជាជន ឬប្រជារាស្ត្របានកកើតជាយូរណាស់មកហើយ តាមរយៈការឲ្យ ការឲ្យខ្ចី និងការផ្ដល់ឲ្យ ឬប្រទាន ដូចជាការផ្ដល់ទ្រព្យសម្បត្តិរបស់រដ្ឋ ជាដីធ្លី ដីស្រែ ដីចំការ ដែលត្រូវបានស្ដេចប្រទាន ផ្ដល់ឲ្យប្រជាជន ឬអ្នកស្រុក ដែលរស់នៅដើម្បីធ្វើ អាជីកម្ម ផលរបរ កសិកម្ម ដាំដុះ ហើយត្រូវផ្ដល់មកឲ្យរដ្ឋ ឬស្ដេចវិញជាភោគផល ឬយកដង្វាយ ដើម្បីជាការតបស្នងក្នុងការផ្ដល់ឲ្យខ្ចី ដែលនេះត្រូវបានចាត់ទុកថា ជាសញ្ញាណនៃការយកពន្ធ និងការប្រមូលពន្ធ ទោះបីមិនទាន់មានលក្ខណៈតាមប្រព័ន្ធ និងមានលក្ខណៈចង្អៀតក៏ដោយ។ ហើយក្នុងសម័យឧដុង្គ ក្រោមការសោយរជ្យ និងដឹកនាំប្រទេសដោយព្រះបាទអង្គឌួង ព្រះអង្គចាប់ផ្ដើមកសាងប្រទេសឡើងវិញ ដោយយកថវិកាពីឃ្លាំងរាជវាំង បង្កើតស្ថាប័នផ្នែកសង្គមកិច្ច ពោលគឺប្រជារាស្ត្រក្រីក្រ និងព្រះសង្ឃ អាចមកទទួលអាហារស្រស់ស្រូប និងឆាន់ប្រចាំថ្ងៃ។ ព្រះអង្គបានបន្ថយពន្ធដារនានា ហើយសុវត្ថិភាពក៏បានកើតឡើងវិញក្នុងប្រទេសដោយព្រះអង្គចាប់ផ្ដើមបង្កើតឲ្យមានច្បាប់ មាត្រាច្បាប់នានា តាមរបៀបនៃការគ្រប់គ្រងមានលក្ខណៈជាប្រព័ន្ធ និងរចនាសម្ព័ន្ធត្រឹមត្រូវ។ រហូតដល់សម័យអាណានិគមនិយមបារាំង កម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំងជិតមួយរយឆ្នាំ គឺពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ បារាំងបានបង្កើតច្បាប់ នាំយកច្បាប់ របៀបរបបគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងប្រទេសមកអនុវត្ត ក្នុងទឹកដីអាណានិគម[31]។

[31] សូមមើល គង់ ប៊ុនធី (២០១៦)។

តាមសន្ធិសញ្ញាថ្ងៃទី១១ សីហា ១៨៦៣ រវាងបារាំង-ខ្មែរ ព្រះចៅអធិរាជបារាំង បានសន្យាថានឹងរៀបចំប្រទេសកម្ពុជាឲ្យស្ថិតក្នុងសន្តិភាព និងរបៀបរៀបរយ ការពារចំពោះការវាយលុកទាំងឡាយមកពីខាងក្រៅ និងជួយខ្មែរ ក្នុងការហូតពន្ធគយ ផ្តល់ភាពងាយស្រួល ក្នុងការធ្វើគមនាគមន៍តាមផ្លូវសមុទ្រ។ ស្ថិតនៅក្រោមអាណានិគម បារាំងបាននាំយកនូវវិស័យសារពើពន្ធ ដែលតម្រូវឲ្យប្រជាពលរដ្ឋម្នាក់ៗ ត្រូវមានកាតព្វកិច្ចបង់ពន្ធ។ បារាំងបានប្រមូលពន្ធដោយមានប្រសិទ្ធិភាព ការកំណត់ពន្ធដារ និងការបង់ពន្ធដារខ្ពស់ តឹងរឹង និងធ្ងន់ធ្ងរ រហូតដល់មានការបះបោរពន្ធដារកើតមានឡើងជាបន្តបន្ទាប់។

ដូចនេះច្បាប់សារពើពន្ធកម្ពុជាអាចត្រូវបានមើលឃើញ និងចាត់ទុកថាជាច្បាប់ពន្ធដារដែលកើតចេញពីការនាំចូលនៃច្បាប់បារាំង ដោយអាណានិគមបារាំង ហើយជាបន្តបន្ទាប់កម្ពុជា ក៏មានប្រព័ន្ធគ្រប់គ្រង ដឹកនាំប្រទេស តាមប្រព័ន្ធច្បាប់ត្រឹមត្រូវ ជានីតិរដ្ឋដោយពឹងផ្អែកលើច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ដែលជាច្បាប់គ្រឹះនៃប្រទេស ហើយការយកពន្ធដារនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត។ ថវិកាជាតិត្រូវបានកំណត់ឲ្យអនុវត្តតាមច្បាប់ ដែលត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់មាត្រាទី៥៧ នៃជំពូកទី៥ អំពីសេដ្ឋកិច្ច។ ផ្តើមចេញពីការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលក្នុងសង្គមមនុស្ស តាមសម័យកាលពីបុរាណរហូតដល់បច្ចុប្បន្នទំនើប ដែលត្រូវឆ្លងកាត់ការបែងចែកវណ្ណៈ ការគាប់សង្កត់ ការបះបោរ ការតស៊ូនិងរើបំរាស់ ការកើតឡើង និងការរៀបចំរដ្ឋបាលកម្ពុជាបច្ចុប្បន្ននេះ មានរចនាសម័ន្ធគ្រប់គ្រងដឹកនាំរដ្ឋទំនើបរឹងមាំ ដោយអនុវត្តតាមច្បាប់ជាធរមានដូចជាច្បាប់ស្តីពីប្រព័ន្ធហរិញ្ញវត្ថុសាធារណៈឆ្នាំ១៩៩៣ និងឆ្នាំ២០០៨ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ច្បាប់ស្តីពីហរិញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងច្បាប់ដែលពាក់ព័ន្ធ និងបទបញ្ញត្តិផ្សេងៗត្រូវបានបង្កើតឡើង ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង ដឹកនាំ និងអនុវត្តសារពើពន្ធ ប្រព័ន្ធសារពើពន្ធ និងពន្ធដារឲ្យមានលក្ខណៈកាន់តែទូលំទូលាយ ទំនើប និងប្រកដោយប្រសិទ្ធភាពខ្ពស់ និងការធានាតុល្យភាពចំណូល និងចំណាយរបស់រាជរដ្ឋាភិបាល។

## ១២. ប្រព័ន្ធសារពើពន្ធ

គោលបំណង និងគោលដៅរបស់វិស័យសាធារណៈ អាចកើតមានតាមរយៈការប្រើប្រាស់ប្រាក់ចំណូលជាតិ ដែលបានមកពីការប្រមូលចំណូលសារពើពន្ធ របស់រដ្ឋាភិបាលដែលមានចែងដោយច្បាប់ និងគោលការណ៍ត្រឹមត្រូវ ហើយត្រូវធ្វើការវិចារណកម្មចំណាយ លៃលកធ្វើយ៉ាងណា ដើម្បីធានានូវវិភាជន៍ថវិកាសម្រាប់ចំណាយ ប្រកបដោយប្រសិទ្ធភាពនៃវិស័យសាធារណៈ ដូចជាការចំណាយទាំងលើទំនិញ សេវាសាធារណៈ និងទំនិញឯកជន។ នៅក្នុងសេដ្ឋកិច្ចទីផ្សារ តាមរយៈទំនិញ សេវាកម្មមួយចំនួនត្រូវបានផលិត ឬផ្គត់ផ្គង់ ឬផ្តល់ដោយវិស័យសាធារណៈ ដោយសារការផលិត ឬការផ្គត់ផ្គង់ ឬការផ្តល់គឺមានការលំបាក ឬមិនអាចធ្វើទៅបានដោយវិស័យឯកជន ។ លើសពីនេះទៀត ដោយសារ

កម្រិតនៃការប្រើប្រាស់ និងផលិតកម្មមិនមែនជាជម្រើស ឬអាចត្រូវបានផ្គត់ផ្គង់ក្នុងតម្លៃទាប តាមរយៈវិស័យសាធារណៈ បើទោះបីជាប្រព័ន្ធទីផ្សារអាចផលិត ឬផ្គត់ផ្គង់ ឬផ្តល់ទំនិញបែបនេះក៏ដោយ ។

រដ្ឋាភិបាលអាចផលិត ឬផ្គត់ផ្គង់ ឬផ្តល់ទំនិញ និងសេវាកម្មមួយចំនួន ដែលជាមធ្យោបាយមួយនៃបំណែងចែកប្រាក់ចំណូលឡើងវិញសម្រាប់ប្រជាជន និងសង្គម។ នយោបាយដើរតួនាទីសំខាន់ដោយសារតែបង្ហាញពីសកម្មភាព នៃរដ្ឋាភិបាលដែលប្រើប្រាស់ប្រាក់ចំណូល ដែលបានមកពីប្រភពពន្ធដើម្បីអាចគាំទ្រចំណាយ និងផ្គត់ផ្គង់ក្នុងវិស័យសាធារណៈ សូម្បីតែដំណើរការនៃយកចិត្តទុកដាក់កំណត់តម្រូវការ ទំនិញសាធារណៈនឹងធ្វើឲ្យមានឥទ្ធិពលលើលទ្ធផល។ ដូចនេះការកំណត់ និងការវិភាគទ្រឹស្តីនៃបរាជ័យនៃទីផ្សារ ដែលកើតចេញពីមូលហេតុនៃការផលិត ឬផ្គត់ផ្គង់ ឬផ្តល់ដោយវិស័យសាធារណៈ គឺមិនអាចគ្រប់ជ្រុងជ្រោយនោះទេ ហើយអ្វីដែលសំខាន់នោះគឺ ត្រូវពិនិត្យមើលនូវទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងការិយាធិបតេយ្យនៃថវិកាចំណាយជារណៈ[32]។

សារពើពន្ធសំដៅលើបណ្តាពន្ធគ្រប់ប្រភេទ សព្វសារពើទាំងអស់។ ពន្ធដារ មាននិយមន័យច្រើនទៅតាមការកំណត់ន័យនៃបទប្បញ្ញត្តិនៃច្បាប់របស់រដ្ឋ តាមការកំណត់ន័យ នៃសកម្មភាពសេដ្ឋកិច្ច និងសង្គម។ល។ យោងតាមច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ពាក្យពន្ធនេះ មានន័យថាជាពន្ធ និងអាករទាំងឡាយ ដែលសំដៅលើពន្ធផ្ទាល់ និងពន្ធប្រយោល ហើយបើយោងតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យពន្ធនេះ មានន័យថា សួយ អាករ ដែលប្រជានិករត្រូវបង់តាមកំណត់។

ពន្ធ គឺជាកាតព្វកិច្ចនៃការចូលរួមវិភាគទានដល់ចំណូលរដ្ឋ ឬចំណូលប្រទេសជាតិ ដែលត្រូវបានប្រមូលដោយរដ្ឋាភិបាលលើប្រាក់ចំណូល ប្រាក់ចំណេញ ដែលបានមកពីសម្មភាពសេដ្ឋកិច្ច អាជីវកម្ម និងការដោះដូរទំនិញ សេវាកម្ម ឬជាសកម្មភាពប្រតិបត្តិការ។ ពន្ធ គឺជាបន្ទុកហិរញ្ញវត្ថុ ដែលមានកាតព្វកិច្ច ឬប្រភេទពន្ធផ្សេងទៀត ដែលត្រូវបានដាក់លើអ្នកជាប់ពន្ធ ដោយរដ្ឋាភិបាល ដើម្បីផ្តល់ថវិកាគាំទ្រដល់ការចំណាយរបស់រដ្ឋាភិបាល និងការចំណាយសាធារណៈផ្សេងៗ។ ការខកខានមិនបានបង់កាតព្វកិច្ចនៃការចូលរួមវិភាគទាន ឬមានការគេចវេសការបង់ពន្ធនឹងត្រូវផ្តន្ទាទោសតាមច្បាប់។

ពន្ធ គឺជាចំណូលដែលត្រូវបានបង់ជូនរដ្ឋាភិបាល ដោយអ្នកជាប់ពន្ធពន្ធ ហើយចំណូលពន្ធដែលប្រមូលបាន នឹងត្រូវត្រលប់ទៅជាចំណាយសាធារណៈដោយរដ្ឋាភិបាល។ ពន្ធ គឺជាវិភាគទានហិរញ្ញវត្ថុ ជាកាតព្វកិច្ចដែលរដ្ឋ ឬស្ថាប័ន (អាជ្ញាធរដែនដី ឬគ្រឹះស្ថានសាធារណៈ) ត្រូវប្រមូលដោយមានការកំណត់ដាច់ខាត់ និងដោយគ្មានបដិភាគអ្វីទាំងអស់ ដើម្បីយកមកបំពេញ ចំណាយសាធារណៈ (បណ្ឌិត ហង់ ជួន ណារ៉ុង និងប្រ៉ាទ្រីក ហ្សីលបែ-ដឺវ៉ាល់ឡុង ឆ្នាំ២០០៩)។ គ្រប់ផលរបរ

[32] សូមមើល Clifford Winston (2006)។

ស្របច្បាប់ដែលកើតពីសកម្មភាពសេដ្ឋកិច្ច អាជីវកម្ម ឬការដោះដូរ ដើម្បីផលប្រយោជន៍ បានចំណូល ចំនេញ និងការចំណាយដែលកើតមាន ទោះបីក្នុងហេតុផលណាក៏ដោយ គឺត្រូវមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ ដើម្បីឲ្យរដ្ឋមានលទ្ធភាពធ្វើការបែងចែកឡើងវិញ នូវចំណូលដែលបានមកពីពន្ធ ក្នុងការចំណាយសាធារណៈ។

ពន្ធដារ គឺជារូបភាពនៃការបែងចែកឡើងវិញនូវចំណូលជាតិ ដែលរដ្ឋាលភិបាលប្រើប្រាស់ដើម្បីប្រមូលចំណូលមួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ច ក្នុងការផ្សារភ្ជាប់ជាមួយនឹងសិទ្ធិអំណាចនយោបាយរបស់រដ្ឋាភិបាល និងជាវិភាគទានទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលកើតចេញពីសកម្មភាពសេដ្ឋកិច្ច និងអាជីវកម្ម។ តាមទស្សនៈរបស់លោក Charles.M.Allan ពន្ធដារ គឺជាលំហូរនៃទ្រព្យសម្បត្តិឯកជនទៅកាន់រដ្ឋ លើកលែងតែជាប្រាក់កម្ចី និងការលក់សេវាកម្មសាធារណៈរបស់រដ្ឋ។ ចំពោះទស្សនៈរបស់លោក E.R.A.Seligman ពន្ធដារ គឺជាអ្វីៗដែលរដ្ឋធ្វើការកំណត់ប្រមូលមកពីរាស្ត្រ ដើម្បីនាំមកប្រើប្រាស់ជាប្រយោជន៍ដល់សង្គមជាតិ ដោយមិនចំពោះបុគ្គលណាមួយឡើយ រួមទាំងអ្នកជាប់ពន្ធផងដែរ។ តាមលោក Gaston Jéz ដែលមានក្នុងសៀវភៅ នីតិសារពើពន្ធ ធុរកិច្ច រៀបរៀងដោយ លោកគង់ ប៊ុនលី ពន្ធ គឺត្រូវបានកំណត់និយមន័យថា ជាតាវកាលិក គិតជាប្រាក់កាសដែលប្រមូលបានពីបុគ្គលឯកជននានា តាមរយៈអំណាចសាធារណៈ ជាលក្ខណៈស្ថាពរ និងគ្មានអ្វីជាថ្នូរ ក្នុងកោលបំណងដើម្បីបំពេញបន្ទុកសាធារណៈ (គង់ ប៊ុនធី ២០១៦) ហើយស្រដៀងគ្នានេះដែរ ពន្ធ គឺជាការបង់ដោយបង្ខំ ដែលកំណត់ដោយរដ្ឋាភិបាលទៅលើរូបវន្តបុគ្គល សាជីវកម្ម ឬសហគ្រាស ហើយគ្មានផ្តល់សេវាកម្មទៅឲ្យអ្នកបង់ពន្ធនោះដោយផ្ទាល់វិញឡើយ។ ពលរដ្ឋគ្រប់រូបត្រូវបង់ពន្ធដោយផ្អែកលើចំណូល ដែលគេរកបាន (អ៊ឹម សុផល ១៩៩៧)។ ពន្ធ មិនមែនជាការបង់ដោយស្ម័គ្រចិត្ត ឬជាអំណាយនោះទេ ប៉ុន្តែជាវិភាគទានដោយបង្ខំ ដោយអនុលោមទៅតាមអំណាចនីតិប្បញ្ញត្តិ និងមានការគាំទ្រដោយអំណាចនីតិប្រតិបត្តិ និងតុលាការ។

ពន្ធ គឺជាវិភាគទានដែលប្រជាពលរដ្ឋត្រូវចូលរួមដោយមានការចាប់បង្ខំពីរដ្ឋាភិបាល។ ពន្ធត្រូវបានចាត់ទុកជាប្រភពចំណូល ដ៏សំខាន់ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណូលដែលបានមកពីការប្រមូលសារពើពន្ធត្រូវបានបែងចែង ប្រើប្រាស់ដើម្បីជួយដល់ចំណាយ និងទ្រទ្រង់ចំណាយក្នុងប្រទេសលើកិច្ចការរដ្ឋបាលសាធារណៈ ហិរញ្ញវត្ថុសាធារណៈ ដូចជាការផ្តល់ជាទំនិញ ឬសេវាសាធារណៈ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងសុខុមាលភាពសេដ្ឋកិច្ច និងសង្គម។

យោងតាមមាត្រាទី ៧(មួយ) នៃច្បាប់ស្តីពីសារពើពន្ធកំណត់ថា ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធ ដែលសម្រេចបានពីសកម្មភាពអាជីវកម្ម និងសកម្មភាពនានាក្រៅពីអាជីវកម្មរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល។ ប្រាក់ចំណូលជាប់ពន្ធរួមបញ្ចូលទាំងចំណេញមូលធន ការប្រាក់ ថ្លៃឈ្នួលសួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ រាប់ទាំងអចលនទ្រព្យផង។ ចំពោះនីតិបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលកើតចេញពីការនិយ័តកម្មលើលទ្ធផលគណនេយ្យ

ក្នុងឆ្នាំជាប់ពន្ធ។ ចំពោះរូបវន្តបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលបានមកពីការយកចំនួនសរុបនៃប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធ កាត់កងនឹងចំណាយ និងទាយជ្ជទាននានា។

## ១២.១. របបកំណត់ពន្ធ

យោងតាមមាត្រាទី១៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ពន្ធ អាករ និងចំណូលសារពើពន្ធផ្សេងៗត្រូវកំណត់ដោយច្បាប់ និងត្រូវប្រមូល និងត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អត្រាពន្ធ អាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និងវិវាទ ដែលទាក់ទងនឹងការកំណត់ ប្រមូល និងការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និងតាមបែបបទ ដែលមានចែងនៅក្នុងក្របខ័ណ្ឌ និងតាមបែបបទ ដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និងអាករនីមួយៗ។ មុនឆ្នាំ២០១៥ ប្រព័ន្ធពន្ធដារកម្ពុជា សម្រាប់អ្នកជាប់ពន្ធនៅព្រះរាជាណាចក្រកម្ពុជា មានរបបកំណត់ពន្ធពីរប្រភេទគឺ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត) និងអ្នកជាប់ពន្ធតាមរបបម៉ៅការ។ អ្នកជាប់ពន្ធទាំងឡាយត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ថ្ងៃ ក្រោយមានសកម្មភាពសេដ្ឋកិច្ច។ បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស ដោយយោងតាមមាត្រាទី១០១ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានចែងពីកាតព្វកិច្ច ការចុះបញ្ជីពន្ធដារ សំដៅដល់ការចុះបញ្ជីអ្នកជាប់ពន្ធទាំងឡាយ ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

សហគ្រាសខ្នាតតូច មធ្យម និងធំដើរតួយ៉ាងសំខាន់ក្នុងសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ តាមរយៈចំណូលពន្ធដែលប្រមូលបាន ហើយត្រូវបានចាត់ទុកជាកម្លាំងចលករក្នុងការរុញច្រានកំណើនសេដ្ឋកិច្ច ជាពិសេសនៅបណ្តាប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើនដូចប្រទេសកម្ពុជា។ ការរីកចម្រើននៃសកម្មភាពអាជីវកម្ម របស់សហគ្រាសខ្នាតតូច មធ្យម និងធំ ជួយឲ្យប្រជាជនមានការងារធ្វើច្រើន ព្រោះថានៅពេលដែលមានសហគ្រាសខ្នាតតូច មធ្យម និងធំកាន់តែច្រើនឡើងនឹងជួយបង្កើតការងារកាន់តែច្រើន កាត់បន្ថយអត្រានិកម្មភាព កាត់បន្ថយចំណាកស្រុក បង្កើនផលិតភាពផលិតកម្ម និងបង្កើនប្រាក់ចំណូលជាដើម។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឲ្យអនុវត្តកំណែទម្រង់សារពើពន្ធថ្មី ដែលមានរបបកំណត់ពន្ធតែមួយ គឺរបបស្វ័យប្រកាស។ ប្រព័ន្ធដារថ្មីនេះ ត្រូវបានចាប់ផ្តើមអនុវត្ត ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ តាមរយៈប្រកាសលេខ ១៨១៩ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស បានសម្រេចលុបចោលរបបពន្ធម៉ៅការ និងដាក់ឲ្យអ្នកជាប់ពន្ធអនុវត្តតាមរបបស្វ័យប្រកាស។ ហើយប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបប

ស្វ័យប្រកាស លេខ ០២៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ មានគោលបំណង និងគោលដៅកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ក្នុងខែធ្នូ ឆ្នាំ២០១៥ ដើម្បីឲ្យមានសង្គតិភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធគ្រប់ប្រភេទឲ្យមានប្រសិទ្ធភាព តម្លាភាព និងសមធម៌ ឲ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច។ របបកំណត់ពន្ធនៃព្រះរាជណាចក្រកម្ពុជា ជារបបស្វ័យប្រកាស ដែលតម្រូវឲ្យអ្នកជាប់ពន្ធ ធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធដោយខ្លួនឯង។ អ្នកជាប់ពន្ធ សំដៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបានចែកជា ៣ប្រភេទ គឺអ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធម្យ និងអ្នកជាប់ពន្ធធំ។

អ្នកជាប់ពន្ធតូច ត្រូវប្រើវិធានគណនេយ្យសាមញ្ញ ដែលនឹងត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំត្រូវប្រើវិធានគណនេយ្យតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា។ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធ បានកើតឡើងលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ច ដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធបង្ហាញច្បាស់លាស់។ សកម្មភាពសេដ្ឋកិច្ច គឺសំដៅដល់សកម្មភាពរបស់បុគ្គល (រូបវន្តបុគ្គល ឬនីតិបុគ្គល)ដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដង មួយគ្រា ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាឲ្យដល់បុគ្គលដទៃក្នុងគោលបំណងដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។ អាជីវកម្ម សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គងសេវា ភិតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងៗទៀត។

## ១២.២. ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

យោងតាមប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសលេខ ០០៩ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ដែលត្រូវអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រ និងបានចុះបញ្ជីពន្ធដារចាប់ពីឆ្នាំ២០២១តទៅ[33]។ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម និងពាណិជ្ជកម្ម។ ផលរបរសំដៅដល់តម្លៃនៃការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មដែល

[33] សូមមើល ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសឆ្នាំ ២០១៨ និង ប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសឆ្នាំ២០២១។

ជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានចាត់ថ្នាក់ជាបីប្រភេទដូចខាងក្រោម៖

១. អ្នកជាប់ពន្ធតូច គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែល៖

ក. មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ

ខ. មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

គ. មានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត ចាប់ពី ៦០ លានរៀលឡើងទៅ ឬ

ឃ. រំពឹងថាមានផលរបរក្នុងរយៈពេលបីខែជាប់ៗគ្នាខាងមុខចាប់ពី ៦០ លានរៀល ឡើងទៅ ឬ

ង. ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវារួមទាំងភាស៊ី។

២. អ្នកជាប់ពន្ធមធ្យម គឺជាបុគ្គលដែលស្ថិតក្នុងល័ក្ខខ័ណ្ឌណាមួយ ក្នុងចំណោមល័ក្ខខ័ណ្ឌខាងក្រោម៖

ក. មានផលរបរប្រចាំឆ្នាំលើសពី ១០០០ លានរៀល ដល់ ៤០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ

ខ. មានផលរបរប្រចាំឆ្នាំលើសពី ១០០០ លានរៀល ដល់ ៦០០០ លានរៀល សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម ឬ

គ. មានផលរបរប្រចាំឆ្នាំលើសពី ១៦០០ លានរៀល ដល់ ៨០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

ឃ. ជាសហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ

ង. ជាស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ ឬ

ច. ជាបេសកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ។

៣. អ្នកជាប់ពន្ធធំ គឺជាបុគ្គលដែលស្ថិតក្នុង ល័ក្ខខ័ណ្ឌណាមួយក្នុងចំណោមល័ក្ខខ័ណ្ឌខាងក្រោម៖

ក. មានផលរបរប្រចាំឆ្នាំលើសពី ៤០០០លានរៀល សម្រាប់វិស័យកសិកម្ម ឬ

ខ. មានផលរបរប្រចាំឆ្នាំលើសពី ៦០០០លានរៀល សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម ឬ

គ. មានផលរបរប្រចាំឆ្នាំលើសពី ៨០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

ឃ. ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ

ង. ជាសហគ្រាស ដែលបានចុះបញ្ជីជាគម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## ១២.៣. ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្ម

ទ្រព្យសកម្មសំដៅដល់ទ្រព្យសម្បត្តិនានា ដែលត្រូវបានយកទៅប្រើប្រាស់ក្នុងអាជីវកម្ម ដែលរួមមានទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង។ ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែងរបស់អ្នកជាប់ពន្ធទេនោះ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធឡើងវិញ ដោយផ្អែកលើតម្លៃទ្រព្យសកម្ម ដែលបានប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាសដូចខាងក្រោម៖

១. អ្នកជាប់ពន្ធតូច

ក. មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លានរៀល ដល់ ១០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ. មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លានរៀល ដល់ ២០០០ លានរៀល សម្រាប់វិស័យឧស្សាកម្ម ឬ

២. អ្នកជាប់ពន្ធមធ្យម

ក. មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ១០០០ លានរៀល ដល់ ២០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ. មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២០០០ លានរៀល ដល់ ៤០០០ លានរៀល សម្រាប់វិស័យឧស្សាកម្ម។

៣. អ្នកជាប់ពន្ធធំ

ក. មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ. មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ៤០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម។

ចាប់តាំងពីឆ្នាំ២០១៤ ក្រសួងឧស្សាហកម្ម និងសិប្បកម្មត្រូវទទួលខុសត្រូវសម្រាប់ការចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម ហើយចំនួនសហគ្រាសខ្នាតតូច និងមធ្យមដែលបានចុះបញ្ជីសរុបបានកើនឡើងដល់ចំនួន ១៥៥ ៧៤៥ នៅឆ្នាំ២០១៨ ។ យោងតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា នៅត្រឹមឆ្នាំ២០២៥ សហគ្រាសដែលមានចំនួនស្មើនឹង៨០ភាគរយ និង៩៥ភាគរយ នៃសហគ្រាសទាំងអស់ ត្រូវបានគេរំពឹងថានឹងចុះបញ្ជីផ្លូវការ ហើយខណៈ៥០ភាគរយ និង៧០ភាគរយ នៃសហគ្រាសខ្នាតតូច និងមធ្យម គួរតែមានកំណត់ត្រាប្រវត្តិហិរញ្ញវត្ថុ និងតារាងតុល្យការឲ្យបានត្រឹមត្រូវ។

## ១៣. ការគ្រប់គ្រងចំណូលពន្ធ

ការគ្រប់គ្រងចំណូលពន្ធដារប្រកបដោយប្រសិទ្ធភាពបានចូលរួមយ៉ាងសកម្ម ក្នុងការជំរុញល្បឿនកំណើនសេដ្ឋកិច្ចប្រទេសជាតិទាំងមូល ដូចនេះរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់លើគោលនយោបាយពន្ធផ្តោតទៅលើលទ្ធភាព យន្តការ និងវិធីសាស្ត្រនៃការគៀរគរ ប្រមូលពន្ធឲ្យបានគ្រប់គ្រាន់ តាមប្រភេទពន្ធ កម្រិតពន្ធ និងអត្រាពន្ធ បំណែងចែកប្រាក់ចំណូល ដែលទទួលបានស្របនឹងតម្រូវការចំណាយរដ្ឋាភិបាលឲ្យមានសមធម៌ដែលអាចជួយរក្សាសមាមាត្ររវាងអ្នកមាន និងអ្នកក្រមិនឲ្យមានចន្លោះធំ ឬឃ្លាតឆ្ងាយពីគ្នា និងធានាកំណើន ស្ថិរភាព និងចីរភាពដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ដែលនោះមានន័យថា ពន្ធដារមិនត្រឹមតែជាប្រភពនៃចំណូលជាតិដ៏សំខាន់របស់ថវិការដ្ឋតែមួយមុខប៉ុណ្ណោះនោះទេ ប៉ុន្តែពន្ធដារបានផ្សារភ្ជាប់ជាមួយបញ្ហាសំខាន់ៗទាំងឡាយអំពីការបង្កើនល្បឿនអភិវឌ្ឍសេដ្ឋកិច្ច អំពីសមាសភាពក្នុងមុខងារនៃការវិភាជ ធនធាន មុខងារនៃបំណែងចែងចំណូល និងមុខងារនៃស្ថិរភាពសេដ្ឋកិច្ចក្នុងសង្គម។ នៅពេលរដ្ឋាភិបាលប្រើប្រាស់ អនុវត្ត និងគ្រប់គ្រងគោលនយោបាយសារពើពន្ធមិនបានត្រឹមត្រូវ ឬមិនមានប្រសិទ្ធភាព នោះនឹងអាចនាំឲ្យមានផលអវិជ្ជមានកើតឡើងចំពោះសេដ្ឋកិច្ច ប៉ះពាល់ដល់ល្បឿនកំណើននៃខឿនសេដ្ឋកិច្ច និងការកើនឡើងនៃភាពក្រីក្រ។ល។

## ១៤. អគ្គនាយកដ្ឋានពន្ធដារ

ពន្ធដារឆ្លុះបញ្ចាំងអំពីការបែងចែកឡើងវិញនូវចំណូលជាតិ ដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ច ដូចជា ពាណិជ្ជកម្ម អាជីវកម្ម ផលិតកម្ម សិប្បកម្ម សេវាកម្ម ការប្រើប្រាស់ក្នុងការផ្សារភ្ជាប់ជាមួយនឹងសិទ្ធិអំណាចនយោបាយ និងជាវិភាគទានទាំង រូបវន្តបុគ្គល និងនីតិបុគ្គល។ ជាទូទៅពន្ធអាចត្រូវបានបែងចែកជាពីប្រភេទ គឺពន្ធផ្ទាល់ និងពន្ធប្រយោល។ ពន្ធផ្ទាល់ គឺជាបន្ទុកផ្ទាល់នៃអ្នកជាប់ពន្ធ ដូចជាពន្ធលើប្រាក់បៀវត្សរ៍ និងពន្ធលើប្រាក់ចំណេញជាដើម។ ពន្ធប្រយោល គឺជាពន្ធដែលត្រូវបង់ដោយអ្នកជាប់ពន្ធជំនួសតតិជនដែលជាអ្នកជាប់ពន្ធពិតប្រាកដ ដូចជាអាករលើតម្លៃបន្ថែម និងពន្ធគយជាដើម។

រដ្ឋបាលសារពើពន្ធ គឺជាអង្គការចាត់តាំងនៃអគ្គនាយកដ្ឋានពន្ធដារ។ រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចប្រមូលពន្ធ អនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងប្តឹងទៅតុលាការក្នុងករណីមានការរំលោភច្បាប់។ អគ្គនាយកដ្ឋានពន្ធដារ គឺជារដ្ឋបាលសារពើពន្ធ ដែលមានប្រព័ន្ធចាត់តាំងឯកភាព ទទួលខុសត្រូវគ្រប់គ្រងទូទាំងប្រទេស និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានពន្ធដារ បំពេញមុខងារជា

សេនាធិការឲ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើបេសកម្មធ្វើឲ្យសម្រេចនូវការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារដូចតទៅ[34]៖

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឲ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឲ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានានស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួន ធ្វើឲ្យមានភាពសាមញ្ញ ចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានានិងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដោយផ្អែកលើការអង្កេត និងផ្ទុំព័ត៌មាន

[34] សូមមើល អនុក្រឹត្យស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០០៨។

- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ពន្ធប្រថាប់ត្រា ការប្រាក់ និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ១៥. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បំពេញមុខងារជាសេនាធិការឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកម្មដូចតទៅ[35]៖

- ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗ លើទំនិញនាំចេញ ឬនាំចូល ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល ការធ្វើចរាចរ និងការធ្វើសន្និធិទំនិញ
- ដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬនាំចូល
- ជំរុញបង្ការ និងការបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ
- ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ជំរុញការអនុវត្តតាមស្តង់ដារអន្តរជាតិ និងឧត្តមានុវត្តន៍ដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ជាពិសេសការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការស្វ័យប្រវត្តិកម្មគយ។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានប្រព័ន្ធចាត់តាំងគ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំ និងត្រួតពិនិត្យលើរាល់អង្គភាពគយ និងរដ្ឋាករពីថ្នាក់កណ្តាល រហូតដល់ថ្នាក់មូលដ្ឋាន រាជធានី ខេត្ត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- លើកសំណើគោលនយោបាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិ រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងារប្រមូលពន្ធ និងអាករនាំចេញ នាំចូល

[35] ដូចលេខ 33

គ្រប់ប្រភេទ ជាពិសេស ពិនិត្យពិចារណា ក្នុងការកសាង និងអនុវត្តតារាងពន្ធគយ និងនីតិវិធីទាំងឡាយ ដែលទាក់ទងនឹងការងារគយ និងរដ្ឋាករ លើមុខទំនិញគ្រប់ប្រភេទឲ្យបានសមស្របទៅតាមដំណាក់កាលនីមួយៗនៃការវិវត្តសេដ្ឋកិច្ច

- ជាស្ថាប័ននាំមុខតែមួយគត់ ដែលទទួលខុសត្រូវ លើការត្រួតពិនិត្យទំនិញនាំចេញ ឬនាំចូល នៅមាត់ច្រកព្រំដែន និងមានភារកិច្ចសម្របសម្រួលឲ្យមានការត្រួតពិនិត្យរួមគ្នាតែមួយលើក ក្នុងករណីដែលតម្រូវឲ្យមានការត្រួតពិនិត្យដោយស្ថាប័នផ្សេងទៀត ស្របតាមការកំណត់រកឃើញហានិភ័យ
- គ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តការប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូលគ្រប់ប្រភេទ
- លើកវិធានការរាំងខ្ទប់ និងចាប់ឃាត់ទំនិញរត់ពន្ធគយគ្រប់ប្រភេទ
- ត្រួតពិនិត្យ តាមដាន និងគ្រប់គ្រងការនាំចេញ នាំចូលទំនិញគ្រប់ប្រភេទ ទោះមាន ឬគ្មានលក្ខណៈពាណិជ្ជកម្មក្តី ដោយរាប់បញ្ចូលទាំងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ ឬផ្លាស់ប្តូរលំនៅដ្ឋាន រូបិយប័ណ្ណ លោហធាតុ ត្បូងថ្មមានតម្លៃ បេតិកភណ្ឌវប្បធម៌ និងភណ្ឌិកាប្រៃសណីយ៍ ព្រមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ
- លើកគម្រោងជ្រើសរើស និងបណ្តុះបណ្តាលជំនាញបច្ចេកទេស មន្ត្រី បុគ្គលិក និងភ្នាក់ងារគយ និងរដ្ឋាករ
- អនុវត្តគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងការងារគយ និងរដ្ឋាករ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។
- អនុវត្តនូវភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# មេរៀនទី៣៖ ថវិកា

## ១. សេចក្តីផ្តើម

ជាទូទៅថវិកាយោងទៅលើប្រាក់ចំណូល និងប្រាក់ចំណាយគ្រោងទុក របស់រដ្ឋាភិបាលនៃប្រទេសមួយ ដែលអាចមានតុល្យភាព និងអាចមិនមានតុល្យភាព។ ប្រសិនបើ រដ្ឋាភិបាលមានចំណូលច្រើនជាងចំណាយ នោះគឺជាអតិរេក។ ចំណាយច្រើនជាងចំណូលនាំឲ្យមានឱនភាព។ ឱនភាពថវិកាកើតឡើងនៅពេលដែលចំណាយ របស់រដ្ឋាភិបាលកើនឡើងលើសចំណូលដែលទទួលបាន ហើយភាពខុសគ្នានេះ បង្កើតបានជាបំណុលសាធារណៈដែលប្រទេសមួយអាចធ្វើហិរញ្ញប្បទានតាមរយៈកម្ចីក្នុងស្រុក កម្ចីប្រាក់បរទេស ឬតាមរយៈមធ្យោបាយផ្សេងៗទៀត[36]។

បំណុលកាន់តែកើនឡើង ធ្វើឲ្យក្លាយជាបញ្ហានៃការគ្រប់គ្រងបំណុល ផលវិបាកនៃថវិកា និងគ្រប់គ្រងថវិកា ហើយធ្វើឲ្យក្លាយជាបញ្ហាហិរញ្ញវត្ថុសាធារណៈ។ ជាការចាំបាច់ ថវិកានៃប្រទេសមួយត្រូវបានធ្វើការគ្រោង និងការព្យាករណ៍ជាប្រចាំឆ្នាំដោយពឹងផ្អែកជាចំបង លើកត្តាប្រាក់ចំណូល ដែលរដ្ឋាភិបាលនៃប្រទេសនោះ ប្រមូលបានតាមរយៈពន្ធដារ និងលើកត្តាប្រាក់ចំណាយតាមរយៈចំណាយសាធារណៈ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ក្នុងមេរៀននេះ យើងនឹងសិក្សាអំពីថវិកា ដែលឆ្លុះបញ្ចាំងពីចរិតលក្ខណៈនៃថវិកា តាមរយៈដំណើរការនៃការរៀបចំថវិកា វិភាជន៍ថវិកា ការអនុម័តថវិកា ការប្រើប្រាស់ថវិកា និងការអនុវត្តថវិកា ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម ដោយលើកយកបរិបទកម្ពុជា។ ការសិក្សាអំពីថវិកា គឺជាផ្នែកមួយនៃហិរញ្ញវត្ថុសាធារណៈ ហើយដើម្បីឲ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានប្រសិទ្ធភាព ស្ថាប័ននីតិបញ្ញត្តិដើរតួនាទីសំខាន់ ក្នុងការអនុម័តច្បាប់ថវិកាដែលត្រូវអនុវត្តដោយរដ្ឋាភិបាល ដែលឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន ដែលជាអ្នកទទួលផលប្រយោជន៍ តាមរយៈផែនការ សកម្មភាព កម្មវិធី យន្តការ និងគោលនយោបាយ។

ថវិកាជាតិ ឬថវិការដ្ឋ សំដៅដល់គម្រោងតុល្យភាពនៃធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ។ ថវិកាជាតិ ឬថវិការដ្ឋរួមមាន ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ។ ថវិកាថ្នាក់ជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ជាតិ ដែលសំដៅដល់ថវិកា របស់របស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។ ថវិកាថ្នាក់ក្រោមជាតិ ជាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលសំដៅដល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងឃុំ សង្កាត់។ ថវិកាមានប្រភពមកពីចំណូលសារពើពន្ធ ថ្លៃសេវា ថ្លៃឈ្នួល ថ្លៃផាកពិន័យ ជំនួយបរទេស និងប្រភពចំណូលផ្សេងៗទៀត។ ថវិកាត្រូវបានបែងចែងសម្រាប់

---

[36] សូមមើល Richard Allen, Richard Hemming and Barry H. Potter (2013)។

ចំណាយលើកិច្ចការ ការងារប្រតិបត្តិការរបស់រដ្ឋាភិបាលតាមរយៈ ប្រាក់ខែមន្ត្រីរាជការ ការសាងសង់ផ្លូវថ្នល់ ការពារជាតិ ការអប់រំ សុខាភិបាល កិច្ចការគាំពារសង្គម និងសេវាសាធារណៈជាដើម។

តាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាល គឺជាអង្គការនីតិប្រតិបត្តិ ដែលមានតួនាទីគ្រប់គ្រងសង្គម និងអនុវត្តនយោបាយទូទៅ របស់ប្រទេសជាតិ។ រាជរដ្ឋាភិបាល មានសិទ្ធិគ្រប់គ្រងការប្រមូលចំណូល និងចំណាយរបស់ជាតិ និងការរៀបចំថវិកាជាតិ។ ថវិកាជាតិ ក្លាយជាច្បាប់ក្រោយពេលអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា។ ថវិការជាតិ ត្រូវបានកំណត់ឲ្យអនុវត្តតាមច្បាប់។ ថវិកាជាតិ មិនមែនជាថវិកាឯកជនដែលធ្វើការចំណាយ ដើម្បីរកចំណូល និងផលប្រយោជន៍ជាប្រាក់ចំណេញក្នុងអាជីវកម្ម នៃរបបសេដ្ឋកិច្ចទីផ្សារសេរីនោះទេ។ ផ្ទុយទៅវិញ ថវិកាជាតិ ផ្តោតសំខាន់ទៅលើការកសាងសុខុមាលភាពសេដ្ឋកិច្ចប្រជាជនឲ្យមានលក្ខណៈល្អប្រសើរ ជាជាងការគិតពីផលចំណេញ ដែលកើតពីការចំណាយ។ ច្បាប់ថវិកាជាតិ ដើរតួជាឧបករណ៍គោលនយោបាយចំណូល និងចំណាយសាធារណៈដ៏សារៈសំខាន់ និងចាំបាច់បំផុតរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តផែនការចំណូល និងចំណាយ ដើម្បីកកសាងសកម្មភាពការងារ និងជាផែនទីនៃមុខងារកំណត់អំពីចំណូល និងចំណាយជាតិ ដើម្បីសម្រេចបាននូវគោលបំណងកំណើនសេដ្ឋកិច្ចខ្ពស់ ដោះស្រាយតម្រូវការរបស់ប្រជាជន ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រមកត្រឹមកម្រិតអប្បបរមា។

នៅក្នុងឆ្នាំ២០០៤ ដើម្បីប្រមូលចំណូល និងប្រើប្រាស់ថវិកាឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ឲ្យអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៥-២០១៥ ដែលចែកចេញជាបួនដំណាក់កាល គឺ៖ ១.ភាពទុកចិត្តលើថវិកា៖ ពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល ២.គណនេយ្យភាពហិរិញ្ញវត្ថុ៖ ប្លង់គណនីថ្មី មាតិកាថវិកាថ្មី អង្គភាពថវិកា ៣.ការផ្សារភ្ជាប់ថវិកា នឹងគោលនយោបាយ៖ ការកែទម្រង់ប្រព័ន្ធថវិកា ៤.គណនេយ្យភាពចំពោះសមិទ្ធកម្ម៖ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម។ អត្ថប្រយោជន៍នៃកំណែទម្រង់នេះ បានឆ្លុះបញ្ចាំងឲ្យឃើញពីជំហានដំបូងនៅក្នុងដំណើរការ ដ៏វែងអន្លាយដើម្បីបង្កើតល័ក្ខខ័ណ្ឌ សម្រាប់ទទួលបាននូវការគ្រប់គ្រង ដែលមានស្តង់ដារខ្ពស់នៅកម្ពុជា និងមានការទទួលខុសត្រូវ ចំពោះការគៀគរធនធានមូលធន និងចរន្តរបស់រដ្ឋាភិបាលហើយធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៅក្នុងការប្រើប្រាស់ធនធានទាំងនោះ សម្រាប់អនុវត្តកម្មវិធីជាអាទិភាពរបស់រាជរដ្ឋាភិបាល។

ការរៀបចំថវិកាត្រូវកែលម្អមួយកម្រិត ជាពិសេសបន្ទាប់ពីការដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការសាកល្បងថវិកាកម្មវិធី ព្រមទាំងការពង្រឹងការព្យាករណ៍ចំណូល និងការគណនាតម្រូវការចំណាយ។ ការអនុម័តថវិកា ត្រូវបានកែលម្អមួយកម្រិត ជាពិសេសបន្ទាប់ពីការដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការសាកល្បងថវិកាកម្មវិធី ព្រមទាំងការកែលម្អលើសេចក្តីព្រាងច្បាប់តារាងឧបសម្ព័ន្ធ ព្រមទាំងកំណត់បង្ហាញពីសេចក្តីថ្លែងហេតុ។ ចំណែកការអនុវត្តថវិកា ពិតជាមាន

លក្ខណៈល្អប្រសើរច្រើន ជាពិសេសតាមរយៈ ការកាត់បន្ថយនីតិវិធីចំណាយ និងការធ្វើវិសហមជ្ឈការ ការត្រួតពិនិត្យហិរញ្ញវត្ថុ និងការកែលម្អនីតិវិធីលទ្ធកម្មសាធារណៈ ព្រមទាំងការកែលម្អការទូទាត់ និងពង្រឹងការគ្រប់គ្រងសាច់ប្រាក់។ ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម មានវឌ្ឍនភាពតិចតួចរួមទាំងការអនុវត្តថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័នដែលគុណភាពនៃការកំណត់សូចនាករ និងគោលដៅទៅតាមកម្មវិធី និងអនុកម្មវិធីនៅមានកម្រិត។ ចំពោះភាពប្រឈម និងបញ្ហាដែលកើតមានឡើងចំពោះការរៀបចំថវិកា គឺបណ្ដាលមកពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីមិនទាន់បានល្អ ហើយការព្យាករណ៍ចំណូល និងការគណនាតម្រូវការចំណាយនៅមិនទាន់មានភាពសុក្រឹតល្អ។ ចំពោះបញ្ហាប្រឈមនៃការអនុម័តថវិកាវិញ គឺបណ្ដាលមកពីការអនុម័តថវិកា នៅតែផ្អែកលើគណនី ជំពូក ប្រភេទ ដោយសារផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីដែលគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករ មិនទាន់ត្រូវបានអនុវត្តពេញលេញ និងយកមកធ្វើជាមូលដ្ឋានក្នុងការវិភាជន៍ និងអនុម័តនៅឡើយ ហើយដំណើរការនៃការអនុវត្តថវិកានៅមានលក្ខណៈស្មុគស្មាញ និងពុំទាន់ស្របទៅនឹងថវិកាកម្មវិធីនៅឡើយ។

## ២. និយមន័យ

យោងតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ២០០៨ ថវិកា សំដៅដល់សំណុំនៃគណនី ដែលពិពណ៌នាសម្រាប់ឆ្នាំនីមួយៗ អំពីធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ឬស្ថាប័ន ឬរបស់អង្គភាពណាមួយ។ ហើយបើយោងតាមវចនានុក្រមខ្មែរសម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យ ថវិកា មានន័យថា ថង់ យាម ទៃ ដែលសព្វថ្ងៃពាក្យនេះ ប្រើសំដៅបញ្ជីដែលគ្រោង ឬកត់ត្រាទុកនូវប្រាក់ចំណូល និងចំណាយរៀងរាល់ឆ្នាំ ប្រៀបដូចជាថង់សម្រាប់ដាក់ប្រាក់។ ថវិកា គឺជាការពិពណ៌នាអំពីផែនការហិរញ្ញវត្ថុ។ វាគឺជាបញ្ជីនៃការប៉ាន់ប្រមាណនៃចំណូល និងការចំណាយដោយភ្នាក់ងារមួយក្នុងរយៈពេលជាក់លាក់មួយ។ ជាទូទៅថវិកាពិពណ៌នាអំពីរយៈពេលមួយនាពេលអនាគត មិនមែនអតីតកាលទេ។

ពាក្យ ថវិកា មានដើមកំណើតមកពីពាក្យភាសាបារាំង (Bougette) ដែលមានន័យថា កាបូបស្បែក (Leather Bag or Briefcase) ឬកូនស្បោងតូច (Purse)។ ពាក្យនេះ ក៏បានប្រភពមកពីពាក្យអង់គ្លេស ដែលមានន័យថា ស្បោងរបស់ព្រះមហាក្សត្រ ឬប្រាក់កាសរបស់ព្រះមហាក្សត្រ។ តាមប្រពៃណីរបស់អង់គ្លេស ព្រះមហាក្សត្រមិនអាចយកពន្ធ ដោយគ្មានការអនុញ្ញាតពីសភាជាតិឡើយ។ បើយើងពិចារណាលើអត្ថន័យនៃនិយមន័យនេះ យើងនឹងមានការពិបាកស្វែងយល់ អំពីការកំណត់អត្ថន័យជាក់លាក់ពិតប្រាកដ និងពិបាកងាយយល់ ពាក្យថវិកានេះណាស់[37]។

[37] សូមមើល https://en.wikipedia.org/wiki/Budget និង https://www.etymonline.com/word/budget។

នៅក្នុងទ្រឹស្តីសេដ្ឋកិច្ចក្លាសិច (Classic) គំនិតមួយចំនួនអះអាងថា រដ្ឋាភិបាលត្រូវគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមិនគិតពីគោលដៅសេដ្ឋកិច្ច សង្គមកិច្ចនោះឡើយ ពោលគឺត្រូវតែគោរពនូវអាព្យាក្រឹត្យភាពនៃថវិកា ដែលមានន័យថា រដ្ឋមិនចាំបាច់ធានានូវតុល្យភាពសេដ្ឋកិច្ចឡើយ ពីព្រោះតុល្យភាពនេះ នឹងកើតឡើងដោយខ្លួនឯងតាមរយៈ ច្បាប់សេដ្ឋកិច្ច។ ក៏ប៉ុន្តែទស្សនទាននេះ ត្រូវបានគេបោះបង់ចោល នៅដើមសតវត្សទី២០ ជាពិសេសនៅក្នុងឆ្នាំ ១៩២៩ នៅពេលដែលសហរដ្ឋអាមេរិកបានប្រើប្រាស់ថវិកា ជាអាវុធទប់ទល់នឹងខួបនៃវិបត្តសេដ្ឋកិច្ច សម្រាប់រុញច្រានសេដ្ឋកិច្ចឲ្យចាកផុតពីវិបត្តិសេដ្ឋកិច្ចពិភពលោក (វចនានុក្រមបច្ចេកសព្ទសេដ្ឋកិច្ច)។ បច្ចុប្បន្ននេះ សកម្មភាពរបស់រដ្ឋាភិបាលកាន់តែបានពង្រីកធំឡើង ដែលអាចនាំឲ្យតួនាទីរបស់ថវិការដ្ឋ កាន់តែមានភាពស្មុគស្មាញ។ រដ្ឋាភិបាល មានតួនាទីអនុវត្តបេសកម្ម ដ៏សន្ធឹកសន្ធាប់ស្មុគស្មាញ លើគ្រប់វិស័យដើម្បីធានាឲ្យផ្នែកសាធារណៈទាំងអស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ពេញលេញ សមស្រប និងប្រសិទ្ធភាពខ្ពស់[38]។

ដូចនេះរដ្ឋាភិបាល ត្រូវខិតខំប្រមែប្រមូលចំណូលពីក្នុងប្រទេស និងក្រៅប្រទេសដើម្បីឲ្យមានថវិកាគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ដល់ផ្នែកសាធារណៈរដ្ឋបាល ឲ្យដំណើរការបានជាប្រក្រតី និងប្រកបដោយនីរន្តរភាព។ ម្យ៉ាងទៀត ដើម្បីឲ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើនលូតលាស់ និងនយោបាយមានភាពរឹងមាំ រដ្ឋាភិបាលចាំបាច់ត្រូវមានមធ្យោបាយហិរញ្ញវត្ថុ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធឲ្យបានគ្រប់គ្រាន់ និងទំនើប ដូចជាសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ស្ពាន អាគារសាធារណៈផ្សេងៗ។ ការចំណាយលើផ្នែកនេះ ត្រូវការប្រើប្រាស់ធនធានយ៉ាងច្រើន ដូចនេះមានតែរដ្ឋាភិបាលទេដែលមានលទ្ធភាព និងជាអ្នកទទួលបន្ទុក។

ទន្ទឹមនឹងនេះ រដ្ឋាភិបាល ក៏ត្រូវយកចិត្តទុកដាក់ដល់ការងារសេង្គមកិច្ច និងសកម្មភាពផ្សេងៗទៀត ដូចជាការផ្តល់សេវាសាធារណៈ ការផ្តល់ការគាំពារសង្គមកិច្ច ការផ្តល់អាហារូបករណ៍ដល់និស្សិត ការបើកប្រាក់ឧបត្ថម្ភជូនមន្ត្រីជានិវត្តន៍ជន ឬជនដែលបាត់បង់សមត្ថភាពពលកម្ម បែងចែកជំនួយដល់ជនរងគ្រោះដោយគ្រោះធម្មជាតិ និងការផ្តល់ប្រាក់ឧបត្ថម្ភធន ប្រាក់សង្គ្រោះ ឬប្រាក់បម្រុងទុកអន្តរាគមន៍ដល់សហគ្រាឯកជនដែលត្រូវការចាំបាច់។ ដូចនេះថវិកា មានមុខងារធ្វើជាសនិទានកម្មលើការបែងចែក ប្រើប្រាស់ធនធានហិរញ្ញវត្ថុ ដើម្បីជាឧបករណ៍នៃគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុដ៏រឹងមាំធានាឲ្យមានការប្រព្រឹត្តទៅជាប្រក្រតីរបស់ស្ថាប័នសាធារណៈ និងការអនុវត្ត កម្មវិធីនយោបាយរបស់រដ្ឋាភិបាល។ រដ្ឋាភិបាលអាចប្រើប្រាស់ថវិកា សម្រាប់ធានាឲ្យមានតុល្យភាព ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច រក្សាកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រក្នុងសង្គម។

[38] សូមមើល របាយការណ៍ស្រាវជ្រាវស្តីពីបញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅអង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡាក្នុងករណីសក្សាអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ របស់ ហែម ចន្ទី (២០១២) និងខឹមសារិទ្ធ (២០១៨)។

វិសាលភាព នៃថវិការដ្ឋអាស្រ័យដោយសកម្មភាពរបស់រដ្ឋាភិបាល។ ប៉ុន្តែទោះបីជាយ៉ាងណា រដ្ឋាភិបាល ត្រូវតែអនុវត្តតាមគោលនយោបាយដ៏រឹងមាំត្រឹមត្រូវ ដែលបានអនុម័តដោយសភាជាតិ។ យើងអាចនិយាយបានថា ថវិកា គឺជាឧបករណ៍ហិរញ្ញវត្ថុមានលក្ខណៈនយោបាយជាក់លាក់ និងឆ្លុះបញ្ចាំងនូវកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ព្រោះថវិកា គឺជាកម្មវិធីហិរញ្ញវត្ថុរបស់រដ្ឋ ដែលបានរៀបចំឡើងដោយរដ្ឋាភិបាល និងត្រូវបានអនុម័តយល់ព្រមដោយសភាជាតិ។

ថវិកា គឺជាលិខិតគតិយុត្តិដែលក្នុងនោះបានគ្រោង និងបានអនុញ្ញាតឲ្យប្រមែប្រមូលចំណូល និងបែងចែកចំណាយប្រចាំឆ្នាំរបស់រដ្ឋ។ តាមនិយមន័យខាងលើនេះ បានបង្ហាញឲ្យឃើញពីលក្ខណៈរបស់ថវិកាដូចខាងក្រោមៈ

ថវិកា គឺជាលិខិតគតិយុត្តិគ្រោង ព្រោះថវិកាត្រូវរៀបចំឡើង សម្រាប់ការិយបរិច្ឆេទខាងមុខ ដូចនេះ ចាំបាច់ត្រូវតែគ្រោងទុកមុន និងប៉ាន់ស្មានមុនតាមការចង្អុលបង្ហាញទិស របស់រដ្ឋាភិបាល អំពីប្រភេទ និងចំនួនទឹកប្រាក់ចំណូល ដែលអាចប្រមូលបាន សម្រាប់បែងចែកបម្រើឲ្យការចំណាយ។ ការគ្រោងថវិកា គឺជាការលំបាកបំផុត ព្រោះជាញឹកញាប់តែងមានមារខុសគ្នាខ្លាំងរវាងថវិកាអនុម័ត និងថវិកាអនុវត្ត។ ថវិកា គឺជាលិខិតគតិយុត្តិអនុញ្ញាត ព្រោះថវិការដ្ឋ ត្រូវបានសភាជាតិផ្តល់ការអនុញ្ញាតឲ្យប្រមូលចំណូលដាក់ចូលក្នុងបេឡារបស់រដ្ឋ និងអនុញ្ញាតឲ្យប្រតិបត្តិការចំណាយ ដោយកម្រិតទឹកប្រាក់ មិនឲ្យរដ្ឋាភិបាលអនុវត្តចំណាយលើសបានទេ។

ថវិកាមានសណ្ឋានជាច្បាប់ ព្រោះថវិកាត្រូវបានអនុម័តដោយសភាជាតិ។ ដោយសារមូលហេតុនេះហើយ ទើបបានត្រូវបានគេហៅថា ថវិកា ជាច្បាប់ហិរញ្ញវត្ថុ។ ច្បាប់ហិរញ្ញវត្ថុគ្រោង និងអនុញ្ញាត សម្រាប់ឆ្នាំនីមួយៗ នូវសំណុំនៃធនធាន និងបន្ទុកទាំងអស់របស់រដ្ឋ ក្នុងក្របខ័ណ្ឌតម្រង់ទិស និងគោលដៅរបស់ជាតិក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ព្រមទាំងគិតគូរដល់ការថែរក្សាតុល្យភាពហិរញ្ញវត្ថុ និងរូបិយវត្ថុ។ ជារៀងរាល់ឆ្នាំ សភាជាតិបានពិនិត្យ ពិភាក្សា និងអនុម័តច្បាប់ហិរញ្ញវត្ថុលើគម្រោងថវិកា ដែលបានកសាងឡើងដោយរដ្ឋាភិបាល និងអនុញ្ញាតឲ្យប្រមូលធនធាន និងអនុវត្តបន្ទុករបស់រដ្ឋ។ ច្បាប់ហិរញ្ញវត្ថុ ចែកចេញជាច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬច្បាប់ថវិកា ច្បាប់ហិរញ្ញវត្ថុកែតម្រូវ និងច្បាប់ទូទាត់។ ដូចនេះ ថវិកា គឺជាកម្មវិធីហិរញ្ញវត្ថុសម្រាប់សកម្មភាព របស់រដ្ឋាភិបាល ក្នុងរយៈពេលមួយឆ្នាំសារពើពន្ធ ដែលត្រូវបានរៀបចំដោយអង្គនីតិប្រតិបត្តិ និងអនុម័តដោយអង្គនីតិបញ្ញាតិ។ ផែនការថវិការបស់រដ្ឋាភិបាល អាចយកទៅប្រតិបត្តិជាផ្លូវការបាន លុះណាតែមានការអនុញ្ញាតិពីប្រមុខរដ្ឋ។

គោលដៅនៃថវិកា គឺជាការកំណត់ចំណាយ និងចំណូលថវិកា ដែលត្រូវបានអនុម័តយល់ព្រម និងកំណត់នូវនីតិវិធីក្នុងការអនុវត្តចំណូល និងចំណាយរបស់រដ្ឋ។ នៅក្នុងប្រទេសដែលមានការដឹកនាំបែបទំនើបតាមរបប ដែលហៅថារដ្ឋាភិបាលប្រជាធិបតេយ្យទំនើប ថវិកាគឺឆ្លុះបញ្ចាំងពីអន្តរសកម្មភាព

រវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ អង្គការអំណាចនីតិប្រតិបត្តិ មានតួនាទីរៀបចំ និងអនុវត្តតាមផែនការ ដែលបានគ្រោងឡើង ចំណែកអំណាចនីតិបញ្ញត្តិ អនុម័ត និងត្រួតពិនិត្យសកម្មភាពនៃការអនុវត្ត។

## ៣. ចរិតលក្ខណៈនៃថវិកា

នៅក្នុងបណ្ដាប្រទេសមួយចំនួនធំ ថវិកាសេដ្ឋកិច្ច មានសារៈសំខាន់ណាស់។ មូលហេតុជាច្រើនបានបង្ហាញ និងកំណត់ពីលក្ខណៈនៃសកម្មភាពសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ពីព្រោះថវិកា គឺជាការសន្មត់ ការប៉ាន់ស្មាន និងសំណើចំណូល ចំណាយ ដែលក្លាយជាឧបករណ៍នយោបាយ នៃសកម្មភាពការងារ និងជាសកម្មភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុត្រូវបានរួមបញ្ចូល។ នៅពេលបច្ចុប្បន្នមានការផ្លាស់ប្ដូរជាច្រើនក្នុងទម្រង់ថវិកា និងមុខងារនៃរដ្ឋាភិបាល ហើយការផ្លាស់ប្ដូរទាំងនេះ មានដូចជា ការរៀបចំនយោបាយសេដ្ឋកិច្ច គោលការណ៍សេដ្ឋកិច្ច រដ្ឋបាលសាធារណៈ និងគណនេយ្យហិរញ្ញវត្ថុសារធារណៈជាដើម ដែលអាចមានឥទ្ធិពលយ៉ាងខ្លាំង។ ថវិកាទំនើប មិនត្រឹមតែកំណត់ និងខុសត្រូវច្បាប់ ឬអនុម័តដោយអង្គនីតិប្បញ្ញត្តិតែប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងក្លាយជាធាតុនៃផែនការការរៀបចំគ្រោងចំណូល ចំណាយ ដែលត្រូវបានអនុវត្តដោយរដ្ឋាភិបាលតាមកម្មវិធី និងសកម្មភាព។

តាមនិយមន័យ ថវិកា គឺជាឧបករណ៍នៃគោលនយោបាយ ប៉ុន្តែការអនុវត្តជាក់ស្ដែងរដ្ឋាភិបាលនៃប្រទេសភាគច្រើនមកដល់បច្ចុប្បន្ន នៅតែមានការលំបាលក្នុងការធានា និងធ្វើឲ្យសាធារណជនមានជំនឿថា ថវិការបស់រដ្ឋាភិបាល គឺពិតជាឧបករណ៍នៃគោលនយោបាយ ហើយការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល គឺពិតជាដើម្បីបម្រើឲ្យប្រជាពលរដ្ឋ ប្រកបដោយភាពស័ក្ដិសិទ្ធ និងប្រសិទ្ធភាពប្រាកដមែន។ ម្យ៉ាងទៀតសូម្បីតែការគោរពគោលការណ៍ថវិកាដ៏សំខាន់៣ គឺវិន័យថវិកា (រក្សាតុល្យភាព និងចីរភាព) ប្រសិទ្ធភាពនៃវិភាជន៍ថវិកា (ធានាការវិភាជន៍ចំគោលដៅអាទិភាព) និងប្រសិទ្ធភាពបច្ចេកទេស នៃការប្រើប្រាស់ថវិកា (ធានាការប្រើប្រាស់ថវិកាប្រកបដោយភាពស័ក្ដិសិទ្ធ និងប្រសិទ្ធភាព) ក៏រដ្ឋាភិបាលនៃបណ្ដាលប្រទេសមួយចំនួនមកដល់បច្ចុប្បន្ន នៅតែពុំទាន់អាចគោរពបានពេលលេញនៅឡើយ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៣ និង ២០១៥)។

ជាក់ស្ដែងប្រទេសភាគច្រើនមកដល់ពេលនេះ នៅតែប្រឈមនឹងការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ឬ/និងទៅនឹងសកម្មភាព ឬ/និងសមិទ្ធកម្ម ទោះជាសម្រាប់ប្រទេសអភិវឌ្ឍដែលមានប្រព័ន្ធគ្រប់គ្រងថវិកា ប្រកបដោយកម្រិតស្តង់ដារអន្តរជាតិ ប្រើប្រាស់បច្ចេកវិទ្យាទាន់សម័យ និងមានសមត្ថភាពស្ថាប័ន និងធនធានមនុស្សកម្រិតខ្ពស់ក៏ដោយ។ តួយ៉ាងដូចជា បញ្ហាវិបត្តិបំណុលសាធារណៈ និងឱនភាពថវិកាខ្ពស់ហួសហេតុ នៃបណ្ដាប្រទេសមួយចំនួនព្រមទាំងការចំណាយខ្ពស់ហួសព្រំដែនលើវិស័យមួយចំនួនដូចជាវិស័យយោធា និងប្រព័ន្ធសុវត្ថិភាពសង្គម ដែលបានធ្វើឲ្យ

ប្រទេសទាំងនោះធ្លាក់ទៅក្នុងវិបត្តិហិរញ្ញវត្ថុសាធារណៈធ្ងន់ធ្ងរ ដោយសារតែការធ្វេសប្រហែសក្នុងការគោរពគោលការណ៍ថវិកាដ៏សំខាន់ទាំង៣ ដូចដែលបានគូសបញ្ជាក់ខាងលើ។

ទោះបីជាយ៉ាងណា បច្ចុប្បន្នប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាដែលកំពុងពេញនិយម ហើយដែលប្រទេសភាគច្រើនបាននឹងកំពុងប្រឹងប្រែងកសាងឆ្ពោះទៅរក ឬបាននឹងកំពុងបន្តកែលម្អ ឲ្យកាន់តែប្រសើរឡើងតាមរយៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះគឺ ប្រព័ន្ធគ្រង់គ្រង់ហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រងគ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម។

ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្មនេះ គឺជាប្រព័ន្ធដែលផ្សារភ្ជាប់ការវិភាជន៍ថវិកា ទៅនឹងសកម្មភាពជាក់ស្តែង និងកម្មវិធីច្បាស់លាស់ ទៅនឹងគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័ន និងជាពិសេស ទៅនឹងគោលបំណងគោលនយោបាយតាមវិស័យ និងរបៀបវារៈគោលនយោបាយថ្នាក់ជាតិ របស់រដ្ឋាភិបាលដើម្បីធានាថា ថវិកាជាតិពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយ របស់រដ្ឋាភិបាលប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពប្រាកដមែន។

ជាក់ស្តែងស្របតាមនិន្នាការជាសកលនេះ កម្ពុជាបានប្តេជ្ញាធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនឆ្ពោះទៅរកស្តង់ដារអន្តរជាតិ ពោលគឺការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវិធីរយៈពេលវែង មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអនុវត្តតាមយុទ្ធសាស្ត្រ៤ ជំហាន ឬ/និង៤ ដំណាក់កាលគឺ ១.ការបង្កើនភាពទុកចិត្តលើថវិកា ២.ការង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ៣.ការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ និង៤.ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម។

ក្នុងដំណាក់ទីមួយ ត្រូវបានចាប់ផ្តើមដាក់ឲ្យអនុវត្តចាប់ពីចុងឆ្នាំ២០០៤ និងត្រូវបានអនុវត្តពេញលេញនៅឆ្នាំ២០០៥ ហើយត្រូវបានបញ្ចប់ដោយជោគជ័យ ជាមួយនឹងការប្រកាសដាក់ឲ្យអនុវត្តដំណាក់កាលទី២ នៅចុងឆ្នាំ២០០៨ ហើយបញ្ចប់នៅក្នុងឆ្នាំ២០១៥ បន្ទាប់ពីការដាក់ឲ្យអនុវត្តជំហានទី១ នៃប្រព័ន្ធព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានចប់សព្វគ្រប់។ ដំណាក់កាលទី៣ នឹងត្រូវដាក់ឲ្យអនុវត្តព្រមជាមួយនឹងការបញ្ចប់ដំណាក់កាលទី២ នៅចុងឆ្នាំ២០១៥ ជាមួយនឹងការចាប់ផ្តើមជំហានទី១ នៃកំណែទម្រង់ប្រព័ន្ធថវិកានៅដើមឆ្នាំ២០១៥ ដែលត្រូវបានដាក់ឲ្យអនុវត្តពេញលេញនៅឆ្នាំ២០២០ ហើយដែលកំណែទម្រង់ប្រព័ន្ធថវិកានេះ នឹងក្លាយជាកម្លាំងចលករដ៏សំខាន់សម្រាប់ដំណាក់កាលទី៣ ដែលបានបញ្ចប់នៅចុងឆ្នាំ២០២០ ជាមួយនឹងការដាក់ឲ្យអនុវត្តដំណាក់

កាលទី៤ ដែលសង្ឃឹមថា អាចនឹងបញ្ចប់ជាស្ថាពរនូវគោលដៅទាំងបួន នៃកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈទាំងមូលនៅឆ្នាំ២០២៥។

ថវិកាត្រូវមានគោលការណ៍គ្រឹះ១១យ៉ាង ដែលត្រូវអនុវត្តដាច់ខាត ដូចមានចែងក្នុងច្បាប់ស្តីពី ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ត្រង់មាត្រាទី ៥ នោះរួមមាន ១.ភាពជាអាជ្ញា ២.ការបរិច្ឆេទមាន កាលកំណត់មួយឆ្នាំ ៣.ភាពគ្រប់ជ្រុងជ្រោយ ៤.ឯកត្តភាព ៥.សកលភាព ៦.វិសេសភាព ៧.តុល្យភាព ៨.គណនេយ្យភាព ៩.តម្លាភាព ១០.ស្ថិរភាព និង ១១.សមិទ្ធកម្ម។

## ៤. តួនាទី និងសារៈសំខាន់នៃថវិកា

ការធ្វើថវិកា គឺជាផ្នែកដ៏សំខាន់បំផុតមួយ នៃសកម្មភាពការងារ និងសុខុមាលភាពសេដ្ឋកិច្ច នៃសង្គម។ នៅក្នុងសង្គមដ៏មមារញឹក និងស្មុគស្មាញ តឹងតែង ភាពភាពប្រែប្រួល បត់បែនយ៉ាងលឿន និងមានភាពទាន់សម័យទំនើប នៃយុគសម័យថ្មី ដែលត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាល តម្រូវការ និងការឆ្លើយតបទាន់ពេលវេលា និងគ្រប់គ្រាន់នៃតម្រូវការសេដ្ឋកិច្ច សង្គមរបស់ប្រជាជន តាមរយៈ តួនាទី និងមុខងារទាំងបី នៃការវិភាជន៍ធនធានឡើងវិញ បំណែងចែកចំណូលឡើងវិញ ឲ្យមានសម ធម៌ និងរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច ជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងការធ្វើថវិកា និងការអនុវត្តថវិកា។ រាជរដ្ឋាភិបាលប្រើថវិកាជាតិ ជាឧបករណ៍ធ្វើផែនការសម្រាប់កៀរគរចំណូល និងដើម្បីកំណត់ចំណាយ បំពេញសេចក្តីត្រូវការលើផ្នែកអកវិវឌ្ឍ។

ថវិកាដែលរៀបចំបានល្អមួយ គឺជាថវិកាដែលឆ្លុះបញ្ចាំងអាទិភាពគោលនយោបាយសង្គម សេដ្ឋកិច្ច មានឥទ្ធិពលលើសេដ្ឋកិច្ចរបស់ប្រទេស និងអនុញ្ញាតឲ្យរដ្ឋាភិបាលអាចសម្រេចបាននូវការ ការតបន្តភាពក្រក្រី និងគោលដៅអភិវឌ្ឍន៍របស់ខ្លួន។ សារៈសំខាន់នៃផែនការយុទ្ធសាស្ត្រថវិកាមាន ដូចជា៖ ១.ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយ របស់ រដ្ឋាភិបាល ២.បង្កើនវិចារណកម្មអាទិភាពចំណាយ ឲ្យឆ្លើយតបទៅនឹងគោលនយោបាយ របស់ ក្រសួង-ស្ថាប័ន ៣.ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណង គោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ ៤.ជាមូលដ្ឋានសម្រាប់ពន្យល និងបង្ហាញ សេចក្តីសំអាងអំពីតម្រូវការ សម្រាប់អនុវត្តគោលនយោបាយ ៥.ជាមូលដ្ឋានសម្រាប់រៀបចំ និងវិភាជន៍ ប្រចាំឆ្នាំឲ្យចំគោលដៅអាទិភាព។

## ៥. រចនាសម្ព័ន្ធថវិកា

យោងតាមមាត្រាទី ១២ថ្មី នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ២០០៨ ដែលត្រូវបានកែប្រែដោយ បទប្បញ្ញត្តិ គឺថវិកាត្រូវរៀបចំទៅតាមចំណាត់ថ្នាក់ថវិកា ដែលកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សូមមើលមាត្រទី១៥ នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១)។ ធនធានអចិន្ត្រៃយ៍របស់រដ្ឋមានចំណូលចរន្ត និងចំណូលមូលធន។ ចំណូលចរន្ត ត្រូវបាន បែងចែកជា ២ក្រុម និង៣ប្រភេទ ហើយចំណូលមូលធន ត្រូវបានបែងចែកជា២ក្រុម និង៣ប្រភេទ។ ប្រភេទចំណូលនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ ជាជំពូកគណនី អនុគណនី និងជាយថាហេតុអាច លម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៥.១. ចំណូល

ចំណូលចរន្តត្រូវបានបែងចែកជា ២ក្រុម និង៣ប្រភេទគឺ៖

- ក្រុមទី១៖ ចំណូលពិត មាន ២ប្រភេទ
  - ប្រភេទទី១៖ ចំណូលសារពើពន្ធ
  - ប្រភេទទី២៖ ចំណូលមិនមែនសារពើពន្ធ
- ក្រុមទី២៖ ចំណូលតាមដីកា
  - ប្រភេទទី៣៖ ចំណូលតាមដីកា

ចំណូលមូលធនត្រូវបានបែងចែកជា២ក្រុម និង៣ប្រភេទគឺ៖

- ក្រុមទី១៖ ចំណូលពិត
  - ប្រភេទទី១៖ ចំណូលពីប្រភពផ្ទាល់
  - ប្រភេទទី២៖ ចំណូលពីប្រភពខាងក្រៅ
- ក្រុមទី២៖ ចំណូលតាមដីកា
- ប្រភេទទី៣៖ ចំណូលតាមដីកា

## ៥.២. ចំណាយ

ចំណូលទាំងមូលត្រូវវិភាជសម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់។ ប៉ុន្តែចំណូលខ្លះអាចត្រូវ វិភាជសម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់ និងក្រោមល័ក្ខខ័ណ្ឌដែលត្រូវកំណត់ ដោយច្បាប់។ បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមាន ចំណាយចរន្ត និងចំណាយមូលធន។ បន្ទុកនេះត្រូវបាន ចែកជាក្រុម និងប្រភេទ។ ចំណាយមូលធន នៃធនធានថវិកា គឺសម្រាប់ការអនុវត្តកម្មវិធី ការអនុវត្ត គម្រោងវិនិយោគ ការចូលរួមភាគកម្ម និងការទូទាត់បំណុល។ ប្រភេទចំណាយនីមួយៗ ត្រូវបានធ្វើ ចំណាត់ថ្នាក់ជាជំពូកគណនី អនុគណនី និងជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណាយចរន្តនៃថវិកត្រូវបានបែងចែកជា ២ក្រុម និង៦ប្រភេទគឺ៖

ក្រុមទី១៖ ចំណាយពិត

ប្រភេទទី១៖ មធ្យោបាយសេវា

ប្រភេទទី២៖ បន្ទុកហិរញ្ញវត្ថុ

ប្រភេទទី៣៖ អន្តរាគមន៍សាធារណៈ

ប្រភេទទី៤៖ ចំណាយផ្សេងៗ

ក្រុមទី២៖ ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក

ប្រភេទទី៥៖ ចំណាយតាមដីកា

ប្រភេទទី៦៖ ប្រភេទចំណាយមិនបានគ្រោងទុក

ចំណាយមូលធនត្រូវបានបែងចែកជា ២ក្រុម និង៣ប្រភេទគឺ៖

ក្រុមទី១៖ ចំណាយពិត

ប្រភេទទី១៖ ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល

ប្រភេទទី២៖ អចលកម្ម

ក្រុមទី២៖ ចំណាយតាមដីកា

ប្រភេទទី៣៖ ចំណាយតាមដីកា

## ៥.៣. ចំណូល និងចំណាយថវិកាថ្នាក់ជាតិ

ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងក្នុងឆ្នាំ២០២១ ២០២០ និង២០១៩ គិតជាលានរៀល[39]

| | ២០២១ | ២០២០ | ២០១៩ |
|---|---|---|---|
| **ចំណូលក្នុងប្រទេស** | **១៩ ៩២៧ ១៨៦** | **២៤ ០៩២ ៦៦៥** | **១៩ ៧៨៦ ២៦០** |
| ចំណូលចរន្ត | ១៩ ៧០៥ ៩៨៣ | ២៣ ៨៩៩ ៣២៤ | ១៩ ៥៩៣ ១១១ |
| ចំណូលមូលធន | ២២១ ២០៣ | ១៩៣ ៣៤១ | ១៩៣ ១៤៩ |
| **ចំណាយថវិកាសរុប** | **២៩ ៣០៦ ១៤៦** | **២៩ ៩៨៩ ៩៣៣** | **២៤ ៨៥៩ ០៨០** |
| ចំណាយចរន្ត | ១៧ ៤៤៦ ៨៤១ | ១៨ ០៣៦ ៨៨៤ | ១៦ ៨២៧ ២៨០ |
| ចំណាយមូលធន | ១១ ៨៥៩ ៣០៥ | ១១ ៩៥៣ ០៤៩ | ៨ ០៣១ ៨០០ |

[39] សូមមើល៖ ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ២០១៩-២០២១។

## ៦. គោលការណ៍សំខាន់ៗនៃថវិកា

### ៦.១. គោលការណ៍ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ

ថវិកាជាតិ ត្រូវបានរៀបចំ អនុម័ត និងអនុវត្តសម្រាប់រយៈពេលមួយឆ្នាំ។ នៅប្រទេសខ្លះ ឆ្នាំថវិកាដូចគ្នានឹងឆ្នាំតាមប្រតិទិន គឺចាប់ផ្តើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅក្នុងថ្ងៃទី៣១ ខែធ្នូ។ ប៉ុន្តែនៅប្រទេសខ្លះទៀត ការិយកម្មថវិកា ត្រូវបានចាប់ផ្តើម និងបញ្ចប់ទៅវិញខុសពីឆ្នាំតាមប្រតិទិនៈ

- នៅប្រទេសបារាំង ការិយកម្មថវិកាចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។
- នៅប្រទេសអូស្ត្រាលី ការិយកម្មថវិកាចាប់ផ្តើមពីថ្ងៃទី០១ ខែកក្កដា ហើយត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ជារៀងរាលឆ្នាំ។
- នៅប្រទេសអាមេរិក ការិយកម្មថវិកាចាប់ផ្តើមពីថ្ងៃទី០១ ខែតុលា ហើយត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា។
- នៅប្រទេសអង់គ្លេស និងប្រទេសជប៉ុន ការិយកម្មថវិកាផ្តើមពីថ្ងៃទី០១ ខែមេសា ហើយត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែមីនា។

គោលការណ៍ថវិកាប្រចាំឆ្នាំមានន័យថា រាល់ឥណទានប្រចាំឆ្នាំ ជាពិសេសចំណាយចរន្តដែលមិនបានប្រើប្រាស់ និងត្រូវលុបចោលនៅពេលចុងឆ្នាំ។ ចំពោះចំណាយមូលធនឥណទានថវិកា ត្រូវបានចែកចេញជាឥណទានកម្មវិធី ឥណទានភ្ជាប់សន្យា និងឥណទានទូទាត់។ ឥណទានកម្មវិធី គឺជាគម្រោងចំណាយសរុប សម្រាប់កម្មវិធីទាំងមូល ដែលត្រូវបានអនុវត្តក្នុងរយៈពេលជាច្រើនឆ្នាំ។

ចំពោះឥណទានសន្យា គឺជាឥណទានដែលធានាចំណាយក្នុងឆ្នាំ ត្រូវបានផ្តល់ជូនអាណាប័កសម្រាប់ចំណាយចាំបាច់ទាំងឡាយ ដើម្បីអនុវត្តគម្រោងវិនិយោគ ដែលបានគ្រោងដោយច្បាប់ហិរញ្ញវត្ថុ។ ឥណទានភ្ជាប់សន្យា អាចមានតម្លៃគ្មានកាលកំណត់។ ឥណទានេះ ត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់មានការលុបបំបាត់ចោលដោយថាហេតុ។ ឥណទាទូទាត់ គឺជាឥណទាសម្រាប់ទុកឲ្យចេញអណត្តិបើកប្រាក់លើ ការចំណាយ ដែលជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌនៃឥណទានភ្ជាប់សន្យា។

ឥណទានទូទាត់ដែលមិនបានប្រើនៅក្នុងឆ្នាំ ត្រូវលុបចោលនៅពេលបិទបញ្ជីចុងឆ្នាំ និងអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់។ ដូចនេះ ចំពោះចំណាយមូលធន យើងមិនអាចអនុវត្តគោលការណ៍ប្រចាំឆ្នាំបានទាំងស្រុងឡើយ។ ប៉ុន្តែគោលការណ៍ថវិកាប្រចាំឆ្នាំ នៅតែត្រូវបានគោរពដោយយន្តការនៃឥណទានទូទាត់ ដែលជារៀងរាល់ឆ្នាំ រដ្ឋកំណត់ឥណទានថវិកាប្រចាំឆ្នាំសម្រាប់ការអនុវត្តគម្រោងនេះបាន។

## ៦.២. គោលការណ៍ឯកភាព

គោលការណ៍ឯកភាព គឺជាគោលការណ៍ដែលកំណត់ថា គ្រប់ចំណូល ចំណាយទាំងអស់របស់រដ្ឋ ត្រូវបានប្រមូលផ្តុំនៅក្នុងឯកសារថវិកាតែមួយ ដែលនឹងត្រូវបង្ហាញដើម្បីអនុម័តក្នុងពេលជាមួយគ្នា។ គោលការណ៍នេះ ត្រូវបានហាមឃាត់រាល់ការប្រមូលចំណូល និងរាល់ការអនុវត្តចំណាយ ក្រៅពីថវិកា ដែលសភាជាតិបានអនុម័ត។ មានន័យថាត្រូវហាមឃាត់នូវរាល់ការប្រមូលចំណូល ដោយចំពោះ ឬមិនចំពោះ ក្រៅពីចំណូលដែលបានអនុញ្ញាតដោយច្បាប់ ឬបទបញ្ញាដែលពាក់ព័ន្ធ ទោះជាចំណូលនោះស្ថិតក្នុងប្រភេទលក្ខណៈ ឬមានឈ្មោះដូចម្តេចក៏ដោយ។

ទន្ទឹមនឹងនេះ គ្រប់ក្រសួងស្ថាប័នរដ្ឋបាលសាធារណៈទាំងអស់ មិនត្រូវបង្កើនទឹកប្រាក់ នៃឥណទានដែលបានទទួលការអនុម័តរួចហើយពីសភាជាតិ ដោយសំអាងទៅលើប្រភពប្រាក់ចំណូលពិសេសណាមួយឡើយ។ រាល់ចំណូល និងចំណាយរបស់រដ្ឋត្រូវបានគ្រោងទុក និងបានអនុញ្ញាតដោយថវិកា ហើយខ្លឹមសារ និងនីតិវិធីនៃចំណូល ចំណាយនេះ ត្រូវបានកំណត់យ៉ាងម៉ឺងម៉ាត់ដោយច្បាប់បទប្បញ្ញត្តិ និងសេចក្តីណែនាំទាំងឡាយ។

## ៦.៣. គោលការណ៍សកលភាព

គោលការណ៍នេះ តម្រូវឲ្យកត់ត្រាទាំងស្រុងនូវចំណូល ចំណាយទាំងអស់ ដោយមិនអនុញ្ញាតឲ្យកាត់កងគ្នាឡើយ។ ម្យ៉ាងទៀត រាល់ចំណូលទាំងអស់ត្រូវតែប្រមូលចូលថវិការដ្ឋ ដើម្បីប្រើប្រាស់សម្រាប់ចំណាយរួម ដោយហាមប្រើប្រាស់ចំណូលដោយឡែកៗ សម្រាប់ធានាការចំណាយដោយៗឡែកៗ។ ប៉ុន្តែមានចំណូលខ្លះត្រូវបានចាត់ចែងសម្រាប់ចំណាយដោយឡែកក្រោមរូបភាព និងក្នុងល័ក្ខខ័ណ្ឌដែលត្រូវបានកំណត់ដោយច្បាប់។ ចំណូលដែលបានមកពីជំនួយបរទេស តែងតែអនុវត្តផ្ទុយពីគោលការណ៍សកលភាពថវិកា ពីព្រោះជាទូទៅកិច្ចការប្រតិបត្តិការចំណូល ចំណាយថវិកានេះ (ការប្រើប្រាស់ជំនួយ) ត្រូវបានអនុវត្តទៅតាមល័ក្ខខ័ណ្ឌរបស់ប្រទេសផ្តល់ជំនួយ។ ជំនួយត្រូវបានកត់ត្រាជាចំណូល ប៉ុន្តែរដ្ឋាភិបាលមិនអាចប្រើប្រាស់ជាចំណាយតាមទំនើងចិត្តបានទេ។ ម្ចាស់ជំនួយ និងអ្នកទទួលខុសត្រូវជំនួយ ត្រូវតែឯកភាពគ្នាលើបញ្ហាបច្ចេកទេស និងលើការប្រើប្រាស់ជំនួយទាំងនេះ។

## ៦.៤. គោលការណ៍ឯកទេសភាព

ឥណទានថវិកា ត្រូវបានចែកជូនក្រសួង ស្ថាប័នសាធារណៈ ទៅតាមមាតិកានៃខ្ទង់ថវិកាដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមជំពូក គណនី និងអនុគណនី។ ខ្ទង់ថវិកា គឺជាការអនុញ្ញាតឲ្យក្រសួង ស្ថាប័នសាធារណៈមួយ អនុវត្តកិច្ចប្រតិបត្តិការការចំណាយ ក្នុងកម្រិតទឹក

ប្រាក់ដែលបានកំណត់ និងអនុវត្តទៅតាមច្បាប់ និងបទបញ្ញាជាកំណត់។ ចំពោះ ចំណាយមួយត្រូវបានធានាដោយឥណទានមួយ។

ផ្អែកលើគោលការណ៍នេះ ត្រូវបានហាមឃាត់រាល់ការកែប្រែចំពោះឥណទានថវិកា និងរាល់កិច្ចការចុះបញ្ជីកាឲ្យខ្ទង់ផ្សេងៗ ក្រៅពីខ្ទង់ដែលបានគ្រោងបម្រុងទុក សម្រាប់ចំណាយនោះ។ គោលការណ៍ឯកទេសភាពឥណទានចង់ឲ្យឥណទានដែលបានអនុម័តដោយសភាជាតិ ត្រូវបានយកទៅប្រើប្រាស់លើការចំណាយតាមការកំណត់។ ការផ្ទេរ និងការបង្វែរឥណទានពីខ្ទង់ថវិកាមួយទៅខ្ទង់ថវិកាមួយទៀត ត្រូវអនុវត្តទៅតាមច្បាប់ និងបទបញ្ញាជាធរមាន។

## ៦.៥. គោលការណ៍តុល្យភាព

ថវិកា ត្រូវបានរៀបចំឡើងដោយគោរពទៅតាមគោលការណ៍តុល្យភាព។ ប៉ុន្តែនៅក្នុងកិច្ចប្រតិបត្តិការជាក់ស្តែង ថវិកាកម្រជួបតុល្យភាពណាស់ ព្រោះជាញឹកញយតែងជួបប្រទះនឹងឱនភាព។ នៅក្នុងការអនុវត្ត យើងតែងតែជួបនូវមូលហេតុបីយ៉ាង ដែលនាំឲ្យមានឱនភាពដូចជា៖

- ការប្រមូលចំណូលពុំអាចសម្រេចបានតាមផែនការដោយជួបប្រទះនូវឧបសគ្គផ្សេងៗ
- ការគ្រោងចំណាយមិនត្រូវ និងមានតម្រូវការចំណាយកើនឡើងខ្ពស់
- បំណុលកកស្ទះឆ្នាំចាស់

ដើម្បីទប់ទល់នឹងឱនភាពនេះ រដ្ឋាភិបាលមានមធ្យោបាយ និងដំណោះស្រាយដូចខាងក្រោម៖

- មធ្យោបាយពន្ធដារ៖ ដំឡើង និងបង្កើតពន្ធថ្មីដើម្បីកៀរគរចំណូលឲ្យអស់លទ្ធភាព
- មធ្យាបាយហិរញ្ញប្បទាន៖ ស្នើសុំជំនួយ កម្ចីក្នុងស្រុក និងកំចីបរទេស
- មធ្យោបាយធនាគារកណ្តាល៖ ខ្ចីប្រាក់ពីធនាគារកណ្តាល ឬបោះពុម្ពក្រដាស់ប្រាក់ថ្មី
- មធ្យោបាយថវិកា៖ រឹតត្បិត និងត្បិតត្បៀតចំណាយដែលមិនចាំបាច់

## ៧. ក្របខ័ណ្ឌប្រព័ន្ធថវិកា

ដំណើរការធ្វើថវិកាមិនមែនគ្រាន់តែជាព្រឹត្តិការណ៍មួយ ឬឯកសារមួយប៉ុណ្ណោះទេ ប៉ុន្តែគឺជាដំណើរការជាបន្តមួយ ចាប់តាំងពីការធ្វើផែនការដំបូង រហូតការអនុវត្តថវិការ និងការទទួលបានសមិទ្ធកម្ម។ ប្រព័ន្ធថវិកាជាតិ ត្រូវបានកំណត់តាមរយៈ ការកែលម្អទៅលើដំណាក់កាលទាំង៤ នៃវដ្តថវិកា គឺការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម។

## ៧.១. ក្របខ័ណ្ឌនយោបាយ

ការរៀបចំថវិកា មិនមែនធ្វើឡើងដើម្បីគ្រាន់តែជាកម្មវត្ថុនៃបទបញ្ញានោះទេ តែផ្ទុយទៅវិញ គឺត្រូវបានធ្វើឡើងសម្រាប់ដាក់ជូនសភាជាតិអនុម័ត។ ម្យ៉ាងទៀត ដូចដែលបានបង្ហាញរួចមកហើយថា ថវិកា គឺជាឧបករណ៍គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដូចនេះ ការរៀបចំថវិកាត្រូវតែឲ្យស្របទៅតាមគោលដៅយុទ្ធសាស្ត្រ និងអាទិភាពរបស់រដ្ឋាភិបាល ដែលបានកំណត់។ រដ្ឋាភិបាលនឹងរៀបចំគម្រោងថវិកាមួយក្នុងគោលបំណង មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីដឹកនាំនយោបាយរបស់ប្រទេសជាតិឲ្យមានលក្ខណៈប្រសើរឡើង។ មិនត្រឹមតែប៉ុណ្ណោះ ការរៀបចំថវិកាត្រូវបានគិតគូទៅដល់កំណើនសេដ្ឋកិច្ច និងសម្រេចឲ្យបាននូវតុល្យភាព ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ចំណូល និងចំណាយរបស់រដ្ឋាភិបាល មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយ។

ប្រទេសកំពុងអភិវឌ្ឍជាច្រើន តែងជួបប្រទះជាប្រចាំនូវការបាត់បង់តុល្យភាព រវាងចំណូល និងចំណាយ។ ប្រទេសទាំងនោះ ត្រូវពឹងផ្អែកសំខាន់ទៅលើជំនួយ ឬការខ្ចីប្រាក់ពីក្រៅប្រទេស ដើម្បីបំពេញតុល្យភាពថវិកា។ ក៏ប៉ុន្តែមធ្យោបាយទាំងនោះ អាចធ្វើឲ្យប្រទេសកំពុងអភិវឌ្ឍជួបប្រទះនូវការបញ្ហាជាច្រើន ដោយសារតែការលូកដៃចូលជ្រៀតជ្រែកពីប្រទេស ដែលជាម្ចាស់ជំនួយ ក្រោមល័ក្ខខ័ណ្ឌ និងសកម្មភាពនយោបាយ។ ទោះបីជាយ៉ាងនេះ ភារកិច្ចរបស់រដ្ឋាភិបាល នៅតែមានឧត្តមានុភាពខ្ពស់ទៅលើផែនការបច្ចេទេសសេដ្ឋកិច្ច ក្នុងការរៀបចំគម្រោងថវិកា។

## ៧.២. ក្របខ័ណ្ឌសេដ្ឋកិច្ច

ការរៀបចំថវិកា គឺជាការប៉ាន់ស្មានចំណូល និងចំណាយរបស់រដ្ឋដោយផ្អែកតាមសម្មតិកម្មសេដ្ឋកិច្ច និងផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការព្យាករណ៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ រូបិយវត្ថុ ការជះឥទ្ធិពលពីអតិផរណា និងឱនភាពនៃជញ្ជីងទូទាត់ ការតាមដាននិន្នាការវិវត្តនៃសេដ្ឋកិច្ចសកល ការប្រែប្រួលនៃអត្រាប្តូរប្រាក់ ជាដើម។ ការប៉ាន់ស្មានអំពីចំណូល ត្រូវបានគិតទៅដល់ប្រភពចំណូលទាំងអស់របស់រដ្ឋ ដែលរួមមានចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ជំនួយ និងការខ្ចីប្រាក់។ ម្យ៉ាងទៀត ក៏ត្រូវពិចារណាពីប្រភពចំណូលថ្មីៗ ដែលអាចមានលទ្ធភាពគៀគរ និងទទួលបានផងដែរ។ ចំពោះចំណាយត្រូវគ្រោងនូវចំណាយចាំបាច់មួយចំនួនដូចជា ចំណាយបៀវត្សមន្ត្រីរាជការ និងចំណាយសាធារណៈលើទំនិញ និងសេវាសធារណៈ។

ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិកាការទៅតាមការណែនាំចង្អុលបង្ហាញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការកសាងគម្រោងថវិកានេះ ត្រូវឈរលើមូលដ្ឋាន នៃការប្រមូលទិន្នន័យ តួលេខ និងការប៉ាន់ស្មាន ព្យាករណ៍ចំណូល ចំណាយ និងការស្នើសុំចំណាយរបស់ផ្នែកនានា ត្រូវឲ្យមានលក្ខណៈសមស្របតាមគោលដៅថវិការបស់រដ្ឋាភិបាល។ ក្រសួង ស្ថាប័ន

ត្រូវបញ្ជាក់អំពីមូលហេតុឲ្យបានច្បាស់ ក្នុងករណីដែលគម្រោងថវិកា មានការប្រែប្រួល ធៀបនឹងឆ្នាំមុន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវប្រមូលផ្តុំគម្រោងចំណូល ចំណាយដែលក្រសួង ស្ថាប័ននីមួយៗបានរៀបចំ និងកសាងឡើង ហើយត្រូវពិនិត្យ និងកែសម្រួលឡើងវិញនូវគម្រោងថវិការបស់ក្រសួង ស្ថាប័នទាំងអស់ ព្រមទាំងអនុញ្ញាតិឲ្យអ្នកទទួលខុសត្រូវ ក្នុងការរៀបចំថវិកាជូនព័ត៌មាន និងយោបល់ពាក់ព័ន្ធទៅនឹងកម្មវត្ថុ ដែលបានលើកឡើងនៅក្នុងគម្រោងថវិការបស់ខ្លួន។ ចំពោះឥណទានសម្រាប់ក្រសួង ស្ថាប័ននីមួយៗ គឺត្រូវកំណត់នូវចំនួនអតិបរមាដែលមិនអាចប្រើប្រាសលើសបាន និងបង្កើតបានជាថវិការដ្ឋ ហើយអាចហៅបានថាជាច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ។

ការរៀបចំថវិកា គឺជាការងារដែលត្រូវប្រើប្រាស់ពេលវេលាយូរ ស្មុគស្មាញ និងត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ហ្មត់ចត់ ប្រាកដជាក់ច្បាស់ ដែលទាមទារឲ្យមានការចូលរួមពីមន្ត្រីមានសមត្ថភាព និងមានឯកទេសច្រើនរូប។ ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ការរៀបចំថវិកា ត្រូវតែផ្អែកលើមូលដ្ឋានតុល្យភាពសេដ្ឋកិច្ច និងតុល្យភាពហិរញ្ញវត្ថុ។

## ៧.៣ ក្របខ័ណ្ឌនៃការរៀបចំថវិកានៅកម្ពុជា

មាត្រាទី ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំចែកជា ៣ ដំណាក់កាល៖ ដំណាក់កាលទី១. គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ ខែឧសភា។ ដំណាក់កាលទី២. គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែកញ្ញា និងដំណាក់កាលទី ៣. គឺការអនុម័តថវិកា ចាប់ពី ខែតុលា ដល់ខែធ្នូ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រតិទិនដូចខាងក្រោមនេះ៖

### ១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែ មីនា ដល់ខែ ឧសភា)

នៅសប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាព ទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិ សម្រាប់ការអភិវឌ្ឍដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលបានកំណត់ដោយរាជរដ្ឋាភិបាល។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើសារាចរណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និងផែនការសម្មភាពជាអាទិភាពរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបម្រើឲ្យគោលនយោបាយអាទិភាពរបស់វិស័យ និងគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ។ ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែឧសភា។

## ២. ការរៀបចំកញ្ចប់ថវិកា (ពីខែ មិថុនា ដល់ ខែកញ្ញា)

នៅសប្ដាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសេចក្ដីព្រាងសារាចរណែនាំស្ដីបច្ចេកទេសនៃការរៀបចំគ្រោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញ និងឯកសារពាក់ព័ន្ធ ដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចហើយផ្ញើជូនក្រសួង ស្ថាប័នអង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្ដីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និងអាទិភាពនៃគោលនយោបាយរបស់ខ្លួន។ គម្រោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការប្រមូលផ្ដុំបូកសរុបនូវគម្រោងចំណូល ចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលខេត្ត និងរាជធានីដែលបានស្នើឡើង។ នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ព្រមទាំងអភិបាលគ្រប់ខេត្ត និងរាជធានី មកពិភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូល ចំណាយថវិកាទាំងនោះ ឲ្យបានសមស្របតាមបទប្បញ្ញត្តិនៃការណែនាំ ដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និងបង្កើនចំណូលឲ្យបានសមស្រប។

នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ។

### ៣. ការអនុម័តថវិកា (ពីខែ តុលា ដល់ខែធ្នូ)

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទីមួយនៃខែធ្នូ ដើម្បីឲ្យសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុខថ្ងៃទី២៥ ខែធ្នូ។ ដំណើរការនៃការអនុម័តច្បាប់ថវិកានៅក្នុងរដ្ឋសភា មានដំហាននៃដំណើរការដូចខាងក្រោម៖

- ដំហាននៃដំណើរការទី១៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់សេចក្តីព្រាងច្បាប់ថវិកាជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។
- ដំហាននៃដំណើរការទី២៖ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្តីព្រាងច្បាប់នេះជូនគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា។
- ដំហាននៃដំណើរការទី៣៖ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភាសិក្សាលម្អិត ដោយគិតគូរដល់ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច យុទ្ធសាស្ត្រគោលនយោបាយ និងគោលបំណងអភិវឌ្ឍជាតិជាដើម។
- ដំហាននៃដំណើរការទី៤៖ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភាកោះប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិភាក្សា និងកសុំការបំភ្លឺ។ ប្រធាន និងអនុប្រធាន និងលេខាធិការនៃគណៈកម្មការផ្សេងៗទាំងអស់ក្នុងរដ្ឋសភាបានអញ្ជើញចូលរួមនៅក្នុងនោះ ការបំភ្លឺអាចត្រូវបានទាមទារលើបញ្ហានានាទាក់ទិននឹងវិស័យអាទិភាព និងការទទួលខុសត្រូវរបស់ខ្លួន។ សេចក្តីព្រាងច្បាប់ថវិកាត្រូវបានដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាសម្រាប់ការបោះឆ្នោត អនុម័ត តាមវិធីដូចគ្នានឹងច្បាប់ផ្សេងៗទៀតដែរ។

## ៤. ដំណើរការរៀបចំថវិកា

### ៤.១ ដំណើរការរៀបចំចំណូល

ការរៀបចំថវិកាត្រូវគោរពបទប្បញ្ញត្តិ ដែលមានចែងនៅក្នុងមាត្រាទី១ មាត្រាទី២ និងមាត្រាទី៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។ ការគ្រោងចំណូលចរន្តត្រូវឈរលើមូលដ្ឋាននៃប្រភពធនធាន ដែលបានមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។

១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគ្រោងដោយផ្ទាល់នូវចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដែលជាកម្មវត្ថុនៃការប្រមូលនៅក្រោមសមត្ថកិច្ចរបស់ខ្លួន និងគ្រោងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធបានមកពីសហគ្រាសសាធារណៈ។

២.រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលគ្រប់ខេត្ត និងរាជធានីដែលមានចំណែកក្នុងការគ្រប់គ្រងចំណូលក្រោមសមត្ថកិច្ចរបស់ខ្លួន ត្រូវផ្ញើរមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវបញ្ជីរាយគ្រប់មុខចំណូល និងបញ្ជីប៉ាន់ស្មានចំណូលទាំងអស់ ដើម្បីកត់ត្រាក្នុងគម្រោងចំណូលនៃថវិកាឲ្យបានពេលលេញ និងត្រឹមត្រូវ។ ចំណូលទាំងនេះ ជាចំណែកមិនអាចបំបែកបាននៃចំណូលសរុបនៃថវិការដ្ឋ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគ្រោងចំណូលមូលធន ដោយឈរលើមូលដ្ឋាន នៃប្រភពធនធានបានមកពី៖

១. ចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ

២. ការសងបំណុល និងសងបុរេប្រទានដោយសហគ្រាសសាធារណៈ ដែលត្រូវកត់ត្រាឲ្យបានក្នុងតារាងរំលស់។

៣. រាល់ប្រភពចំណូលពីការខ្ចីក្នុងប្រទេស ដោយមានការសម្រេចយល់ព្រម ពីរាជរដ្ឋាភិបាលដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវវាយតម្លៃ និងវិភាគលើស្ថានការណ៍សេដ្ឋកិច្ច និងចរិតនៃការខ្ចី ដោយសហការជាមួយទេសាភិបាលធនាគារជាតិនៃកម្ពុជា។

៤. ហិរញ្ញប្បទានក្រៅប្រទេស ក្រោមរូបភាពជាហិរញ្ញប្បទានឥតសំណង សម្រាប់វិនិយោគ ឬការខ្ចីដែលត្រូវកត់ត្រា ក្នុងគម្រោងចំណូលទៅតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង។ ធនធានសម្រាប់ទ្រទ្រង់ថវិកា និងសម្រាប់គម្រោងត្រូវវាយតម្លៃទៅតាមលំហូរមូលនិធិ និងវឌ្ឍនភាពនៃការអនុវត្តគម្រោង។ មូលនិធិបដិភាគក្រោមរូបភាពជាទំនិញ ត្រូវគ្រោងជាចំណូល នៃថវិការដ្ឋនូវចំនួនទឹកប្រាក់ ដែលរំពឹងទុកតាមកម្មវិធីនៃការនាំចូលទំនិញទាំងនេះ។

៥. ចំណូលមូលធនផ្សេងទៀត។

## ៨.២. ដំណើរការរៀបចំចំណាយ

គម្រោងចំណាយចរន្ត និងចំណាយមូលធន ត្រូវបានរៀបចំឡើងដោយរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គ្រប់សេវា និងសកម្មភាពទាំងមូល។ ការគ្រោងនៃតម្រូវការថវិកា ត្រូវផ្អែកលើគោលការណ៍ច្បាប់ និងគោលបំណងនៃគោលនយោបាយ កម្មវិធី សកម្មភាព និងលទ្ធផលរំពឹងទុកដោយហ្មត់ចត់ និងច្បាស់លាស់។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតនិយាម និង

ឯកតារង្វាស់សម្រាប់រាល់សកម្មភាពការងារ ដែលមានលក្ខណៈផ្សេងៗគ្នា ព្រមទាំងសម្រាប់ទ្រព្យ និងសេវាដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំណាយមូលធន ត្រូវផ្អែកលើកម្មវិធី ឬគម្រោងដោយឡែកៗ ដែលមានការយល់ព្រមជាមុន និងដែលត្រូវបានរៀបចឡើង សំដៅសម្រេចឲ្យបាននូវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ កម្មវិធី ឬគម្រោងទាំងអស់នោះ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយមូលធនសរុបរបស់កម្មវិធី និងគម្រោង និងសម្រាប់កំណត់រយៈពេល នៃការសន្យា និងការទូទាត់សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ។

ដើម្បីគោរពតាមប្រតិទិននៃមាត្រាទី៣៩ នៃច្បាប់នេះ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធក្នុងការគ្រោងចំណូល ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនបានលើគម្រោងចំណូល ចំណាយរបស់ខ្លួនតាមកាលកំណត់ដោយផ្អែកលើលទ្ធផលនៃឆ្នាំកំពុងអនុវត្ត។

## ៨.៣. របាយការណ៍ដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវ៖

១. របាយការណ៍វិភាគពីនិន្នាការ និងការវិវត្តរួម នៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និងការវិភាគលើចរិតលក្ខណៈ នៃថវិកាថ្មីព្រមទាំងបញ្ជាក់អំពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្ត ពិសេសតុល្យភាពថវិកា។

២. របាយការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងនិន្នាការចំណាយចរន្ត ដោយវិភាគ និងបង្ហាញពីស្ថានភាពឥណនា ពាក់ព័ន្ធនឹងការអនុម័តឆ្នាំមុន ទៅនឹងតម្រូវការ និងវិធានការថ្មី ដែលមានសារៈសំខាន់ចាំបាច់សម្រាប់ការគ្រប់គ្រងថ្មី។

៣. កម្រងកម្មវិធី និងគម្រោងចំណាយមូលធន ដែលរំលេចនូវឥណទាន វិនិយោគឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់កម្មវិធី និងគម្រោងក្នុងឆ្នាំ ការគ្រោងបម្រុងឥណទានដែលមានប្រភេទដូចគ្នា ចាំបាច់សម្រាប់បន្តកម្មវិធី និងគ្រោងទាំងនេះ និងការវិភាគកម្មវិធី និងគម្រោងថ្មី ព្រមទាំងតម្រូវការឥណទាន សម្រាប់កម្មវិធី និងគម្រោងថ្មីទាំងនេះ ដោយកំណត់តាមប្រតិទិនប្រើប្រាស់ដែលបានគ្រោងទុក។

៤. ឯកសារពាក់ព័ន្ធផ្សេងៗទៀត ដែលចាំបាច់សម្រាប់ជាព័ត៌មាន និងសម្រាប់ត្រួតពិនិត្យរបស់រដ្ឋសភា និងព្រឹទ្ធសភា។

### ៨.៤. សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំចែកចេញជាពីរផ្នែក៖

- ផ្នែកទី១៖ សេចក្តីព្រាងច្បាប់អនុញ្ញាតឲ្យប្រមូលគ្រប់ធនធានសាធារណៈ និងកំណត់ធនធានទាំងនោះជាទឹកប្រាក់សរុប។ សេចក្តីព្រាងច្បាប់ត្រូវកំណត់ទិសដៅ និងមធ្យោបាយអនុវត្តចំពោះចំណាយមូលធន។ សេចក្តីព្រាងច្បាប់ បានកំណត់នូវឥណទានត្រូវផ្តល់ខ្ពស់បំផុត ដែលជាគុណប្រយោជន៍ដល់ថវិការដ្ឋ និងគណនីពិសេសរបស់រតនាគាជាតិ។ សេចក្តីព្រាងច្បាប់រួមមាន បទប្បញ្ញត្តិទាំងឡាយដែលទាក់ទងដល់ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលមូលធន និងទាក់ទងដល់គ្រប់បទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត។
- ផ្នែកទី២៖ រួមមានតារាងបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ដែលទាក់ទងដល់ចំណូលនៃថវិការដ្ឋ។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយចរន្ត របស់ថវិការដ្ឋ បែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ហើយបែងចែកទៅតាមប្រភេទចំណាយ ដែលត្រូវអនុម័ត។ សេចក្តីព្រាងច្បាប់មានគម្រោងចំណាយមូលធនបែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល និងជាជំពូក ដែលចែកចេញជាឥណទានភ្ជាប់សន្យា និងឥណទានទូទាត់។ សេចក្តីព្រាងច្បាប់ ត្រូវកំណត់បញ្ជីគណនីពិសេសរបស់រតនាគារជាតិ ដែលមានលក្ខណៈរដ្ឋបាល និងកំណត់គណនីពិសេសនីមួយៗនូវចំនួនទឹកប្រាក់ចំណូល និងចំនួនទឹកប្រាក់ចំណាយ។

## ៩. ការអនុម័តច្បាប់ហិរញ្ញវត្ថុ

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវអនុម័តដោយរដ្ឋសភា និងពិនិត្យដោយព្រឹទ្ធសភា និងត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រម ហើយត្រូវបោះផ្សាយឲ្យអនុវត្ត ជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី០១ ខែមករា នៃឆ្នាំការិយបរិច្ឆេទទេនោះ ថវិកាឆ្នាំមុខត្រូវបានបន្តដោយស្របតាមច្បាប់ក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម៖

១. ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលគ្រប់ប្រភេទផ្សេងៗទៀតត្រូវអនុញ្ញាត និងបន្តឲ្យប្រមូលក្នុងល័ក្ខខ័ណ្ឌ និងតាមបែបបទ ដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និងក្នុងក្របខ័ណ្ឌច្បាប់ ព្រមទាំងបទបញ្ជា ដែលមានជាធរមាន។

២.ចំណាយចរន្ត ក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុខ ដោយគិតតាមវិធីមួយភាគដប់ពីរជាបណ្តោះអាសន្នក្នុងខែនីមួយៗរហូតដល់ថវិកាថ្មីត្រូវបានអនុម័ត។

៣. ចំណាយមូលធននៃថវិកាក្រៅពីរំលស់បំណុលសាធារណៈ នៅតែបន្តអនុវត្តតាម ក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ក្នុងក្របខ័ណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយអាច លើសពីនេះប្រសិនបើចាំបាច់ ដោយមិនឲ្យការទូទាត់នោះលើសពីកម្រិតឥណទាន ភ្ជាប់សន្យា ដែលបានអនុម័តក្នុងថវិកាឆ្នាំមុន។

៤. ចំណាយទាំងឡាយ ដែលជាកាតព្វកិច្ចទាក់ទងទៅនឹងសមាជិកភាពរបស់កម្ពុជា ក្នុងស្ថាប័នអន្តរជាតិ និងអន្តររដ្ឋាភិបាល និងកាតព្វកិច្ចទាក់ទងទៅនឹងបន្ទុកបំណុល សាធារណៈរួមមានការរំលស់ប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ឬការបង់ ពិន័យជាយថាហេតុ ត្រូវបានរ៉ាប់រងជាបន្តមិនឲ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន។

ច្បាប់ហិរញ្ញវត្ថុ ត្រូវបានអនុម័តក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងច្បាប់ដទៃទៀតដែរ លើកលែងតែករណី ពិសេសដូចខាងក្រោម៖

- គម្រោងចំណូល ត្រូវបានអនុម័តសរុបជាកញ្ចប់ទាំងមូល សម្រាប់ចំណូលចរន្តទាំង សម្រាប់ចំណូលមូលធន
- គម្រោងចំណាយ ត្រូវបានអនុម័តជាសរុបទាំងប្រភេទចំណាយចរន្ត ទាំងប្រភេទ ចំណាយមូលធនលើបញ្ជីក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល
- ចំពោះគណនីពិសេសរបស់រតនាគារជាតិ ត្រូវអនុម័តសរុបជាកញ្ចប់លើបញ្ជីនៃគណនី ទាំងអស់ដែលមាន
- បទប្បញ្ញត្តិទាំងអស់នៃច្បាប់ហិរញ្ញវត្ថុជាកម្មវត្ថុនៃការអនុម័តចុងក្រោយបង្អស់។

គ្មានវិសោធនកម្មណាមួយលើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ អាចត្រូវបានអនុញ្ញាតឲ្យធ្វើនោះទេ ប្រសិនបើវិសោធនកម្មនោះ ធ្វើឲ្យប៉ះពាល់ដល់តុល្យភាពនៃគម្រោងថវិកា ដែលបានស្នើឡើង។ វិសោធនកម្មប្រភេទនេះ អាចធ្វើទៅបានតែក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម៖

- សំណើចំណាយថ្មីត្រូវបានធ្វើឡើង ដោយមានភ្ជាប់ជាមួយនូវសំណើរសន្សំសំចៃលើប្រភេទ ចំណាយណាមួយ ដែលបានស្នើឡើងរួចហើយ ដើម្បីរក្សាតុល្យភាពថវិកា
- សំណើចំណាយថ្មីត្រូវបានធ្វើឡើង ដោយមានភ្ជាប់ជាមួយនូវសំណើបង្កើតមុខចំណូលថ្មី ឬបង្កើនចំណូល ដើម្បីរក្សាតុល្យភាពថវិកា

វិសាធនកម្មដែលធ្វើឡើងផ្ទុយនឹងបទប្បញ្ញតិខាងលើនឹងត្រូវបានបដិសេធ ហើយទុកជាមោឃៈ។

## ១០. ការអនុវត្តថវិកា

### ១០.១. ក្របខ័ណ្ឌនៃការអនុវត្តថវិកា

ការផ្ទេរឥណទានពីក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយ ពីស្ថាប័នមួយ ឬពីអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ដោយភាពចាំបាច់នៃការងារពង្រឹងរចនាសម្ព័ន្ធ ឬរដ្ឋបាលរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានតាមអនុក្រឹត្យព ក្នុងករណីផ្ទេរឥណទាននេះមិនកែប្រែមុខចំណាយ និងការបែងចែកឥណទានតាមជំពូកនីមួយៗទេ។

ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយនៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬពីអង្គភាពសាធារណៈប្រហាក់ប្រហែលត្រូវធ្វើឡើងដោយអនុក្រឹត ក្នុងករណីមិនកែប្រែឥណទានចំណាយមូលធនសម្រាប់វិនិយោគទៅជាឥណទានចំណាយចរន្តសម្រាប់ដំណើរការ។ ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬពីអនុគណនីមួយទៅអនុគណនីមួយនៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អនុក្រឹត្យដែលធ្វើឡើងតាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបែងចែងឥណទានថវិកាដែលកត់ត្រានៅក្នុងចំណាយមិនបានគ្រោងទុក ក្រោមរូបភាពនៃឥណទានបន្ថែមជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលនានា។ ឥណទានដែលលែងមានមុខសញ្ញាប្រើប្រាស់នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា អាចត្រូវបានលុបចោលដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានទទួលព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅពេលដែលការវិវត្តនៃចំណូល និងចំណាយស្តែងចេញឲ្យឃើញនូវការបាត់បង់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញជាប្រកាស ដើម្បីបង្កកមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ ក្នុងករណីដែលការបាត់បង់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចធ្វើនីតិវិធីតាមអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យបន្ថែមឥណទានដើម្បីប្រើប្រាស់។ ឥណទាននេះត្រូវអនុម័តដោយច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែលរដ្ឋាភិបាលសុំការយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំង

នេះត្រូវបានចប់សព្វគ្រប់។ ដោយបដិបញ្ញត្តិនៃកថាខ័ណ្ឌខាងលើនៃច្បាប់នេះ បើច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុនេះពុំអាចធ្វើទៅកើតក្នុងត្រីមាសទី៤ នៃការិយច្ឆេទនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ឥណទានទាំងនេះជាកម្មវត្ថុ នៃនិយ័តភាវូបនីយកម្មក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់។ ការកែប្រែផ្សេងៗទៀតលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាអនុម័តដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ។

## ១០.២. ការអនុវត្តថវិកា

ការផ្ទេរឥណទានពីក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយ ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ដោយភាពចាំបាច់នៃការងារពង្រឹងរចនាសម្ព័ន្ធ ឬរដ្ឋបាលរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងករណីការផ្ទេរឥណទាននេះ មិនកែប្រែមុខចំណាយ និងការបែងចែកឥណទានតាមជំពូកនីមួយៗទេ។

ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយនៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលត្រូវធ្វើឡើងដោយអនុក្រឹត្យ ក្នុងករណីមិនកែប្រែឥណទានចំណាយមូលធនសម្រាប់ការវិនិយោគទៅជាឥណទានចំណាយចរន្តសម្រាប់ដំណើរការ។ ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយនៅក្នុងជំពូកតែមួយត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អនុក្រឹត្យដែលធ្វើឡើងតាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបែងចែកឥណទានថវិកា ដែលកត់ត្រានៅក្នុងចំណាយមិនបានគ្រោងទុកក្រោមរូបភាពនៃឥណទានបន្ថែមជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលនានា។ ឥណទានដែលលែងមានមុខសញ្ញាប្រើប្រាស់នៅក្នុងការិយច្ឆេទនៃឆ្នាំថវិកាអាចត្រូវបានលុបចោលដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោយពីបានទទួលព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅពេលដែលការវិវត្តនៃចំណូល និងចំណាយស្តែងចេញឲ្យឃើញនូវការបាត់បង់តុល្យភាពថវិការដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញជាប្រកាសដើម្បីបង្កកមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ ក្នុងករណីដែលការបាត់បង់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចធ្វើនីតិវិធីតាមអនុក្រឹត្យ តាមសំណើររបស់រដ្ឋម

ន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលនអាចចេញអនុក្រឹត្យបន្ថែមឥណទានដើម្បីប្រើប្រាស់។ ឥណទាននេះត្រូវអនុម័តដោយច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែលរាជរដ្ឋាភិបាលត្រូវសុំការយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់។ ដោយបដិបញ្ញត្តិនៃកថាខ័ណ្ឌខាងលើនៃច្បាប់នេះ បើច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុនេះពុំអាចធ្វើទៅកើតក្នុងត្រីមាសទី៤ នៃការិយបរិច្ឆេទនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់គ្រប់គ្រងឆ្នាំនីមួយៗ ឥណទានទាំងនេះជាកម្មវត្ថុនៃនិយ័តភាវូបនីយកម្មក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់។

ការកែប្រែផ្សេងៗទៀតលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ។

## ១០.៣. ដំណើរការនៃការអនុវត្តថវិកា

ការអនុវត្តកិច្ចការប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ និងគណនីពិសេសរបស់ធនាគារជាតិជាភារកិច្ចរបស់អាណាប័ក និងគណនេយ្យករសាធារណៈ។ អាណាប័ក និងគណនេយ្យសាធារណៈមានមុខងារវិសមិតភាពនឹងគ្នា។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ទាំងនៅក្នុងរដ្ឋបាលថ្នាក់ជាតិ និងទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមខ្សែបណ្តាយដែលស្ថិតក្រោមឱវាទ។ អាណាប័កដើមខ្សែជាអ្នកបញ្ជាចំណូល និងបញ្ជាចំណាយថវិកាតាមផ្នែករៀងៗខ្លួន។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិជាអណាប័កផ្ទេរសិទ្ធិ សម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនអាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទ ប្រធានមន្ទីជំនាញខេត្ត និងរាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីអាណាប័កដើមខ្សែ ឬអាណាប័កតាមការប្រទានសិទ្ធិអវត្តមាន ឬមានធុរៈកិច្ចអាចជ្រើសតាំងប្រភេទមន្ត្រីរាជការ ដើម្បីផ្ទេរសិទ្ធិ ឬជំនួសខ្លួនដោយផ្អែកលើ

បទបញ្ញាគណនេយ្យសាធារណៈ។ ការផ្ទេរសិទ្ធិ ឬការចុះហត្ថលេខាត្រូវធ្វើឡើងដោយប្រកាសបន្ទាប់ពីមានការយល់ព្រមជាមុខពីរដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណាយលើថវិការដ្ឋ និងលើគណនីពិសេសរបស់រតនាគារជាតិ ជាកម្មវត្ថុនៃការឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានទទួលការតែងតាំងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គោលបំណង និងហេតុផលជាក់ស្តែងនៃការត្រួតពិនិត្យនេះ ព្រមទាំងវិធីសាស្ត្រនៃកិច្ចប្រតិបត្តិការ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណាយថវិការដ្ឋរួមទាំងថវិកថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ និងថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងគណនីពិសេសរបស់រតនាគារជាតិក្នុងការទិញ ការជុសជុល ការសាងសង់ និងការជួលសេវា ត្រូវអនុវត្តតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

## ១១. គណនេយ្យ និងការត្រួតពិនិត្យលទ្ធផល

### ១១.១. ក្របខ័ណ្ឌគណនេយ្យ និងការទូទាត់ថវិកា

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភារៈកិច្ចរៀបចំ និងផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវរបាយការណ៍ស្តីពីការអនុវត្តថវិកា របាយការណ៍ស្តីពីការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់គេ ការបោះផ្សាយមូលបត្ររដ្ឋ ការធានា និងការសន្យានានាផ្នែកហិរញ្ញវត្ថុ ការទទួលហិរញ្ញប្បទានឥតសំណង និងដែលពាក់ព័ន្ធនឹងចំណូលមានប្រភពមកពីការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ និងព័ត៌មានចាំបាច់ផ្សេងៗទៀតតាមតម្រូវការរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានកាតព្វកិច្ចកំណត់កាលបរិច្ឆេទនៃកាផ្តល់ និងគំរូនៃរបាយការណ៍ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនៃមាត្រានេះ ដើម្បីជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត។

### ១១.២ ក្របខ័ណ្ឌគណនេយ្យ ការត្រួតពិនិត្យលទ្ធផល

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌ និងគ្រប់គ្រងកិច្ចប្រតិបត្តិការការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនដើម្បីធានាភាពត្រឹមត្រូវ និងស្របតាមបទដ្ឋាន បទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល។ ដោយឡែក រដ្ឋមន្ត្រីក្រសួងសេដ្ឋ

កិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការណែនាំអំពីការរៀបចំក្របខ័ណ្ឌ កិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពប្រហាក់ប្រហែល សហគ្រាសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យសាធារណៈទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រមូលផ្តុំនៅរតនាគារជាតិ និងអនុវត្តដោយគណនេយ្យការសាធារណៈ។ ប្រព័ន្ធគណនេយ្យសាធារណៈត្រូវមានសង្គតិភាពទៅនឹងនិយាមគណនេយ្យអន្តរជាតិដែលមានការទទួលស្គាល់ជាទូទៅ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ប្រព័ន្ធគណនេយ្យនេះ។ បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈត្រូវកំណត់គ្រប់ល័ក្ខខ័ណ្ឌ ដែលធ្វើឲ្យប្រតិបត្តិការគណនេយ្យ និងហិរញ្ញវត្ថុអាចកត់ត្រា វិភាគ និងគ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រកបដោយគណនេយ្យភាព ស័ក្តិសិទ្ធ និងប្រសិទ្ធភាព។

ការទូទាត់ថវិកា គឺជាកម្មវត្ថុនៃច្បាប់។ សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ពិនិត្យកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលគណនីទោលរបស់រតនាគារជាតិ និងអាណប័ណ្ណចំណាយដែលបានប្រព្រឹត្តនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។ សេចក្តីព្រាងច្បាប់នេះទុកជាមោឃៈនូវឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងឲ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុងគណនីលទ្ធផល របស់រតនាគារជាតិ។ សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវបានរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅតាមមាតិកាថវិកានីមួយៗ ដោយផ្អែកលើទិន្នន័យចំណូលចំណាយ ដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយអាណាប័កពាក់ព័ន្ធ។ ក្របខ័ណ្ឌ និងកិច្ចដំណើរការនៃសវនកម្មផ្ទៃក្រៅត្រូវបានអនុវត្តតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។

ប្រតិបត្តិការដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថិវិកាត្រូវឆ្លុះបញ្ចាំងនូវវិធានការគណនេយ្យសាធារណៈតាមលំនាំដូចខាងក្រោម៖

១. ចំពោះចំណូល៖ ការគ្រោងទុកដើមគ្រា ព្រមទាំងការកែប្រែ និងចំណូលជាក់ស្តែង ដែលបែងចែកតាមក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី។

២. ចំពោះចំណាយ៖ ការគ្រោងទុកដើមគ្រា ការអនុញ្ញាតថ្មី និងចំណាយជាក់ស្តែងទៅតាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមមាតិកាថវិកា។

៣. ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និងចំណាយនិងការកែប្រែដែលបានធ្វើ ប្រសិនបើមានជាមួយនឹងលទ្ធផលចុងក្រោយ នៃថវិការបស់រដ្ឋបាលសាធារណៈនីមួយៗ។ ប្រតិបត្តិការដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ទាំងថវិការដ្ឋ និងទាំងគណនីពិសេស

របស់រតនាគារជាតិ ត្រូវបង្ហាញជាលម្អិតនូវឥណទានដែលបានអនុម័តដើមឆ្នាំ និងឥណទានកែតម្រូវទៅតាមមាតិកាថវិកា។ សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ដែលត្រូវដាក់ជូនរដ្ឋសភាពសុំការអនុម័ត និងព្រឹទ្ធសភាសុំពិនិត្យ ត្រូវភ្ជាប់នូវៈ

១. របាយការណ៍វិភាគស្តីពីលទ្ធផលនៃការប្រមូលចំណូល និងស្ថានភាពនៃការអនុវត្តចំណាយថវិកា។

២. របាយការណ៍ស្តីពីស្ថានភាពទូទៅនៃសេដ្ឋកិច្ច និងហរិញ្ញវត្ថុនៅក្នុងឆ្នាំអនុវត្ត និងស្តីពីស្ថានភាពនៃការសម្រេចបាននូវតុល្យភាពម៉ាក្រូសេដ្ឋកិច្ច។

៣.តារាងតុល្យការរបស់រាជរដ្ឋាភិបាល។

ក្រោយពីបានប្រកាសឲ្យប្រើច្បាប់ទូទទាត់ថវិកា ត្រូវបោះផ្សាយដូចគ្នា នឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ។ គណនេយ្យករសាធារណៈទទួលបន្ទុកប្រមូលចំណូលទូទាត់ចំណាយរក្សាទុកដាក់មូលនិធិ មូលបត្រ ផលិតផល និងសម្ភារៈដែលជាកម្មសិទ្ធរបស់ស្ថាប័នសាធារណៈ។ មានតែគណនេយ្យករសាធារណៈមួយគត់ ដែលមានសិទ្ធអំណាចក្នុងការអនុវត្តប្រតិបត្តិការទាំងឡាយ និងដោះស្រាយបញ្ហាមូលនិធិពាក់ព័ន្ធដទៃទៀតជាមួយចំណូល និងចំណាយ។ ក្នុងសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈ មានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជាប្រាក់កាស។

គណនេយ្យករសាធារណៈ ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណនេយ្យករសាធារណៈមានអំណាចពិសេសរបស់ខ្លួន។ មុខចូលកាន់តំណែង គណនេយ្យករសាធារណៈត្រូវតែធ្វើសច្ចាប្រណិធានជាផ្លូវការតាមបែបបទត្រឹមត្រូវនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច។ អាណាប័កដើមខ្សែ និងអាណាប័កផ្ទេរសិទ្ធិព្រមទាំងគណនេយ្យករសាធារណៈដទៃទៀតត្រូវទទួលស្គាល់គណនេយ្យករសាធារណៈដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាល់ការអនុវត្តចំណូល និងចំណាយនៃថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញតិ និងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រាល់ការកត់ត្រា ចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគោរពទៅតាមប្លង់គណនេយ្យ និងមាតិកាថវិកា ហើយរាល់របាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុត្រូវមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ។ រាល់ប្រតិបត្តិហិរញ្ញវត្ថុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិចាត់តាំងមន្រ្តីក្រោមឱវាទចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាន និងទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំទូទាត់ថវិកាប្រចាំឆ្នាំ។

## ១២. ទោសប្បញ្ញត្តិ

មន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ ដែលបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ដែលរដ្ឋបានប្រគល់ជូនត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត។ ក្នុងករណីកំហុសរបស់មន្ត្រីសាធារណៈនោះបានធ្វើឲ្យមានការបាត់បង់ប្រាក់កាស ឬខូចខាតទ្រព្យសម្បត្តិសាធារណៈ នោះតម្លៃនៃការបាត់បង់ ឬខូចខាតរួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬខូចខាតនេះ នឹងក្លាយជាបំណុលចំពោះមន្ត្រីសាធារណៈនោះដែលត្រូវសង និងបង់ចូលថវិការដ្ឋវិញ។ មន្ត្រីសាធារណៈដែលបញ្ជាក់នៅក្នុងមាត្រា ៨៥នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ នេះរួមបញ្ចូលទាំងមន្ត្រីសាធារណៈដែលកំពុងបម្រើការងារ និងមន្ត្រីសាធារណៈដែលធ្លាប់បានបម្រើការងារ។

## ១៣. វិធីសាស្ត្រនៃការរៀបចំថវិកា

ចាប់តាំងពីដើមទសវត្សឆ្នាំ១៩៩០ រដ្ឋាភិបាលនៃបណ្តាលប្រទេសជាច្រើននៅលើពិភពលោកបានចាប់ផ្តើមធ្វើកំណែទម្រង់ថវិការបស់ខ្លួន ដោយបញ្ចូលទៅក្នុងវិធីសាស្ត្រ នៃការរៀបចំថវិកានូវទស្សនៈ និងវិធាននៃការរៀបចំថវិកាដោយផ្តោតលើលទ្ធផលក្នុងកម្រិតណាមួយ។ ជាក់ស្តែងដូចជាប្រទេសណូវែលហ្សឺលែន កាណាដា និងចក្រភពអង់គ្លេសជាដើម ដែលបានផ្លាស់ប្តូរការគ្រប់គ្រងពីការផ្តោតការត្រួតពិនិត្យលើធាតុចូល និងធនធានទៅជាការគ្រប់គ្រងដែលមានភាពទន់ភ្លន់ និងផ្តោតជាសំខាន់លើការតាមដានវាយតម្លៃលើការសម្រេចបានលទ្ធផល ឬសមិទ្ធកម្ម ហើយមាននិន្នាការនៃការផ្លាស់ប្តូរប្រព័ន្ធ និងការគ្រប់គ្រងនេះ ត្រូវបានបន្តរីកចម្រើនជាបន្តបន្ទាប់នៅគ្រប់តំបន់ទូទាំងពិភពលោករហូតមកដល់បច្ចុប្បន្ន។

គោលដៅប្រសិទ្ធភាព និងភាពស័ក្តិនៃការប្រើប្រាស់ថវិកា ឬនៃប្រព័ន្ធគ្រប់គ្រងថវិកាទាំងមូលដែលត្រូវបានយល់ថា ជាគោលដៅចាំបាច់ត្រូវតែសម្រេចឲ្យបាននោះ ក៏ឆ្លងតាមការវិវត្តិនៃវិទ្យាសាស្ត្រនយោបាយ និងសង្គម ហើយបណ្តាគោលដៅ ឬល័ក្ខខ័ណ្ឌដទៃទៀតក៏ត្រូវបានរកឃើញថាចាំបាច់ និងតម្រូវឲ្យមានផងដែរ ដូចជាគណនេយ្យភាព តម្លាភាព និងការគិតគូរជាពហុឆ្នាំជាដើម។

ជារួមបច្ចុប្បន្នមានវិធីសាស្ត្រ ៣ ក្នុងការរៀបចំថវិកាគឺ ១. ថវិកាតាមមាតិកា ដែលការរៀបចំថវិកាផ្អែកលើបន្ទាត់មាតិកាថវិកា ២.ថវិកាកម្មវិធី គឺជាការរៀបចំថវិកា ដោយផ្អែកលើកម្មវិធី និង៣. ថវិកាសមិទ្ធកម្ម គឺជាការរៀបចំថវិកាដោយផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម។

តាមបទពិសោធន៍ជាអន្តរជាតិត្រូវបានទទួលស្គាល់ថាមានប្រព័ន្ធគ្រប់គ្រងថវិកា ២ប្រភេទគឺ ១. ប្រព័ន្ធគ្រប់គ្រងថវិកាបែបបុរាណ ដែលជាប្រព័ន្ធប្រើថវិកាតាមមាតិកា និងការគ្រប់គ្រងផ្តោតលើធាតុចូលនិងមានលក្ខណៈមជ្ឈការខ្ពស់ និង ២. ប្រព័ន្ធគ្រប់គ្រងថវិកាបែបទំនើប ដែលជាប្រព័ន្ធប្រើវិធីសាស្ត្រថវិកាកម្មវិធីផង និងថវិកាសមិទ្ធកម្មផង ហើយការគ្រប់គ្រងផ្តោតលើធាតុចេញ (លទ្ធផល ឬសមិទ្ធកម្ម) និងមានលក្ខណៈវិមជ្ឈការ។ ប្រព័ន្ធទី២នេះ ជាប្រព័ន្ធកំពុងពេញនិយមដែលប្រទេសភាគច្រើនកំពុងអនុវត្ត ឬកំពុងធ្វើការកែទម្រង់ឆ្ពោះទៅរកដូចដែលកម្ពុជាបាន និងកំពុងធ្វើដំណើរការឆ្ពោះទៅរកក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ២០០៨ ដើម្បីបើកប្រឡូរាជរដ្ឋាភិបាលកម្ពុជាអាចផ្តើមអនុវត្តសាកល្បង ថវិកាកម្មវិធី និងក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារស្តីពី ទស្សនទានស្តីពីទិសដៅយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាឆ្នាំ ២០១៣-២០២០ ដោយបានប្តេជ្ញាធ្វើការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការក្នុងឆ្នាំ ២០២០។

ដោយផ្អែកតាមទស្សនទាននេះ ថវិកាកម្មវិធីត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងពេលលេញចាប់ពីឆ្នាំ ២០១៥ ហើយនៅក្នុងឆ្នាំ ២០១៨នេះ ត្រូវបានអនុវត្តពេលលេញគ្រប់ស្ថាប័នទាំងអស់។ ការអនុវត្ត ថវិកាកម្មវិធី គឺជាដំណើរការនៃការផ្លាស់ប្តូរឆ្ពោះទៅកាន់ប្រព័ន្ធថវិកផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ដោយក្រសួង ស្ថាប័ននីមួយៗអាចមានអង្គភាពថវិកាច្រើន។

ឆ្លងកាត់តាមបទពិសោធន៍នៃការអនុវត្តអស់រយៈពេលជាង ២ឆ្នាំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានកិច្ចសហការពីអ្នកជំនាញពាក់ព័ន្ធ បានធ្វើការសិក្សា និងវាយតម្លៃវឌ្ឍនភាពឡើងវិញអំពីការអនុវត្ត ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម ពីព្រោះចាប់តាំងពីពេលចាប់ផ្តើមមកដល់ពេលនេះ គឺបានធ្វើដំណើរបានពាក់កណ្តាលផ្លូវហើយ ហើយបរិការណ៍អន្តរជាតិក៏មានការប្រែប្រួលជាច្រើនក្នុងអភិក្រមឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្មដែរ។ ចំពោះកម្ពុជា ការវាយតម្លៃជាបឋមបានផ្តល់នូវការសន្និដ្ឋានថា ការសម្រេចចិត្តឲ្យបាន ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មនៅក្នុងឆ្នាំ២០២០ គឺជាមហិច្ឆតាខ្ពស់របស់កម្ពុជា។

## ១៣.១. គោលការណ៍នៃប្រព័ន្ធថវិកាផ្អែកលើថវិកាកម្មវិធី

គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាតាមវិធីសាស្ត្រថវិកាកម្មវិធី គឺជាការបង្កើតឲ្យមានដំណើរការធ្វផែនការជាយុទ្ធសាស្ត្រដើម្បីជួយសម្រួលដល់ការផ្សារភ្ជាប់ទំនាក់ទំនងថវិកាទៅនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល និងធ្វើការវិភាជន៍ធនធានឡើងវិញពីគោលនយោបាយជាអាទិភាពពីលើកមុនមកគោលនយោបាយជាអាទិភាពថ្មី។

គោលគំនិតចំបងនៃថវិកាកម្មវិធី គឺមានភាពសាមញ្ញ ពោលគឺកំណត់ពីលទ្ធផល និងទិន្នផលគន្លឹះ ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃគោលនយោបាយ បន្ទាប់មកកំណត់ពីសម្មភាពការងារដែលនឹងបង្កើតឲ្យមាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ ហើយការវិភាជន៍ធនធានរវាងកម្មវិធីដោយឈរលើមូលដ្ឋាន នៃលទ្ធផលដោយធ្វើការវាយតម្លៃជាប្រចាំ លើការអនុវត្តកម្មវិធី។ គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាកម្មវិធីឆ្នាំ ២០១៧ មានដូចខាងក្រោម៖

១. ការរិះរក និងធ្លុះរកប្រភពចំណូល៖ ដើម្បីបង្កើនចំណូលថវិកាឲ្យអស់លទ្ធភាព ហើយផ្អែកលើមូលដ្ឋាននេះ គិតគូរៀបចំចំណាយឲ្យ កាន់តែចំទិសដៅគោលនយោបាយ និងសន្សំសំចៃខ្ពស់ ។

២.ការកំណត់លំដាប់អាទិភាព៖ តាមរយៈការបន្តនូវភាពម៉ឺងម៉ាត់ និងការសម្រួចលើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាព របស់រាជរដ្ឋាភិល ព្រមទាំងទៅលើកម្មវិធី សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ កំណើនថវិកាត្រូវបានផ្តល់អាទិភាពជាសំខាន់ទៅលើកម្មវិធីអនុកម្មវិធី សកម្មភាពណាដែលអាចរំពឹងថានឹងសម្រេចបានលទ្ធផលជាក់លាក់ ជាពិសេសសកម្មភាពណាដែលអាចសម្រេចបានលទ្ធផលច្រើន ដោយចាយថវិកាតិច ។ លើសពីនេះ ក្នុងករណីដែលលទ្ធភាពថវិកានៅតែមិនអាចឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពថ្មីរបស់ក្រសួង-ស្ថាប័ន មុខចំណាយជាប្រចាំមួយចំនួនក៏ត្រូវបានយកមក ពិនិត្យធ្វើអាទិភាពឡើងវិញដែរ ។

៣. ការយកចិត្តទុកដាក់លើមនុស្ស៖ ទន្ទឹមនឹងបន្តបង្កើនប្រាក់បៀវត្សអប្បរមា ជូនមន្ត្រីរាជការគ្រប់ប្រភេទឆ្ពោះទៅច្រើនជាង ១លានរៀល នៅឆ្នាំ២០១៨ ថវិកាឆ្នាំ ២០១៧ បានដាក់ចេញថែមទៀត នូវវិធានការពន្ធដារពាក់ព័ន្ធនឹងការសម្រួលកម្រិតជាប់ពន្ធនៃប្រាក់បៀវត្ស ដើម្បីផ្តល់ការលើកទឹកចិត្ត និងរួមចំណែកលើកកម្ពស់ជីវភាពដល់មន្ត្រីរាជការ ពិសេស គ្រូបង្រៀន និងគ្រូពេទ្យ ព្រមទាំងកម្មករនិយោជិតដែលមានបៀវត្សទាប។ លើសពីនេះ ថវិកាឆ្នាំ ២០១៧ ក៏បានផ្តល់អាទិភាពដល់ការកសាងនិងពង្រឹងធនធានមនុស្ស និងផ្តល់ការយកចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រចំពោះមនុស្សដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់ ក៏ដូចជាការពង្រឹងគុណភាពសេវាសាធារណៈ ដែលផ្តល់ប្រយោជន៍ផ្ទាល់ដល់ប្រជាជនទូទៅ។

៤. ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី សកម្មភាព៖ ដោយគិតគូរឲ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ បរិមាណ និងគុណភាព ក្នុងការអនុវត្តកម្មវិធី សកម្មភាពតាំងពីក្នុងដំណាក់កាលនៃការរៀបចំថវិកាចៀសវាងការលើកគម្រោងចំណាយមានលក្ខណៈច្បោលៗ និងក្នុងលក្ខណៈប្រថុចញ៉ុច ដែលធ្វើឲ្យការវិភាជថវិកាមិនសូវមានប្រសិទ្ធភាព ហើយខ្ជះខ្ជាយថវិកានៅពេលអនុវត្ត។

៥. ការផ្ទេរថវិកាឲ្យដល់អង្គភាពអនុវត្ត ពិសេសនៅក្នុងវិស័យអាទិភាព ពោលគឺ វិស័យអប់រំ និងសុខាភិបាល ដោយបង្កើនការផ្ទេរថវិកាឲ្យទៅដល់អង្គភាពអនុវត្តការងារ

ផ្ទាល់ ដែលនៅក្រោមឱវាទក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្តាល ឬនៅតាមមូលដ្ឋាន ដូចជាសាលារៀ មន្ទីរពេទ្យ និងមណ្ឌលសុខភាពជាដើម។ល។ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពចំណាយ ជាពិសេសធានាបាននូវភាពទាន់ពេលវេលា និងការទទួលខុសត្រូវច្បាស់លាស់នៅក្នុងការគ្រប់គ្រង និងចាត់ចែងអនុវត្តថវិកា។

៦. ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា៖ តាមរយៈវិធានការផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពលើចំណាយមិនមែនបុគ្គលិកដល់ក្រសួងស្ថាប័នដែលកៀរគរចំណូលបាន ដោយការខិតខំអនុវត្តសកម្មភាពប្រមូលចំណូល ហើយបានបង់ចំណូលមួយភាគធំចូលថវិការដ្ឋ។ ទន្ទឹមនឹងការរឹតត្បិតលើការស្នើសុំបង្កើនថវិកាចំពោះក្រសួងស្ថាប័នដែលការប្រមូលចំណូល មិនអាចសម្រេចបានលទ្ធផលសមស្របតាមសក្តានុពលជាក់ស្តែង ឬដែលមានទំហំចំណែកប្រាក់រង្វាន់ធំ។ ។

៧. ការរក្សាតុល្យភាពថវិកា៖ ទោះបីជាស្ថិតក្រោមសម្ពាធនៃតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ ជាពិសេស សម្ពាធនៃចំណាយបន្ទុកបុគ្គលិក ចំណាយចរន្តមិនមែនបន្ទុកបុគ្គលិកដែលកើតឡើងថ្មីៗ ព្រមទាំងចំណាយវិនិយោគដើម្បីជំរុញការអភិវឌ្ឍ ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ហើយនៅក្នុងពេលដំណាលគ្នានេះ ការប្រមូលចំណូលក៏នៅបន្តជួបបញ្ហាប្រឈម និងហានិភ័យមួយចំនួនធំក៏ដោយ ការរៀបចំថវិកាឆ្នាំ ២០១៧ ត្រូវបានធ្វើលើមូលដ្ឋាននៃការធានាឲ្យបាននូវតុល្យភាព ហើយទន្ទឹមនឹងនេះ ក៏មានការត្រៀមបម្រុងសម្រាប់សេចក្តីត្រូវការមិនបានគ្រោងទុក និងសម្រាប់ការធ្វើអន្តរាគមន៍ចាំបាច់ ជាយថាហេតុរបស់រាជរដ្ឋាភិបាលក្នុងវិស័យសេដ្ឋកិច្ច និងសង្គមផងដែរ។

៨. ការគ្រប់គ្រងបំណុលសាធារណៈ ប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន០៤ គឺ ១. ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រទ្រង់បាន ២. ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬល័ក្ខខ័ណ្ឌអនុគ្រោះខ្ពស់ ៣. ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើន និងវិស័យបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ៤. ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

## ១៣.២. គោលការណ៍នៃប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម

រាជរដ្ឋាភិបាលបានកំណត់យកការកែទម្រង់ប្រព័ន្ធថវិកា ជាស្នូលនៃកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបានដាក់ចេញនូវទិសដៅនិងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ ២០១៧-២០២៥។ ក្នុងគោលដៅខាងលើនេះក្របខ័ណ្ឌថវិការយៈពេលមធ្យមនឹងត្រូវបង្កើតឡើង ដោយផ្អែកលើក្របខ័ណ្ឌ

ចំណូលរយៈពេលមធ្យម ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យនិងអនុម័ត។

ប្រព័ន្ធថវិកាសមិទ្ធកម្មគឺផ្តោតទៅលើការយកចិត្តទុកដាក់លើ សូចនាករសមិទ្ធកម្ម ដែលជាលទ្ធផលនៃការងារដែលក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាលគ្រោងនឹងសម្រេចឲ្យបានដោយប្រើប្រាស់កញ្ចប់ថវិកាដែលខ្លួនបានទទួល។ ក្នុងន័យនេះ ជាទ្រឹស្តី សូចនាករសមិទ្ធកម្ម គឺជាមូលដ្ឋាននៃការវិភាជន៍ថវិការដល់ក្រសួង ស្ថាប័ន។ ប្រសិនបើក្រសួង ស្ថាប័នសម្រេចបានសមិទ្ធផលតិច នឹងទទួលបានថវិកាតិច ហើយប្រសិនបើក្រសួង ស្ថាប័នមិនមានសមិទ្ធកម្ម គឺមិនទទួលបានថវិកាតែម្តង។ សូចនាករសមិទ្ធកម្មនឹងត្រូវបានភ្ជាប់ជាមួយនឹងសេចក្តីព្រាងច្បាប់ថវិកា ដើម្បីជាព័ត៌មាន និងជាមូលដ្ឋានសម្រាប់ឆ្លុះបញ្ចាំងលទ្ធផលការងារដែលសម្រេចបាននៅឆ្នាំនីមួយៗ។

ប៉ុន្តែការសិក្សាពីបទពិសោធន៍អន្តរជាតិបានបង្ហាញថា ប្រព័ន្ធថវិកាសមិទ្ធកម្មអាចអនុវត្តតាម៣ម៉ូដែលដែលមានដូចខាងក្រោម៖

១. ប្រព័ន្ធថវិកាបង្ហាញសមិទ្ធកម្ម៖ តាមម៉ូលដែលនេះ ព័ត៌មានសមិទ្ធកម្មបង្ហាញក្នុងឯកសារថវិកា ឬឯកសារផ្សេងៗរបស់រដ្ឋាភិបាល។ ព័ត៌មានសមិទ្ធកម្មសំដៅដល់គោលដៅ ឬលទ្ធផល ឬព័ត៌មានទាំងពីមុខនេះដែលនឹងត្រូវបានបញ្ចូលជាសារតាសម្រាប់គណនេយ្យភាព និងសម្រាប់កិច្ចពិភាក្សាអំពីបញ្ហាគោលនយោបាយសាធារណៈជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងសាធារណជន។ ក៏ប៉ុន្តែព័ត៌មានសមិទ្ធកម្មទាំងនោះមិនមានឥទ្ធិពលជាផ្លូវការចំពោះការសម្រេចនានា នៅក្នុងដំណើរការរៀបចំថវិកានោះទេ។

២. ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម៖ តាមម៉ូដែលនេះ ការរៀបចំកញ្ចប់ថវិកាមានការពាក់ព័ន្ធជាប្រយោលជាមួយនឹងសមិទ្ធកម្មដែលបានស្នើឡើង ឬដែលសម្រេចបានកន្លងមក ដោយក្រសួង ស្ថាប័ន។ ព័ត៌មានសមិទ្ធកម្មមានតួនាទីសំខាន់ ប៉ុន្តែមិនមែនជាទម្ងន់ ឬជាកត្តាកំណត់ដាច់ខាត សម្រាប់ធ្វើការសម្រេចលើការវិភាជន៍ថវិកានោះទេ។ ក្នុងន័យនេះព័ត៌មានសមិទ្ធកម្មមិនមែនជាមូលដ្ឋានតែមួគត់នោះទេ ប៉ុន្តែត្រូវប្រើគួបផ្សំជាមួយនឹងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងសេដ្ឋកិច្ច នយោបាយ និងអាទិភាពគោលនយោបាយសម្រាប់ការសម្រេចចិត្តលើការវិភាជន៍ថវិកា ឬធនធាន។

៣. ប្រព័ន្ធថវិកាសមិទ្ធកម្មផ្ទាល់ ឬប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម៖ តាមម៉ូដែលនេះ ការវិភាជន៍ធនធានធ្វើឡើងដោយផ្ទាល់ និងច្បាស់លាស់ទៅតាមឯកតាសមិទ្ធកម្មដែលត្រូវសម្រេចបាន ដែលជាទូទៅគឺផ្តោតលើលទ្ធផលក្នុងឆ្នាំ។

ជារួមម៉ូដែលទាំង៣ខុសគ្នានៅត្រង់កម្រិតនៃការប្រើប្រាសសូចនាករសមិទ្ធកម្មតាមទម្ងន់ផ្សេងៗគ្នានៅក្នុងការវិភាជន៍ថវិកា ដោយម៉ូដែលទី២ មានលក្ខណៈកណ្តាល គឺផ្តល់នូវភាពបត់បែន និងទន់ភ្លន់ល្មមក្នុងការប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម ពោលគឺមិនធូររលុងពេក ដែលអាចនឹងនាំឲ្យការអនុវត្តថវិកាសមិទ្ធកម្មមិនសូវមានន័យ និងមិនរឹងត្អឹងពេក ដែលនាំឲ្យការអនុវត្តមានលក្ខណៈដូចជាគ្រឿង

ម៉ាស៊ីន ឬក៏ជាគម្ពីរនិយម។ ដោយសារប្រទេសភាគច្រើនកំពុងអនុវត្តតាមម៉ូដែលទី ២ និងតាមការវាយតម្លៃអំពីបរិការណ៍ ល្បឿន និងជម្រៅនៃការកែទម្រង់បច្ចុប្បន្ន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយល់ថា កម្ពុជាគួរជ្រើសរើសយកប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ជាទិសដៅជាក់លាក់នៃការកែទម្រង់ប្រព័ន្ធថវិកា ដោយកំណត់យកគោលដៅពេលវេលាដែលត្រូវសម្រេចឲ្យបាននៅឆ្នាំ២០២៥ស្របតាមគោលដៅនៃជំហានទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។

# ឯកសារយោង

០១. ហង់ ជួនណារ៉ុន និង ប៉ាទ្រីកហ្សីលបែ - ដឺវ៉ាល់ឡុង (២០០៩)៖ ហិរញ្ញវត្ថុសាធារណៈ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារ បោះពុម្ពលើកទី១។
០២. ស៊ិន សំណាង មាស ភិរុណ ឃួន វិច្ឆិក និងឌី ខាំបូលី (២០១៧)៖ ប្រវត្តិវិទ្យា សម័យអាណាចក្របារាំង ព្រះរាជាណាចក្រកម្ពុជាទី២ សេចក្តីសង្ខេបមេរៀនប្រវិត្តសាស្ត្រខ្មែរសម្រាប់ជំនួយសារតីដល់សិស្សថ្នាក់ទី១២ ក្រសួងអប់រំ យុវជន និងកីឡា។
០៣. ហែម ចន្ទី (២០១២)៖ របាយការណ៍ស្រាវជ្រាវស្តីពីបញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅអង្គភាបរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសក្សាអធិការរដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
០៤. អ៊ឹម សុផល (១៩៩៧)៖ ការគ្រប់គ្រងពន្ធ ដោយវិទ្យាស្ថានជាតិនៃកម្ពុជា បោះពុម្ពលើកទី២។
០៥. គង់ ប៊ុនធី (២០១៦)៖ សារពើពន្ធធុរកិច្ច ដោយបណ្ណាគារច្បាប់កម្ពុជា។
០៦. ខឹមសារិទ្ធ (២០១៨)៖ ហិរញ្ញវត្ថុសាធារណៈ ដោយសាកលវិទ្យាល័យបៀលប្រាយ។
០៧. ដេវិត ឆាណ្ឌលែរ (២០០៨)៖ ប្រវត្តិសាស្ត្រខ្មែរ របស់ បោះពុម្ពលើកទី៤។
០៨. ត្រឹង ងា (២០០១)៖ ប្រវត្តិសាស្ត្រខ្មែរ។
០៩. ខាត់ ធី (២០០៩)៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា។
១០. ខួយ ខេមរិន (១៩៨៨)៖ ប្រវិត្តិសាស្ត្រកម្ពុជា។
១១. មីសែល ត្រាណេ (១៩៩៦, ២០០៣)៖ ព្រះបាទជ័យវរ្ម័នទី៧ និងប្រវត្តិសាស្ត្រនៃកម្ពុជា សង្គមខ្មែរក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧។
១២. ហិសតុ និងរៀបចំចងក្រងសម្រួលជាភាសាខ្មែរដោយ អួង វង (២០០៦)៖ ប្រវត្តិសាស្ត្រាសង្ខបនៃរាជធានីក្នុងតំបន់អង្គរ និងសង្គមខ្មែរក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៧។
១៣. ព្រះរាជាណាចក្រកម្ពុជា (១៩៩៣)៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
១៤. រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា (២០១៧)៖ បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា។
១៥. រាជរដ្ឋាភិបាលកម្ពុជា (២០២០)៖ សាររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជូនជនរួមជាតិស្តីពីវិធានការរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងផលប៉ះពាល់ពីជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (ខូវិដ-១៩) និងការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួន ក្រោមកម្មវិធីទំនិញគ្រប់មុខ លើកលែងអាវុធ (EBA)។
១៦. ធនាគារជាតិនៃកម្ពុជា (១៩៩៦)៖ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា។
១៧. វិទ្យាស្ថានសភាកម្ពុជា(២០១៩)៖ សង្ខបស្តីពីថវិកាជាតិឆ្នាំ ២០២០ ទិដ្ឋភាពទូទៅនៃសេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ២០២០ ដើម្បីគាំទ្រដល់សមាជិកសភាក្នុងដំណើរការអនុម័ត បោះពុម្ពដោយព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។
១៨. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (២០០៨)៖ ការវិភាគការអនុវត្តថវិកាឆ្នាំ២០០៧ និងច្បាប់ថវិកាឆ្នាំ២០០៨។
១៩. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (២០០៧)៖ សៀវភៅណែនាំអំពីថវិកាជាតិ។

២០. អង្គការអន្តរជាតិខាងការងារ (២០១២)៖ កម្ពុជាឆ្ពោះទៅកាន់យុទ្ធសាស្ត្រជាតិមុខរបរ និងការងារដើម្បីកាត់បន្ថយភាពក្រីក្រដោយនិរន្តរភាព គម្រោងបង្កើនកិច្ចគាំពារសង្គម និងមុខរបរ ការិយាល័យអន្តរជាតិខាងការងារប្រចាំទីក្រុងហ្សឺណែវឆ្នាំ២០១២។
២១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២០)៖ សេចក្តីព្រាងក្របខ័ណ្ឌ គោលនយោបាយម៉ាក្រូ សេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។
២២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៨)៖ អនុក្រឹត្យស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
២៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១៩៩៦)៖ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
២៤. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៥)៖ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។
២៥. ក្រសួងកិច្ច និងហិរញ្ញវត្ថុ (២០១៥)៖ របាយការណ៍វាយតម្លៃអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈរបស់កម្ពុជាឆ្នាំ២០១៥ ផ្អែកលើក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)។
២៦. រាជរដ្ឋាភិបាលកម្ពុជា (២០១៨)៖ យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា។
២៧. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២០)៖ សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣។
២៨. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៨)៖ ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។
២៩. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)៖ ប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។
៣០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១៩៩៤- ២០២១)៖ ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។
៣១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១៩៩៧)៖ ច្បាប់ស្តីពីសារពើពន្ធ។
៣២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៣)៖ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ។
៣៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៣)៖ ក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
៣៤. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៣)៖ ទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រ នៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០។
៣៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៨)៖ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។
៣៦. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៨)៖ សមិទ្ធផល និងទិសដៅ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេល៥ឆ្នាំ ដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
៣៧. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៦)៖ សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧។

៣៨. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៩)៖ សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២។
៣៩. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៩)៖ សេចក្តីថ្លែងហេតុអំពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩។
៤០. អាជ្ញាធរសវនកម្មជាតិ (២០០០)៖ ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ។
៤១. Toshihiro Lhori. (2017). Principles of Public Finance, National Gradual institute for Policy Studies Minato-ku, tokyo, Japan, Springer Texts in Business and Economics, JP.
៤២. David N. Hyman. (2011). Public Finance, A Contemporary Application of Theory to Policy, 10th Edition, North Carolina State University, USA.
៤៣. Laurance S. Seidman. (2002). Public Fiance, 1st Edition, Mc Graw-Hill Company, USA.
៤៤. Richard A. Musgrave, Peggy B. Musgrave. (1989). Public Finance in Theory and Practice, 5th Edition, Mc Graw-Hill Company, USA.
៤៥. Holley H. Ulbrich. (2011). Public Finance in Theory and Practice, 2th Edition, Mc Routledge, London and New York, USA.
៤៦. Joshua E. Greene. (2012). Public Finance, An International Perspective, World Scientific Publishing, USA.
៤៧. Richard Allen, Richard Hemming and Barry H. Potter. (2013). The International Handbook Of Public Financial Management, 1st Edition, Palgrave Macmillan, UK.
៤៨. D. A. L. Auld and F. C. Miller. (1984). Principles of Public Finance, A Canadian Text, 2nd Edition Revised, Methuen Publication, Canada.
៤៩. Michael E. Kraft & Scott R. Furlong. (2018). Public Policy: Polititcs, Analysis, and Alternatives, 6th Edition, Sage Publication, USA.
៥០. Harvey S. Rosen. (2005). Public Finance, 7th Edition, Mc Graw Hill, USA.
៥១. Michael E. Kraft & Scott R. Furlong. (2018). Public Policy: Polititcs, Analysis, and Alternatives, 6th Edition, Sage Publication, USA.

໕໒. Clifford Winston. (2006). Government Failure versus Market Failure, Microeconomics Policy Research and Government Performance, USA.

໕໓. Joseph E. Stiglitz. (2000). Economics for the Public Sector, 3rd Edition, USA.

໕໔. Mankiw (2010). Macroeconomics, 7th Edition, World Publisher, USA.

**ហិរញ្ញវត្ថុសាធារណៈ:** សំដៅលើសកម្មភាពផ្នែកហិរញ្ញវត្ថុ ដែលជាចំណូល និងចំណាយ ជាឧបករណ៍នៃសកម្មភាព និងមធ្យោបាយផ្សេងៗរបស់រដ្ឋាភិបាលនៃប្រទេសមួយ តាមរយៈដំណើរការកៀរគរ ការប្រមូលចំណូល និងដំណើរការទូទាត់ ការចំណាយដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលចំណូល និងការធ្វើវិចារណកម្មចំណាយៗ ចំណូលកើនឡើងនឹងជួយដល់សកម្មភាពនៃការផលិត ការផ្គត់ផ្គង់ និងការផ្តល់ជូនទំនិញ និងសេវាសាធារណៈជាដើម ហើយចំណាយដែលប្រកបដោយវិចារណកម្ម នឹងត្រូវបានរួមចំណែកយ៉ាងសំខាន់ធ្វើឲ្យសេដ្ឋកិច្ចប្រទេសជាតិមានការរីកចម្រើនខ្ពស់ និងជួយពង្រឹងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌ជាដើមៗ សកម្មភាព តួនាទីក៏ដូចជាមុខងារនៃហិរញ្ញវត្ថុសាធារណៈ ជាទូទៅត្រូវបានផ្តោតទៅលើសកម្មភាពរបស់រដ្ឋាភិបាលលើចំណុចសំខាន់ធំៗចំនួនបីគឺៈ **មុខងារនៃវិភាជន៍ធនធាន មុខងារនៃចំណែងចែកចំណូល និងមុខងារនៃស្ថិរភាព។**

**គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ**
**ក្រសួងអប់រំ យុវជន និងកីឡា**

**មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍**

# ក្របសៀវភៅសម្រាប់បោះពុម្ព

**ហិរញ្ញវត្ថុសាធារណៈ** សំដៅលើសកម្មភាពផ្នែកហិរញ្ញវត្ថុ ដែលជាចំណូល និងចំណាយ ជាឧបករណ៍នៃសកម្មភាព និងមធ្យោបាយផ្សេងៗរបស់រដ្ឋាភិបាលនៃប្រទេសមួយ តាមរយៈដំណើរការក្សៀរគរ ការប្រមូលចំណូល និងដំណើរការទូទាត់ ការចំណាយដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលចំណូល និងការធ្វើវិចារណកម្មចំណាយ។ ចំណូលកើនឡើងនឹងជួយដល់សកម្មភាពនៃការផលិត ការផ្គត់ផ្គង់ និងការផ្តល់ជូនទំនិញ និងសេវាសាធារណៈជាដើម ហើយចំណាយដែលប្រកបដោយវិចារណកម្ម នឹងត្រូវបានរួមចំណែកយ៉ាងសំខាន់ធ្វើឲ្យសេដ្ឋកិច្ចប្រទេសជាតិមានការរីកចម្រើនខ្ពស់ និងជួយពង្រឹងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌ជាដើម។ សកម្មភាព តួនាទីក៏ដូចជាមុខងារនៃហិរញ្ញវត្ថុសាធារណៈ ជាទូទៅត្រូវបានផ្តោតទៅលើសកម្មភាពរបស់រដ្ឋាភិបាលលើចំណុចសំខាន់ធំៗចំនួនបីគឺៈ **មុខងារនៃវិភាជន៍ធនធាន មុខងារនៃចំណែងចែកចំណូល និងមុខងារនៃស្ថិរភាព។**

**គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ**
**ក្រសួងអប់រំ យុវជន និងកីឡា**

**មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍**

CAMBODIA

ហិរញ្ញវត្ថុសាធារណៈ

លោក ជាង គីរីរម្យ

រក្សាសិទ្ធិគ្រប់យ៉ាង

ឆ្នាំ ២០២១

# សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management

# ហិរញ្ញវត្ថុសាធារណៈ



**លោក ជាង គីរីរម្យ**

រក្សាសិទ្ធិគ្រប់យ៉ាង

ឆ្នាំ ២០២១